សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បណ្តឹងឧបាស្រ័យក្នុងនីតិវិធី
# ចាត់ចែងរក្សាការពារ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១


| | | | |
|---|---|---|---|
| តាក់តែងឡើងដោយ | | សាស្ត្រាចារ្យណែនាំ | |
| និស្សិតឈ្មោះ | **ពៅ រក្សា** | លោក **ហ៊ីង គឹមឡេង** | |
| | **ស្រៀង វឌ្ឍនា** | | |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលសិក្សា | ២០១៧ |
| ជំនាន់ទី ២១ | | ឆ្នាំសរសេរសារណា | ២០២១ |

# សេចក្តីថ្លែងអំណរគុណ

ការទទួលបាននូវភាពជោគជ័យក្នុងការសម្រេចភារកិច្ចអ្វីមួយ វាមិនមែនជារឿងងាយស្រួលនោះទេ ហើយ វាកាន់តែពិបាក ដើម្បីធ្វើវាឡើងតែម្នាក់ឯង ពិតណាស់គឺត្រូវតែមានដៃគូរសហការណ៍ដ៏ល្អ និងពូកែរួមគ្នាធ្វើ ព្រម ទាំងមានអ្នកជួយជំរុញ និងលើកទឹកចិត្តគាំទ្រពីសំណាក់ក្រុមគ្រួសារ អ្នកនៅជុំវិញខ្លួនទើបអាចធ្វើឡើង ដោយទទួលបានលទ្ធផលល្អប្រសើរ។

យ៉ាងណាមិញ ក្នុងនាមខ្ញុំបាទជានិស្សិតឈ្មោះ **ពៅ រក្សា** និង **ស្រៀង វឌ្ឍនា** ដែលទទួល ឪកាស ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ អាស្រ័យទៅបានដោយមានការជួយ ជំរុញ និងលើកទឹកចិត្តពីក្រុមគ្រួសារ និងបុគ្គលសំខាន់ៗដែលក្នុងនោះ យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ៖

-លោកឪពុក **ចិក ពៅ** អ្នកម្តាយ **ចៅ ចាន់គង់** និងអ្នកម្តាយ **ទី ស៊ីនឿន** បងស្រី **ស្រៀង សុវណ្ណសិលា** ដែលមាននូវព្រហ្មវិហារធម៌ និងសង្គហធម៌ចំពោះកូនៗ និងប្អូន រួមមានយាយតា ពូមីង បងប្អូន ជាដើម ដែលតែងតែជួយមើលការខុសត្រូវ និងអប់រំណែនាំ ផ្តល់ដំបូន្មានល្អៗ ដល់រូបយើងខ្ញុំ។

-លោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ជាសាស្ត្រាចារ្យណែនាំដ៏ល្អមួយរូប ក្នុងការជួយឲ្យសារណា របស់យើងខ្ញុំបានគ្រប់ជ្រុងជ្រោយ និងល្អប្រសើរ តាមរយៈការខិតខំប្រឹងប្រែងពន្យល់ណែនាំ ផ្តល់ជាមតិយោបល់ ល្អៗ និងការកែតម្រូវនូវរាល់ខ្លឹមសារ ដែលលើសលស់ ឬខ្វះខាតជាដើម។

-ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ បុគ្គលិកបម្រើ ការនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំ ដឹកនាំគ្រប់គ្រង បំពេញ ការងារ បង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ ដើម្បីធ្វើការបណ្តុះបណ្តាល និស្សិត ឲ្យក្លាយទៅជាធនធានមនុស្ស ដ៏ពិតប្រាកដ ប្រកដដោយគុណភាព គុណធម៌ និងភាតរភាព ជាពិសេស ឲ្យទៅជាយុវជនគំរូ និងជាសសរទ្រូង យ៉ាងរឹងមាំ សម្រាប់ទ្រទ្រង់ប្រទេសជាតិ ប្រកប ដោយសន្តិសុខ សន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍ។

ដោយអំណាចនៃគុណានុភាព ដែលពួកលោកបានធ្វើនូវសេចក្តីល្អ ក៏ដូចជាការខិតខំប្រឹង ប្រែងសព្វ បែបយ៉ាងមកលើយើងខ្ញុំ គឺយើងខ្ញុំគ្មានអ្វីជាការតបស្នងសងគុណធំដុំចំពោះពួកលោកនោះទេ មានតែសូមបួង សួងដល់វត្ថុសក្តិសិទ្ធិក្នុងលោក តាមជួយទំនុកបម្រុងបីបាច់ថែរក្សាឃុំគ្រងពួកលោកទាំងអស់គ្នា សូមបានតែសិរី សួស្តី ជ័យមង្គល វិបុលសុខ សុភមង្គលគ្រប់ប្រការ ចូលកើតមានដល់អស់លោកគ្រប់គ្នាជានិច្ចនិរន្តតទៅ ។

ថ្ងៃពុធ ១៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១

# អារម្ភកថា

បណ្តឹងឧបាស្រ័យនៃនីតិវិធីចាត់ចែងរក្សាការពារ ជាប្រធានបទដែលមានភាពស្មុគស្មាញ ហើយងាយ និងមានការភាន់ច្រឡំទាំងលើលិខិតតូបករណ៍គតិយុត្ត ទ្រឹស្តីពាក់ព័ន្ធ និងការអនុវត្តជាក់ស្តែង។ ភាពស្មុគស្មាញ ការភាន់ច្រឡំ និងភាពលំបាកពាក់ព័ន្ធនឹងបណ្តឹងឧបាស្រ័យនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារនេះ មិនមែនមាន តែចំពោះការសិក្សាទៅលើទ្រឹស្តីនោះទេ ប៉ុន្តែវាក៏មានភាពស្មុគស្មាញ និងការលំបាកសម្រាប់ភាគី និងតុលាការ ដូចគ្នាផងដែរ។ បណ្តឹងឧបាស្រ័យនៃក្នុងនីតិវិធីចាត់ចែងរក្សាការពារនេះ មានភាពខុសគ្នាពីបណ្តឹងឧបាស្រ័យ នៅក្នុងនីតិវិធីបណ្តឹងទូទៅ និងឧបាស្រ័យក្នុងនីតិវិធីអនុវត្តដោយបង្ខំ ដោយសារក្នុងនីតិវិធីចាត់ចែងរក្សាការពារ ភាគីដែលមិនសុខចិត្តទៅនឹងការសម្រេចសេចក្តីរបស់តុលាការ មិនសុទ្ធតែអាចប្រើប្រាស់សិទ្ធិរបស់ខ្លួននៅក្នុង ការធ្វើបណ្តឹងជំទាស់បានភ្លាមៗនោះទេ។

ដោយហេតុថា ក្រោយពីការសិក្សាទៅលើទ្រឹស្តីក្នុងថ្នាក់បរិញ្ញាបត្រមកនេះឃើញថា បណ្តឹងឧបាស្រ័យ ក្នុងនីតិវិធីចាត់ចែងរក្សាការពារនេះ មានភាពស្មុគស្មាញ និងងាយមានការភាន់ច្រឡំ ហេតុដូច្នេះទើបយើងខ្ញុំ សម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី **បណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ** ។ សារណាបញ្ចប់ការ សិក្សានេះ ក៏បង្ហាញឱ្យឃើញយ៉ាងច្បាស់ពីឆន្ទៈមុតមាំក្នុងការខិតខំប្រឹងប្រែង ការជំនះរាល់កត្តាលំបាកជាច្រើន នៅក្នុងស្ថានភាពដ៏លំបាក នៃការរាតត្បាតនូវជម្ងឺដ៏កាចសាហាវ ពោលគឺជម្ងឺ កូវីត-១៩ ដើម្បីទទួលបាននូវ សមិទ្ធផលជូនគណៈកម្មាវាយតម្លៃសារណា និងលោកគ្រូអ្នកគ្រូពិនិត្យ និងវាយតម្លៃ ព្រមទាំងទុកជាជំនួយ ស្មារតីសម្រាប់មិត្តៗសិស្សនិស្សិតក្នុងការស្រាវជ្រាវ ដើម្បីពង្រឹងពង្រីកពុទ្ធិបន្ថែម។

បើចង់ដឹងថា ខ្លឹមសារនៃសារណានេះ មានអត្ថន័យ អត្ថរស មានអត្ថប្រយោជន៍យ៉ាងណាចំពោះលោក អ្នក គឺលោកអ្នកគ្រាន់តែបង្អោនចិត្ត ដាក់កាយ ហើយចំណាយពេលវេលាខ្លះៗ ដើម្បីអាន និងគក់ត្រានៅចំណុច សំខាន់ៗទុក អ្នកនឹងដឹងថា សៀវភៅនេះមានអត្ថប្រយោជន៍អ្វីខ្លះ។

ជាចុងក្រោយ យើងខ្ញុំ ដែលជាអ្នកសិក្សាស្រាវជ្រាវ និងតាក់តែងសៀវភៅសារណានេះឡើង ក៏សូមលើក ដៃប្រណមឡើង ខន្តីអភ័យទោសចំពោះលោកអ្នកសិក្សាទាំងឡាយ នូវរាល់កំហុសឆ្គងទាំងអត្ថន័យ អត្ថរស ខ្លឹម សារ ពាក្យពេជន៍ ឃ្លោងឃ្លា និងអក្ខរាវិរុទ្ធជាដើម ដែលកើតឡើងដោយ អចេតនា។ ហើយយើងខ្ញុំ ដែលជាអ្នក តាក់តែងសង្ឃឹមជឿកជាក់យ៉ាងមុតមាំថា សៀវភៅនេះ នឹងបានជាអត្ថប្រយោជន៍ ក៏ដូចជាឯកសារយោងដល់ អ្នកសិក្សាស្រាវជ្រាវទៅថ្ងៃអនាគត។

ថ្ងៃពុធ ១៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ........ i

**អារម្ភកថា** ........ ii

**បញ្ជីពាក្យនាមឧបសម្ព័ន្ធ** ........ iii

**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**សញ្ញាណនៃបណ្តឹងឧបាស្រ័យ និងនីតិវិធី**

**ចាត់ចែងរក្សាការពារ**

**កថាភាគទី ១ ៖ សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ** ........ ៣

**ផ្នែកទី ១ ៖ អត្ថន័យនៃបណ្តឹងឧបាស្រ័យ** ........ ៣

១. ទស្សនៈក្នុងបណ្តឹងឧបាស្រ័យ ........ ៣

២. ការធ្វើបណ្តឹងឧបាស្រ័យ ........ ៤

**ផ្នែកទី ២ ៖ គោលបំណងនៃបណ្តឹងឧបាស្រ័យ** ........ ៤

១. ការសង្គ្រោះសិទ្ធិរបស់ភាគី ........ ៤

២. ការចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ ឬផ្តល់យុត្តិធម៌ដល់ភាគី ........ ៥

**ផ្នែកទី ៣ ៖ ភាពខុសគ្នារវាងបណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី និងបណ្តឹងឧបាស្រ័យ** ........ ៥

១. បណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី ........ ៥

២. បណ្តឹងឧបាស្រ័យ ........ ៥

**កថាខណ្ឌទី ២ ៖ សញ្ញាណនៃនីតិវិធីចាត់ចែងរក្សាការពារ** ........ ៦

**ផ្នែកទី ១ ៖ បទដ្ឋានគតិយុត្តិនៃការចាត់ចែងរក្សាការពារ** ........ ៦

១. គោលបំណងនៃការចាត់ចែងរក្សាការពារ ........ ៦

២. វិសាលភាពនៃការចាត់ចែងរក្សាការពារ ........ ៧

៣. មូលហេតុនៃការស្នើសុំរក្សាការពារ ........ ៧

**ផ្នែកទី ២ ៖ ប្រភេទនៃការចាត់ចែងរក្សាការពារក្នុងសំណុំរឿងរដ្ឋប្បវេណី** ........ ៨

១. ការរឹបអូសបណ្តោះអាសន្ន ........ ៨

២. ការចាត់ចែងរក្សាការពារបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ........ ៩

៣. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន ........ ៩

**ផ្នែកទី ៣ ៖ លក្ខណៈទូទៅនៃការចាត់ចែងរក្សាការពារ** ........ ១០

១. លក្ខណៈបណ្តោះអាសន្ន ........ ១០

២. លក្ខណៈបន្ទាន់បង្ខំ ........ ១០

៣. លក្ខណៈបន្ទាន់បន្ស៊ំ ............ ១០
៤. លក្ខណៈសម្ងាត់ ............ ១១
**ផ្នែកទី ៤ ៖ ដែនសមត្ថកិច្ចនៃនីតិវិធីចាត់ចែងរក្សាការពារ ដែនសមត្ថកិច្ចតុលាការ** ............ ១១
**ផ្នែកទី ៥ ៖ បណ្ដឹងឧបាស្រ័យនៃនីតិវិធីចាត់ចែងរក្សាការពារ** ............ ១១

## ជំពូកទី ២
## ប្រភេទនៃបណ្ដឹងឧបាស្រ័យនៅ
## តុលាការជាន់ខ្ពស់

**កថាភាគទី ១ ៖ បណ្ដឹងឧទ្ធរណ៍** ............ ១២
១. របៀបធ្វើបណ្ដឹងឧទ្ធរណ៍ ............ ១២
២. ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ............ ១៣
៣.អានុភាពនៃការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ............ ១៣
ក. ការបង្អាក់ការចូលជាស្ថាពរនៃសាលក្រម ............ ១៣
ខ. ការផ្ទេរការជំនុំជម្រះក្ដី ............ ១៣
គ. អវិភាគភាពនៃបណ្ដឹងឧទ្ធរណ៍ ............ ១៣
៤. ការជំនុំជម្រះរបស់តុលាការ (សាលាឧទ្ធរណ៍ តាមរយៈសភារដ្ឋប្បវេណី) ............ ១៤
៥. ការដកពាក្យបណ្ដឹង ............ ១៥
៦. ការវិនិច្ឆ័យ និងការចេញសាលដីកា ............ ១៥
៦.១ សាលដីកាលើកចោលបណ្ដឹងឧទ្ធរណ៍ (ផុតសិទ្ធិប្ដឹងឧទ្ធរណ៍) ............ ១៥
៦.២ សាលដីកាច្រានចោលបណ្ដឹងឧទ្ធរណ៍ (យល់ថាសាលក្រមត្រឹមត្រូវ) ............ ១៦
៦.៣ សាលាដីកាទទួលស្គាល់បណ្ដឹងឧទ្ធរណ៍ ............ ១៦
៧. វិសាលភាពនៃការលុបចោល និងការផ្លាស់ប្ដូរ ............ ១៦
៧.១ ការលុបចោល និងជំនុំជម្រះដោយខ្លួនឯង ............ ១៦
៧.២ ការលុបចោល និងការបញ្ជូនត្រឡប់ ............ ១៦
៧.៣ ការលុបចោល និងការផ្ទេររឿងក្ដី ............ ១៧
**កថាភាគទី ២ ៖ បណ្ដឹងសាទុក្ខ** ............ ១៧
១. អត្ថន័យនៃបណ្ដឹងសាទុក្ខ ............ ១៧
១.១ ប្រភេទនៃបណ្ដឹងសាទុក្ខ ............ ១៧
១.១.១ បណ្ដឹងសាទុក្ខទូទៅ ............ ១៧
១.១.២ បណ្ដឹងសាទុក្ខផ្ទោះ ............ ១៧
១.១.៣ បណ្ដឹងសាទុក្ខបន្ទាប់បន្សំ ............ ១៨

២. មូលហេតុប្តឹងសាទុក្ខ ........ ១៨
២.១ មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ........ ១៨
២.២ មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ ........ ១៨
៣. នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ និងការចេញសាលដីកា ........ ១៩
៣.១ ការជំនុំជម្រះបណ្តឹងសាទុក្ខ ........ ១៩
៣.១.១ ដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខ ........ ១៩
៣.១.២ ដីកាសម្រេចលើកចោលពាក្យបណ្តឹងសាទុក្ខ ........ ២០
៣.១.៣ សាលដីកាច្រានចោលបណ្តឹងសាទុក្ខ ........ ២១
៤. សាលដីកាទទួលស្គាល់នូវបណ្តឹងសាទុក្ខ ........ ២២
៤.១ ការបដិសេធចោល និងបញ្ជូនត្រឡប់ទៅតុលាការដើម ឬការបដិសេធចោល និងផ្ទេរសំណុំរឿងក្តី.. ២២
៤.២ ការបដិសេធ និងការវិនិច្ឆ័យដោយខ្លួនឯង ........ ២៣
**កថាភាគទី ៣ ៖ បណ្តឹងជំទាស់** ........ ២៤
១. អត្ថន័យនៃបណ្តឹងជំទាស់ ........ ២៤
២. មូលហេតុនៃបណ្តឹងជំទាស់ ........ ២៥
៣. របៀបបណ្តឹងជំទាស់ ........ ២៥
៣.១ ការធ្វើបណ្តឹងជំទាស់ ........ ២៥
៣.២ អំឡុងពេលសម្រាប់ប្តឹងជំទាស់ ........ ២៦
៤. នីតិវិធីនៃការជំនុំជម្រះទៅលើបណ្តឹងជំទាស់ ........ ២៦
៤.១ ភាគីនៃបណ្តឹងជំទាស់ ........ ២៦
៤.២ បណ្តឹងជំទាស់ និងការបង្អាក់នូវអានុភាពនៃដីកាសម្រេចដើម ........ ២៧
៤.៣ នីតិវិធីជំនុំជម្រះនៃបណ្តឹងជំទាស់ ........ ២៧
៥. ប្រភេទដីកាសម្រេចដែលអាចប្តឹងជំទាស់បាន ........ ២៨
៦. វិសាលភាពនៃបណ្តឹងជំទាស់ ........ ២៨
៦.១ ការប្តឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍ ........ ២៨
៦.២ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬការប្រគល់សិទ្ធិ...... ២៩

**ជំពូកទី ៣**

**ប្រភេទនៃបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ**

**កថាភាគទី ១ ៖ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ** ........ ៣១
១. បុគ្គលដែលអាចដាក់ពាក្យសុំតវ៉ា ........ ៣១

២. នីតិវិធីពាក់ព័ន្ធនឹងពាក្យសុំតវ៉ា ........ ៣១
៣. ការសម្រេចសេចក្ដីអំពីពាក្យសុំតវ៉ា ........ ៣២
៤. អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ........ ៣៣
**កថាភាគទី ២ ៖ ការលុបចោលដីកាសម្រេចរក្សាការពារ** ........ ៣៣
១. បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ........ ៣៣
២. មូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ ........ ៣៤
៣. ការសម្រេចសេចក្ដីអំពីពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ........ ៣៥
៤. អានុភាពនៃពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ........ ៣៦
**កថាភាគទី ៣ ៖ បណ្ដឹងជំទាស់** ........ ៣៦
១. បុគ្គលដែលអាចធ្វើបណ្ដឹងជំទាស់ ........ ៣៦
២. នីតិវិធីទាក់ទងនឹងបណ្ដឹងជំទាស់ ........ ៣៧
៣. ការសម្រេចលើបណ្ដឹងជំទាស់ ........ ៣៨
៤. អានុភាពនៃបណ្ដឹងជំទាស់ ........ ៣៨
**សេចក្ដីសន្និដ្ឋាន** ........ ៣៩
**អានុសាសន៍** ........ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| | | |
|---|---|---|
| - ឧបសម្ព័ន្ធទី ១ | ៖ | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។ |
| - ឧបសម្ព័ន្ធទី ២ | ៖ | ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន លេខៈ ៣៩៣ ត.រ/២០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។ |
| - ឧបសម្ព័ន្ធទី ៣ | ៖ | ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារលេខៈ៥៨១ ត.រ / -២០ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។ |
| - ឧបសម្ព័ន្ធទី ៤ | ៖ | ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ។ |
| - ឧបសម្ព័ន្ធទី ៥ | ៖ | ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារលេខៈ៦៧១ ត.រ/២០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។ |
| - ឧបសម្ព័ន្ធទី ៦ | ៖ | ពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩។ |
| - ឧបសម្ព័ន្ធទី ៧ | ៖ | ពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០។ |
| - ឧបសម្ព័ន្ធទី ៨ | ៖ | ដីកាសម្រេចលេខៈ ៣៦ក្រ III យ ដកស ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ។ |
| - ឧបសម្ព័ន្ធទី ៩ | ៖ | ដីកាសម្រេចលេខៈ ៣៥ក្រ III យ ដកស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ។ |
| - ឧបសម្ព័ន្ធទី ១០ | ៖ | ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៧ ការចាត់ចែងរក្សាការពារ។ |

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ក្រមនីតិវិធីរដ្ឋប្បវេណីបានធ្វើការបែងចែកចំណាត់ការនៃនីតិវិធីជា បី ប្រភេទធំៗរួមមានៈ នីតិវិធីបណ្តឹង នីតិវិធីអនុវត្តដោយបង្ខំ និងនីតិវិធីចាត់ចែងរក្សាការពារ ហើយដំណើរការនៃនីតិវិធីទាំងនេះ ត្រូវគោរពតាមគោលការណ៍សិទ្ធិក្នុងការធ្វើបណ្តឹង ដោយតែងតែរក្សាសិទ្ធិជូនបុគ្គលដែលពាក់ព័ន្ធទាំងឡាយ ក្នុងការធ្វើបណ្តឹងឧបាស្រ័យ ចំពោះសេចក្តីសម្រេច និងសកម្មភាពរបស់តុលាការ ក្នុងគោលដៅដើម្បីធានានូវសុក្រឹតភាពនៃដំណើរការនៃនីតិវិធីទាំងនោះ។ ដោយនៅក្នុងដំណើរការនៃកិច្ចនីតិវិធីចាត់ចែងរក្សាការពារ បានរក្សាផងដែរនូវសិទ្ធិក្នុងការធ្វើបណ្តឹងឧបាស្រ័យ ចំពោះសេចក្តីសម្រេច និងសកម្មភាពរបស់តុលាការ។ ទោះជាយ៉ាងណាក្តី ការធ្វើបណ្តឹងឧបាស្រ័យនេះមិនបានបើកចំហទូលំទូលាយរហូតនាំឱ្យមានការយឺតយ៉ាវដល់ដំណើរការនៃនីតិវិធីនោះទេ ដោយប្រធានបទសារណាមួយនេះ និងធ្វើការលើយកមកបកស្រាយ ប្រភេទនៃបណ្តឹងឧបាស្រ័យទូទៅនៃនីតិវិធីបណ្តឹងមកបកស្រាយលម្អិតជាមួយ និងបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ ដែលជាកម្មវត្ថុចម្បងដែលរួមមានៈ ការតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ ការលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ និងបណ្តឹងជំទាស់ មកបកស្រាយដោយផ្អែកលើទ្រឹស្តីគតិយុត្ត និងជួបប្រទះចំពោះការអនុវត្តជាក់ស្តែងដូចគ្នា។

ដើម្បីឱ្យមានភាពស៊ីជម្រៅ ចំពោះការប្រើប្រាស់សិទ្ធិរបស់ភាគីក្នុងការធ្វើបណ្តឹងឧបាស្រ័យទូទៅនៃនីតិវិធីបណ្តឹង និងសិទ្ធិរបស់ភាគីក្នុងការធ្វើបណ្តឹងឧបាស្រ័យនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ ដែលជាការប្តឹងប្រឆាំងទៅសេចក្តីសម្រេចក្នុងនីតិវិធីចាត់ចែងរក្សាការពារ ចំណាត់ការរបស់តុលាការ និងសេចក្តីសម្រេច និងរួមមានអានុភាពនៃបណ្តឹងឧបាស្រ័យនោះ ដែលជាកត្តាជួយជម្រុញឱ្យយើងខ្ញុំសម្រេចធ្វើការសិក្សាលម្អិត និងចងក្រងជាប្រធានបទសារណាពី **បណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ** នេះ នាឱកាសបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ដើម្បីអាចចងក្រងសារណាបញ្ចប់ការសិក្សានេះបាន យើងខ្ញុំបានសិក្សាទៅលើលិខិតបទដ្ឋានគតិយុត្តរួមមានៈ ក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី និងអត្ថបទរបាយការណ៍ស្រាវជ្រាវផ្សេងៗទៀតជាឯកសារបន្ទាប់បន្សំ។ ជាមួយគ្នានេះដែរ មានការណែនាំបន្ថែមពីលោកសាស្ត្រាចារ្យដឹកនាំសារណាទៅលើប្រភេទនៃបណ្តឹងឧបាស្រ័យនៃនីតិវិធីបណ្តឹង និងការធ្វើបណ្តឹងឧបាស្រ័យនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ ដែលមានលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ ពាក្យសុំលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ បណ្តឹងជំទាស់ និងនីតិវិធីនៃការប្តឹងជំទាស់ និងសេចក្តីសម្រេចនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ ផងដែរ។

ប្រធានបទសារណានេះ ផ្តោតជាសំខាន់ទៅលើការធ្វើបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ និងការពន្យល់ទៅប្រភេទនៃបណ្តឹងឧបាស្រ័យនៃនីតិវិធីបណ្តឹងតែប៉ុណ្ណោះ។ កម្មវត្ថុចម្បងនៃសារណានេះ គឺការសិក្សាទៅលើប្រភេទនៃបណ្តឹងឧបាស្រ័យនៃនីតិវិធីបណ្តឹង និងបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ និងនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងឧបាស្រ័យ ការសម្រេចសេចក្តី និងអានុភាពនៃបណ្តឹងទាំងនោះ។

ខ្លឹមសារនៃប្រធានបទសារណានេះ ត្រូវបានបែងចែកជា ៣ (បី) ជំពូកសំខាន់ៗ ដោយជំពូកទី ១ គឺ សិក្សាទៅលើសញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ និងនីតិវិធីចាត់ចែងរក្សាការពារ ជំពូកទី ២ គឺ ប្រភេទនៃបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ និងជំពូកទី ៣ គឺ ប្រភេទនៃបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ។

ជំពូកទី ១ ត្រូវបែងចែកជា ២ កថាភាគធំៗ រួមមានៈ កថាភាគទី ១ សញ្ញាណទូទៅបណ្តឹងឧបាស្រ័យ និងកថាភាគទី ២ សញ្ញាណនៃនីតិវិធីចាត់ចែងរក្សាការពារ។ ដោយកថាភាគទី ១ ត្រូវបានបែងចែកជាផ្នែកទី ១ អត្ថន័យនៃបណ្តឹងឧបាស្រ័យ ផ្នែកទី ២ គោលបំណងនៃបណ្តឹងឧបាស្រ័យ ផ្នែកទី ៣ ភាពខុសគ្នារវាងបណ្តឹងតវ៉ា (ទាមទារឱ្យមានការជំនុំជម្រះសារជាថ្មី និងបណ្តឹងឧបាស្រ័យ)។ រីឯ កថាភាគទី ២ វិញ ត្រូវបែងចែកជាផ្នែកទី ១ ទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ ផ្នែកទី ២ ប្រភេទនៃការចាត់ចែងរក្សាការពារ ផ្នែកទី ៣ លក្ខណៈទូទៅនៃការចាត់ចែងរក្សាការពារ ផ្នែកទី ៤ ដែនសមត្ថកិច្ចតុលាការ នៃនីតិវិធីចាត់ចែងរក្សាការពារ និងផ្នែកទី ៥ បណ្តឹងឧបាស្រ័យនៃនីតិវិធីចាត់ចែងរក្សាការពារ។

ជំពូកទី ២ ត្រូវបែងចែកជា ៣ កថាភាគធំៗ រួមមានៈ កថាភាគទី ១ បណ្តឹងឧទ្ធរណ៍ ដែលមានដូចជា របៀបធ្វើបណ្តឹងឧទ្ធរណ៍ ការពាក្យបណ្តឹងឧទ្ធរណ៍ អានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ការជំនុំជម្រះលើកបណ្តឹងឧទ្ធរណ៍ ការដកពាក្យបណ្តឹង ការវិនិច្ឆ័យ និងការចេញសាលដីកា វិសាលភាពនៃការលុបចោល និងការផ្លាស់ប្តូរ កថាភាគទី ២ បណ្តឹងសារទុក្ខ ដែលមានដូចជា អត្ថន័យនៃបណ្តឹងសារទុក្ខ មូលហេតុនៃបណ្តឹងសារទុក្ខ ការធ្វើបណ្តឹងសារទុក្ខ និងនីតិវិធីនៃការជំនុំជម្រះ និងកថាភាគទី ៣ បណ្តឹងជំទាស់ ដែលធ្វើការបកស្រាយទៅលើចំណុចដូចជា អត្ថន័យនៃបណ្តឹងជំទាស់ មូលហេតុនៃបណ្តឹងជំទាស់ ការធ្វើបណ្តឹងជំទាស់ និងនីតិវិធីនៃបណ្តឹងជំទាស់ រួមមានការជំនុំជម្រះ ដីកាសម្រេចលើបណ្តឹងជំទាស់ និងវិសាលភាពនៃបណ្តឹងជំទាស់។

ជំពូកទី ៣ ត្រូវបានបែងចែក ៣ កថាភាគធំៗរួមមាន កថាភាគទី ១ ការតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ កថាភាគទី ២ ការលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ និងកថាភាគទី ៣ បណ្តឹងជំទាស់។

ជាចុងក្រោយនៃសារណាបញ្ចប់ការសិក្សា គឺការធ្វើសេចក្តីសន្និដ្ឋាន មតិយោបល់ផ្ទាល់ខ្លួន និងសំណូមពរបន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ។

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ
# និងនីតិវិធីចាត់ចែងរក្សាការពារ

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ និង នីតិវិធី ចាត់ចែងរក្សាការពារ

## កថាភាគទី ១ ៖ សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ

មុននឹងធ្វើការសិក្សាអំពីប្រភេទបណ្តឹងនីមួយៗ នៃបណ្តឹងឧបាស្រ័យត្រូវស្វែងយល់អោយច្បាស់ជាមុនពីសញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ ហេតុដូច្នេះហើយគោលបំណង និងអត្ថន័យនៃបណ្តឹងឧបាស្រ័យនេះនឹងត្រូវបានធ្វើការបកស្រាយនៅខាងក្រោមជាបន្តបន្ទាប់។

### ផ្នែកទី ១ ៖ អត្ថន័យនៃបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងទៅកាន់តុលាការជាន់ខ្ពស់ ដែលទាមទារដោយភាគីទៅតុលាការអោយលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេចដែលចេញដោយតុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាប នៅមុនពេលសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាបបានចូលជាស្ថាពរ ដែលសេចក្តីសម្រេចនោះ ភាគីដែលមិនសុខចិត្តនិងសេចក្តីសម្រេចតុលាការនោះ ទៅកាន់តុលាការជាន់ខ្ពស់បានតាមរយៈបណ្តឹងឧបាស្រ័យ ដែលបណ្តឹងទាំងនោះរួមមាន ៖ បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ និងបណ្តឹងជំទាស់។

#### ១. ទស្សនៈក្នុងបណ្តឹងឧបាស្រ័យ

ចំពោះបណ្តឹងឧបាស្រ័យ គឺធ្វើឡើងដើម្បីលុបចោល ឬកែប្រែនូវសេចក្តីសម្រេចដែលភាគីណាមួយមិនពេញចិត្ត (សាលក្រម ឬសាលដីកា ឬដីកាសម្រេច) ដោយភាគីដែលមិនពេញចិត្តទៅនិងសេចក្តីសម្រេចនេះអាចធ្វើការទាមទារនៅក្នុងបណ្តឹងឧបាស្រ័យបាន។ ចំពោះសេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចដែលចេញដោយតុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាប ដែលគេហៅថា សាលាដំបូង។ មុនពេលដែលសេចក្តីសម្រេចនៃតុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាបនោះ មិនចូលជាស្ថាពរ មានន័យថានៅចន្លោះពេលនៃការចូលជាស្ថាពរនោះ គឺភាគីអាចប្រើប្រាស់សិទ្ធិក្នុងការធ្វើបណ្តឹងបាន តាមរយៈបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់។[1]

ក្រោមមូលដ្ឋានបែបនេះ អាចនិយាយបានថាបើសេចក្តីសម្រេចនោះបានចូលជាស្ថាពរ គឺភាគីមិនអាចធ្វើបណ្តឹងឧបាស្រ័យបាននោះទេ នេះមានន័យសរបញ្ជាក់បានថា មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់បាននោះទេ ប៉ុន្តែភាគីអាចធ្វើទៅបាន ដោយប្រើប្រាស់បណ្តឹងផ្សេងទៀត ក្រៅពីបណ្តឹងឧបាស្រ័យដែលមានបណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មីជាដើម។ ហើយចំពោះអានុភាពនៃបណ្តឹងឧបាស្រ័យ គឺត្រូវបានបង្អាក់នូវការចូលជាស្ថាពរ នៅសេចក្តីសម្រេចរបស់តុលាការនៃសេចក្តីសម្រេចនោះ គឺត្រូវត្រូវរងចាំនៅនីតិវិធីនៃបណ្តឹងឧបាស្រ័យត្រូវបានបញ្ចប់សិន។

[1] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩

**២. ការធ្វើបណ្តឹងឧបាស្រ័យ**

ការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ភាគីអាចធ្វើបណ្តឹងបានតែចំពោះសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាបដែលមិនទាន់បានចូលជាស្ថាពរនោះទេ ក៏ប៉ុន្តែចំពោះសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាបចូលជាស្ថាពរក៏ដោយ ក៏ភាគីនៅតែមានសិទ្ធិប្រើប្រាស់បណ្តឹងទៅតុលាការដដែលបាន ឧទាហរណ៍ បណ្តឹងទាស់ និងសាលក្រមកំបាំងមុខ ឬបណ្តឹងតវ៉ា។ ចំពោះសាលក្រម ឬសាលដីកាភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសារទុក្ខបាន ប៉ុន្តែដីកាសម្រេចរបស់តុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាប អាចធ្វើបណ្តឹងឧបាស្រ័យបាន លុះត្រាតែមានចែងនៅក្នុងច្បាប់ ថាដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ទើបភាគីមានសិទ្ធិក្នុងការធ្វើបណ្តឹងឧបាស្រ័យបាន។ កាលណាភាគីដែលបានធ្វើបណ្តឹងជំទាស់ម្តងរួចហើយលើដីកាសម្រេចដែលមានចែងក្នុងច្បាប់នេះ គឺភាគីនៅក្នុងបណ្តឹងឧបាស្រ័យនោះមិនអាចធ្វើបណ្តឹងជំទាស់ម្តងទៀតបានទេ ទៅលើដីកាសម្រេចចំពោះបណ្តឹងជំទាស់មុននោះឡើយ។[2]

ប្រសិនបើមានបណ្តឹងឧបាស្រ័យ ចំពោះសេចក្តីសម្រេចចុងក្រោយរបស់តុលាការជាន់ទាបជាគោលការណ៍សេចក្តីសម្រេចរបស់តុលាការនោះ នៅក្នុងដំណើរការរឿងក្តីរហូតដល់ចេញសាលក្រមចុងក្រោយត្រូវទទួលនូវ ការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ចំពោះសេចក្តីចុងក្រោយនោះទេ។ ដើម្បីឱ្យមានស្ថេរភាពនៅក្នុងដំណើរការនីតិវិធី ប្រសិនបើតុលាការដែលទទួលបណ្តឹងឧបាស្រ័យចំពោះចំណុចបន្ទាប់ដែលទាក់ទងនិងដំណើរការនៃនីតិវិធី ដោយឡែកចំពោះសាលក្រមចុងក្រោយ ដើម្បីដោះស្រាយចំណុចបន្ទាប់បន្សំឱ្យបានចូលជាស្ថាពរឱ្យបានឆាប់រហ័សហើយមានភាពសមរម្យ។ ការទទួលស្គាល់បណ្តឹងឧបាស្រ័យនេះ គឺដើម្បីបន្ថយនូវបណ្តឹងឧបាស្រ័យនេះ ចំពោះសាលក្រមចុងក្រោយដោយសារតែមានបញ្ហាបន្ទាប់បន្សំប៉ុណ្ណោះ។

**ផ្នែកទី ២ ៖ គោលបំណងនៃបណ្តឹងឧបាស្រ័យ**

នៅក្នុងផ្នែកនេះ នឹងធ្វើការបកស្រាយនូវគោលបំណង នៃបណ្តឹងឧបាស្រ័យនេះតាមរយៈទស្សនៈលើបណ្តឹងឧបាស្រ័យ និងការប្រើប្រាស់បណ្តឹងឧបាស្រ័យ។

**១.ការសង្គ្រោះសិទ្ធិរបស់ភាគី**

ការវិនិច្ឆ័យរបស់តុលាការ គឺធ្វើឡើងដោយមនុស្ស ឬការភ័ន្តច្រឡំកើតមានដោយជៀសមិនរួច ពីព្រោះការសេចក្តីសម្រេចរបស់តុលាការពេលខ្លះមិនប្រាកដថាត្រឹមត្រូវទាំងអស់នោះទេ ដោយសារតែតុលាការបានធ្វើការពិនិត្យ ភស្តុតាង ឬ ឯកសារផ្សេងៗណាមួយអាចមិនគ្រប់ជ្រុងជ្រោយ ដែលជាហេតុធ្វើឱ្យសេចក្តីសម្រេចរបស់តុលាការដែលមានភាពខ្វះចន្លោះនោះ ប្រសិនបើទុកឱ្យស្ថានភាពបែបនេះនៅតែបន្តមាននោះ ដូច្នេះកំហុសនោះ គឺមិនត្រឹមតែបំពានសិទ្ធិរបស់ភាគីតែប៉ុណ្ណោះទេ គឺធ្វើឱ្យបាត់បង់ជំនឿទុកចិត្តចំពោះប្រព័ន្ធតុលាការតែម្តង។

ដូច្នេះហើយ ចាំបាច់ត្រូវតែមាននូវប្រព័ន្ធមួយដែលតាមរយៈនោះ តុលាការជាន់ខ្ពស់អាចនឹងពិនិត្យមើលនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមបាន តាមពាក្យសុំរបស់ភាគីណាមួយដែលមិនសុខចិត្តចំពោះ

[2] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣

សេចក្តីសម្រេចនោះ។ កាលណាភាគីណាម្ខាងមិនសុខចិត្ត ឬក៏មិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាប ភាគីអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដើម្បីទាមទារអ្វីដែលខ្លួនចង់បានដូច្នេះហើយទើបច្បាប់អនុញ្ញាតឱ្យភាគីមានសិទ្ធិធ្វើបណ្តឹងទៅកាន់តុលាការជាន់ខ្ពស់ដែលហៅថា ការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ បើសិនជាភាគីមិនមានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យទេនោះ ភាគីត្រូវតែទទួលបាននូវសេចក្តីសម្រេចនោះតែម្តងដោយមិនអស់ចិត្តនឹងសេចក្តីសម្រេចនោះ ដោយបាត់បង់ផលប្រយោជន៍ណាមួយដែលខ្លួនមិនទាន់ចង់បាន។

### ២. ការចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ ឬផ្តល់យុត្តិធម៌ដល់ភាគី

តាមរយៈការសម្រេចសេចក្តីរបស់តុលាការជាន់ទាប ដែលមានភាពមិនត្រឹមត្រូវនោះតុលាការជាន់ខ្ពស់អាចធ្វើការកែប្រែ ឬលុបចោលនូវសេចក្តីសម្រេចនោះបានដែលគេហៅថា របបនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ កែតម្រូវនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយរងចាំពាក្យសុំឧបាស្រ័យ ដែលអាចហៅផងដែរដែលម្យ៉ាងទៀតជារបបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិរបស់ភាគីឱ្យរួចផុសពីឥទ្ធិពលនៃការវិនិច្ឆ័យខុស ឬកំហុសក្នុងនីតិវិធីក្នុងការជំនុំជម្រះ។

ម្យ៉ាងវិញទៀតតាមរយៈការអនុញ្ញាតឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានរឿងក្តីជាច្រើនដែលត្រូវពិនិត្យ និងធ្វើការជំនុំជម្រះសារឡើងវិញដោយតុលាការជាន់ខ្ពស់ចុងក្រោយបំផុត គឺត្រូវជំនុំជម្រះដោយតុលាការជាន់ខ្ពស់ ដែលមានតែមួយចុងក្រោយគេគឺ តុលាការកំពូល។

## ផ្នែកទី ៣ ៖ ភាពខុសគ្នារវាងបណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី និងបណ្តឹងឧបាស្រ័យ

### ១. បណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី

បណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី គឺជាមធ្យោបាយឧបាស្រ័យមិនប្រក្រតីមួយដែលភាគីប្តឹងទាមទារឱ្យតុលាការដែលចេញសាលក្រម ឬសាលដីកានោះ និងឱ្យជំនុំជម្រះអំពីរឿងក្តីសារជាថ្មី ដោយយកមូលហេតុថានីតិវិធីនៃបណ្តឹងនោះមានវិការៈធ្ងន់ធ្ងរ ឬឯកសារដែលជាមូលដ្ឋាននៃការសេចក្តីសម្រេចវិនិច្ឆ័យនោះមានការខ្វះខាតច្រើនមិនប្រក្រតី។ ម៉្យាងវិញទៀត ភាគីអាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះដីកាសម្រេចចូលជាស្ថាពរហើយ។ ក្នុងចំណោមដីកាសម្រេចដែលបានធ្វើឡើងជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាចុងក្រោយហើយបើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្នុងដីកាសម្រេចនោះភាគីអាចធ្វើការប្តឹងទាមទារឱ្យមានការជំនុំជម្រះសាជាថ្មីដែលខុសពីបណ្តឹងឧបាស្រ័យ ដោយសមត្ថកិច្ចឱ្យជំនុំជម្រះសាជាថ្មី គឺជាសមត្ថកិច្ចរបស់តុលាការកំពូល។ ការប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវតែមានមូលហេតុ ដែលមានចែងក្នុងមាត្រា ៣០៧ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ២. បណ្តឹងឧបាស្រ័យ

ចំពោះបណ្តឹងឧបាស្រ័យវិញ គឺភាគីមានសិទ្ធិប្តឹងទៅតុលាការជាន់ខ្ពស់បាន ប្រសិនបើគិតថាខ្លួនបានបាត់បង់ផលប្រយោជន៍។ ប៉ុន្តែការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ លុះត្រាតែសេចក្តីសម្រេចរបស់តុលាការ

អាចជាសាលក្រម ឬដីកាសម្រេចដែលមិនទាន់ចូលជាស្ថាពរ ក៏អាចប្តឹងបានដែរ ដើម្បីលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេចដើម។

## កថាភាគទី ២ ៖ សញ្ញាណនៃនីតិវិធីចាត់ចែងរក្សាការពារ

### ផ្នែកទី ១ ៖ បទដ្ឋានគតិយុត្តនៃការចាត់ចែងរក្សាការពារ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើក្នុង ឆ្នាំ ២០០៦ គន្ថីទី៧ បានចែងនូវបទប្បញ្ញត្តិលម្អិតស្ដីពីការ ចាត់ចែងរក្សាការពារ ដោយឈរលើគោលគំនិតនៃភាពច្បាស់លាស់នៃនីតិវិធី ព្រមទាំងខ្លឹមសារនៃការចាត់ចែងរក្សាការពារ ជាការអនុវត្តដ៏សមរម្យមួយដែលត្រូវយកបញ្ញត្តិ នៃក្រមនីតិវិធីរដ្ឋប្បវេណីទៅអនុវត្ត។ ប៉ុន្តែនីតិវិធីការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដ៏ស្មុគស្មាញដែលរួមបញ្ចូលទាំងនីតិវិធីនៃការសម្រេចសេចក្តីផងនិងនីតិវិធីការអនុវត្តចាស់(វិធានការបណ្តោះអាសន្ន) នៃសារាចរលេខ ០៤ សរច ៨៤ ឆ្នាំ ១៩៨៤ ចេញដោយក្រសួងយុត្តិធម៌។

#### ១. គោលបំណងនៃការចាត់ចែងរក្សាការពារ

នីតិវិធីចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងថែរក្សាការពារ និង ថែរក្សាស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចរបស់រដ្ឋ ដើម្បីរក្សានូវគោលបំណងរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ នៅពេលដែលមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។[3] មិនត្រឹមតែជាច្បាប់ទម្រង់ប៉ុណ្ណោះទេ សូម្បីតែច្បាប់សារធាតុ ក៏បានជួយធ្វើការអន្តរាគមន៍ផងដែរក្នុងការការពារសិទ្ធិនិងផលប្រយោជន៍របស់ម្ចាស់បំណុល ក្នុងករណីដែលកូនបំណុលចង់យកទ្រព្យសម្បត្តិដែលមាននោះ គេចវេសអំពីការអនុវត្តដោយបង្ខំដោយមានការឃុបឃិតគ្នាជាមួយ និងតតិយជនក៏ត្រូវបានចាត់ទុកជាមោឃៈផងដែរ។

ផ្ទុយទៅវិញប្រសិនបើតតិយជននោះជាសុចរិត ម្ចាស់បំណុលក៏មិនអាចអះអាងចំពោះតតិយជននោះបានដែរ។[4] ត្រង់ចំណុចនេះហើយដែលធ្វើឱ្យម្ចាស់បំណុលជ្រើសរើសយកនីតិវិធីចាត់ចែងរក្សាការពារ ដែលជាមធ្យោបាយដែលល្អមួយដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន។នៅពេលដែលមានបណ្តឹងអង្គសេចក្តីដែលត្រូវបានចាត់ការនោះ គឺត្រូវចំណាយពេលវេលាមួយវែងដែលមិនអាចកំណត់បាន ដូច្នេះនៅអំឡុងពេលនៃនីតិវិធីអង្គសេចក្តីនេះពេលខ្លះម្ចាស់បំណុលអាចបាត់បង់ផលប្រយោជន៍ ដោយសារតែចេតនាទុច្ចរិតរបស់កូនបំណុលដែលលាក់ទុកទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈការផ្ទេរ ការដោះដូរ ការទិញលក់ ការបញ្ចាំ ប្រទានកម្មជាដើម។ ហេតុនេះហើយនាំអោយម្ចាស់បំណុលមានការលំបាកក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន នៅពេលដែលម្ចាស់

[3] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣០

[4] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣៣

បំណុលបានឈ្នះក្តីដោយសារតែមើលឃើញបែបនេះហើយទើបបានជាក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦ មានគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលរហូតដល់នីតិវិធីបណ្តឹងដល់ទីបញ្ចប់។ ហើយមិនថាម្ចាស់បំណុលនោះជាអ្នកណា មកពីណាក៏ដោយ ក៏ដោយអោយតែម្ចាស់មានសមត្ថភាពគ្រប់គ្រាន់ស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ទោះបីជាម្ចាស់បំណុលគ្មានសមត្ថភាពស្របតាមច្បាប់នៃប្រទេសរបស់ខ្លួនក៏ដោយ ក៏ម្ចាស់បំណុលអាចដាក់ពាក្យសុំអោយចេញការចាត់ចែងរក្សាការពារមកតុលាការដើម្បីធ្វើការចាត់ចែងរក្សាការពារបានដែរ។[5]

ការចាត់ចែងរក្សាការពារ នេះផងដែរបានចែកជា ពីរ ផ្នែកសំខាន់ៗគឺ ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន។ ការចាត់ចែងជាបណ្តោះអាសន្នចែកជាការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។[6] ការរឹបអូសជាបណ្តោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារឲ្យសងជាប្រាក់។ ចំណែកឯការចាត់ចែងជាបណ្តោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិត្រូវបានរក្សាការពារ គឺជាសិទ្ធិក្រៅពីសិទ្ធិទាមទាអោយសងជាប្រាក់។ តែទោះជាយ៉ាងណាក៏ដោយបើនិយាយពីមុខងារ ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដែលមានលក្ខណៈរួមត្រង់ថាមានវិធានការទាំងពីរនេះគឺជាការចាត់ចែងដែលមានគោលបំណងរក្សាការពារនូវស្ថានភាពបច្ចុប្បន្ន សម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត។ ដោយឡែកការចាត់ចែងជាបណ្តោះអាសន្ន រហូតដល់ពេលកំណត់ទំនាក់ទំនងនៃសិទ្ធិជាស្ថាពរក្នុងគោលបំណងដកចេញ និង ទប់ស្កាត់នូវគ្រោះថ្នាក់ និង ការលំបាកនាពេលបច្ចុប្បន្ន ដែលបង្កឡើងដោយភាពយឺតយ៉ាវនៃការកំណត់ទម្រង់នៃសិទ្ធិនោះជាស្ថាពរ។

### ២. វិសាលភាពនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារមានភាពធំទូលាយ ការអនុវត្តការចាត់ចែងរក្សាការពារធ្វើឡើងទៅបាន លុះត្រាតែ មានដីកាសម្រេចអំពីការចាត់ចែងដែលចេញដោយតុលាការមានសមត្ថកិច្ច។[7] ចំពោះការអនុវត្តបានគ្របដណ្តប់លើការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន និងបានរួមបញ្ចូលផងដែរចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ វិសាលភាពនៃការអនុវត្តមានលក្ខណៈធំទូលាយ ផ្អែកលើគោលការណ៍ការពារនូវភាពស្របច្បាប់របស់ដើមបណ្តឹង។

### ៣.មូលហេតុនៃការស្នើសុំរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ក្នុងការប្រើសិទ្ធិទាមទារបំណុល ដោយយកលិខិតអនុវត្តពីតុលាការទៅ អនុវត្តដោយបង្ខំលើកូនបំណុលរបស់ខ្លួន។

[5] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣៤

[6] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣១

[7] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៤០

ទោះបី ជាការចាប់ផ្តើមអនុវត្តដោយបង្ខំតម្រូវឱ្យបំពេញនូវ ល័ក្ខខ័ណ្ឌដូចជាអត្ថិភាពនៃលិខិតអនុវត្ត និង ការមកដល់នៃពេលកំណត់សងក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុនដោយមិនឱ្យមានការប្រែប្រួលផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែងក្នុងគោលដៅធានាដល់ការ អនុវត្តដោយបង្ខំនាពេលអនាគត។ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតបញ្ជាក់កាតព្វកិច្ច ដូចជាសាលក្រមស្ថាពរជាដើម ហេតុនេះហើយដើម្បីឱ្យបានសាលក្រមនេះ ត្រូវដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ថែមទាំងត្រូវការពេលវេលាច្រើន។ ក៏ប៉ុន្តែមុនពេលទទួលសាលក្រមនេះ កូនបំណុលនៃការអនុវត្តអាច លក់ ឬ ផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនដែលជាហេតុមិនអាចធ្វើ ឬ ធ្វើឱ្យមានការលំបាកដល់ធ្វើការអនុវត្តដោយបង្ខំ នៅពេលក្រោយបាន ឬ មួយក៏ភាគីណាមួយអាចទទួលការខូចខាតធ្ងន់ធ្ងរ ឬទទួលគ្រោះថ្នាក់ដល់ឋានៈ របស់ខ្លួន ដោយសារវិវាទពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិរវាងភាគីទាំងសងខាង។ ក្នុងករណីនេះបុគ្គល ដែលចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារឱ្យមានការចាត់ចែងរក្សាការពារបាន។

## ផ្នែកទី ២ ៖ ប្រភេទនៃការចាត់ចែងរក្សាការពារក្នុងសំណុំរឿងរដ្ឋប្បវេណី

ប្រភេទនៃការចាត់ចែងរក្សាការពារ អាចត្រូវបានដាក់ឲ្យអនុវត្តបានជាច្រើនសណ្ឋានអាស្រ័យទៅតាមនៃកាលៈទេសៈនៃសំណុំរឿង។ ដែលមានគោលបំណងជៀសវាងផលលំបាក និងភាពមិនអាចអនុវត្តបាននូវនីតិវិធីអនុវត្តដោយបង្ខំនាពេលអនាគត។ ដែលក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវខ្លឹមសារខាងក្រោមដែលអាចធ្វើការចាត់ចែងរក្សាការពារបាន។

### ១. ការរឹបអូសបណ្តោះអាសន្ន

ការរឹបអូសបណ្តោះអាសន្ន ជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីរក្សាចំពោះការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់។ ការរឹបអូសបណ្តោះអាសន្ន ដែលមានគោលបំណងដើម្បីទប់ស្កាត់ដល់កូនបំណុលក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន និងជានាបាននូវទ្រព្យសម្បត្តិសម្រាប់ការទទួលខុសត្រូវរបស់កូនបំណុលសម្រាប់ការអនុវត្តដោយបង្ខំ នៅពេលអនាគត។ ក្នុងសំណុំរឿងរដ្ឋប្បវេណីកម្មវត្ថុនៃការរឹបអូសបណ្តោះអាសន្នត្រូវបានគេបែងចែកជាច្រើនប្រភេទក្នុងនោះរួមមាន ចលនវត្ថុ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗ អចលនវត្ថុ នាវា។

ចលនវត្ថុ៖ ការរឹបអូសជាបណ្តោះអាសន្ននៃចលនវត្ថុ ត្រូវធ្វើតាមការអនុវត្តដោយអាជ្ញាសាលា ដែលដូចគ្នាទៅនឹងការរឹបអូសអចលនវត្ថុដែរ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាសាច់ប្រាក់ អាជ្ញាសាលាមិនត្រូវបញ្ជូនទៅម្ចាស់បំណុលផ្ទាល់ទេ ត្រូវបញ្ជូនទៅតុលាការ។ អាជ្ញាសាលាដែលធ្វើការរឹបអូសនូវចលនវត្ថុដែលបានចុះបញ្ជី ដូចជា រថយន្ត ទោចក្រយានយន្ត ត្រូវផ្ទុកផ្តាក់ឱ្យសរសេរនូវរបាយការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជី ហើយការរឹបអូសនោះនឹងមានអានុភាព។

អចលនវត្ថុ៖ សំដៅទៅលើ អគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។ ចំពោះការរឹបអូសជាបណ្តោះអាសន្ននៃអចលនវត្ថុ ត្រូវធ្វើឡើងដោយអាជ្ញាសាលា។ ការរឹបអូសបណ្តោះអាសន្នចំពោះ

អចលនវត្ថុ មានគោលបំណងរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណង ឲ្យសងជាប្រាក់ដែលជាត្រូវការពារ។

សិទ្ធិលើបំណុលៈ ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ត្រូវធ្វើឡើងដោយតុលាការអនុវត្តរក្សាការពារ។ ក្នុងករណីដែលកូនបំណុលទី ៣ ដែលបានទទួលការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល បានផ្ញើរសិទ្ធិលើបំណុលនោះ ឬមួយផ្នែកនៃចំនួនប្រាក់ដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ក្នុងចំណោមប្រាក់ផ្ញើរនោះ ត្រូវចាត់ទុកថាជាការផ្ញើរប្រាក់រំដោះ តែចំពោះភាគដែលលើសចំនួនទឹកប្រាក់ដែលស្មើនឹងរំដោះពីការរឹបអូសជាបណ្តោះអាសន្ននោះ ការផ្ញើរនៅតុលាការបង្កើតឱ្យមានអានុភាពនៃការទូទាត់ទៅកូនបំណុលនៃការអនុវត្ត។

នាវាៈ នាវាសំដៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី ២០ តោន ទោះជាមិនបានចុះបញ្ជី ឬបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក្តី។ ការរឹបអូសបណ្តោះអាសន្នចំពោះនាវា គឺអាជ្ញាសាលាធ្វើការដកហូតលិខិតបញ្ជាក់សញ្ជាតិនាវានោះ។ មិនខុសគ្នាពីការរឹបអូសជាបណ្តោះអាសន្ននៃអចលនវត្ថុ និងចលនវត្ថុប៉ុន្មានដែរត្រង់ចំណុចផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះប្រើអំពីការរឹបអូស។ការរឹបអូសបណ្តោះអាសន្នចំពោះនាវា ត្រូវអនុវត្តដោយតុលាការអនុវត្តរក្សាការពា។

### ២. ការចាត់ចែងរក្សាការពារបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថាម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការកែប្រែស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។

### ក. ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរកាន់កាប់

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរកាន់កាប់ មានគោលបំណងហាមឃាត់កូនបំណុលក្នុងការផ្ទេរនូវការកាន់កាប់វត្ថុដែលបានកំណត់ជាក់លាក់ទៅឱ្យតតិយជន ហើយកំណត់អំពីភាគីម្ខាងទៀតនៃកាទាម ទារឱ្យប្រគល់។ ការចាត់ចែងជាបណ្តោះអាសន្នក្នុងការទប់ស្កាត់ការផ្ទេរការកាន់កាប់នេះ បានរក្សាការពារលើសិទ្ធិទាមទារប្រគល់វត្ថុដែលបានកំណត់ជាក់លាក់។

### ខ.ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងមានគោលបំណងហាមឃាត់កូនបំណុលកុំឱ្យមានការចាត់ចែង ធ្វើការផ្ទេរកម្មសិទ្ធិ ដាក់បន្ទុក ដកបន្ទុក លើវត្ថុដែលបានកំណត់ជាក់លាក់ ហើយកំណត់ភាគីម្ខាងទៀតនៃការទាមទារ។ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង បានរក្សាការពារនូវសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកចំពោះកម្មវត្ថុដែលបានកំណត់ជាក់លាក់។

### ៣ .ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន

ការចាត់ចែងរក្សាការពារចំពោះការកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន ជាយន្តការម្យ៉ាងដែលបានធានាដល់ការបាត់បង់ និងខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតមានឡើងចំពោះម្ចាស់បំណុល។ ជា

យន្តការដែលកំណត់នូវឋានៈជាបណ្តោះអាសន្ននៃបុគ្គល ឬភាគីដើម្បីកំណត់នូវសិទ្ធិជាបណ្តោះអាសន្នរបស់អ្នកដាក់ពាក្យសុំក្នុងការបន្តនីតិវិធីបណ្តឹងអង្គសេចក្តី និងមានភាពចាំបាច់សម្រាប់កំណត់សិទ្ធិជាបណ្តោះអាសន្ន នៃសិទ្ធិបុគ្គលណាមួយដែលបានដាក់ពាក្យសុំ។ ការកំណត់ឋានៈបុគ្គលពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារ ជាឋានៈរូបវន្តបុគ្គល នីតិបុគ្គលដែលតុលាការបានចេញដីកាសម្រេចរក្សាការពារ ដែលបានកំណត់ថាបុគ្គលនោះមានសិទ្ធិ ក៏ដូចជាកាតព្វកិច្ចបែបណាក្នុងការអនុវត្តជាបណ្តោះអាសន្ន។

ករណីមានបណ្តឹងកំពុងបន្តដំណើរការនីតិវិធី វាមានការលំបាកក្នុងការកំណត់នូវអត្ថិភាព និងនត្ថិភាពនៃគូភាគីដែលចាំបាច់កំណត់នូវឋានៈបុគ្គលនោះជាបណ្តោះអាសន្ន ដើម្បីធានាដល់ស្ថេរភាព និងនិរន្តរភាពនៃដំណើរការនីតិវិធីទាំងមូល។ ជាពិសេស ការចាត់ចែងរក្សាការពារក្នុងការកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន មានលក្ខណៈខុសគ្នាពីការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយមិនមែនមានគោលបំណងធ្វើការរក្សាការពារសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគតនោះទេ។

### ផ្នែកទី ៣ ៖ លក្ខណៈទូទៅនៃការចាត់ចែងរក្សាការពារ

#### ១. លក្ខណៈបណ្តោះអាសន្ន

នៅក្នុងបណ្តឹងអង្គសេចក្តី ដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលទៅលើសេចក្តីសម្រេច ដោយសាលក្រមឬ សាលដីកាឡើយ។ ដីកាសម្រេចចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដែលមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ។ សិទ្ធិលើបំណុល ឬសិទ្ធិទាមទារផ្សេងៗទៀត នៃបណ្តឹងអង្គសេចក្តីមិនត្រូវបានបញ្ជាក់ទេនោះថាមានអត្ថិភាព និងនត្ថិភាពនៅឡើយ។

#### ២.លក្ខណៈបន្ទាន់បង្ខំ

លក្ខណៈបន្ទាន់នៃដីកាសម្រេចរក្សាការពារ ធ្វើឡើងដើម្បីការពារផលប្រយោជន៍ស្របច្បាប់ និងបង្ការកុំឱ្យ មានការខូចខាតនូវកម្មវត្ថុនៃវិវាទជាដើម។ ហេតុនេះនីតិវិធីនៃការចេញដីកាសម្រេចរក្សាការពារ មានលក្ខណៈបន្ទាន់និងប្រញាប់។ ដើម្បីបំពេញនូវលក្ខណៈបន្ទាន់បង្ខំនេះ ចៅក្រមអាចប្រើប្រាស់នីតិវិធីណាមួយក៏បានក្នុងចំណោមការទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរភាគីនៃបណ្តឹងតែម្តង ដែលជាឆន្ទសិទ្ធិសម្រេចរបស់លោកចៅក្រមដែលគិតថា ជានីតិវិធីដែលមិនប្រើប្រាស់ពេលវេលាយូរ។

#### ៣. លក្ខណៈបន្ទាប់បន្សំ

នីតិវិធីចាត់ចែងរក្សាការពារ អាចប្រើប្រាស់ជំនួសនីតិវិធីអនុវត្តដោយបង្ខំបានក្នុងគោលបំណងការធានាដល់សិទ្ធិរបស់ម្ចាស់បំណុល។ ដូចដែលបានរៀបរាប់ក្នុងចំណុចនៃលក្ខណៈបណ្តោះអាសន្ននៃដីកាសម្រេចចាត់ចែងរក្សាការពារជានីតិវិធីមួយដែលបង្កើតឡើងជាបណ្តោះអាសន្ន ដូចច្នេះវាពុំមានឥទ្ធិពលទៅលើបណ្តឹងអង្គសេចក្តីទេហើយការកំណត់សមត្ថកិច្ចរបស់តុលាការវាផ្អែកលើបណ្តឹងអង្គសេចក្តីប៉ុណ្ណោះ ហេតុដូចនេះ នីតិវិធីចាត់ចែងរក្សាការពារជាលក្ខណៈបន្ទាប់បន្សំនៃនីតិវិធីបណ្តឹង។

**៤. លក្ខណៈសម្ងាត់**

ដើម្បីបង្ការក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល នៅក្នុងករណីម្ចាស់បំណុលដាក់ពាក្យសុំចាត់ចែងរក្សាការពារលើចលនវត្ថុ ឬអចលនវត្ថុទាំងនោះ នីតិវិធីនៃការចាត់ចែងរក្សាការពារត្រូវតែរក្សាការសម្ងាត់ជូនម្ចាស់បំណុល។ ម្យ៉ាងវិញទៀត ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងរក្សាការពារពុំចាំបាច់មានការបញ្ជូនទៅកូនបំណុលឡើយ។ខុសពីនីតិវិធីនៃបណ្ដឹងអង្គសេចក្ដី ដែលតម្រូវឱ្យមានការបញ្ជូនដីកានានាដល់កូនបំណុលដើម្បីទទួល និងដឹងអំពីព័ត៌មានផ្សេងៗ នេះសបញ្ជាក់ឱ្យឃើញផងដែលអំពីលក្ខណៈសម្ងាត់របស់ដីកាសម្រេចរក្សាការពារ។

## ផ្នែកទី ៤ ៖ ដែនសមត្ថកិច្ចនៃនីតិវិធីចាត់ចែងរក្សាការពារ ដែនសមត្ថកិច្ចតុលាការ

នីតិវិធីនៃការចាត់ចែងរក្សាការពារ មានចរិតលក្ខណៈជានីតិវិធីដែលបំពេញបន្ថែមលើការអនុវត្តដោយបង្ខំ ដូចនេះរឿងក្ដីនៃនីតិវិធីចាត់ចែងរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចទៅលើបណ្ដឹងអង្គសេចក្ដី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការចាត់ចែងនោះស្ថិតនៅ។ មិនតែប៉ុណ្ណោះ បណ្ដឹងរដ្ឋប្បវេណីភាគីគឺជាម្ចាស់បណ្ដឹងផ្ទាល់ ដូចនេះការកំណត់ដែនសមត្ថកិច្ចតុលាការជារឿងសំខាន់ ដោយហេតុថានៅពេលដាក់ពាក្យសុំទៅតុលាការ កាលណាពាក្យសុំខុសពីសមត្ថកិច្ចរបស់តុលាការ នោះពាក្យសុំនោះនឹងត្រូវបានលើកចោលដោយតុលាការនោះ។ នៅក្នុងនីតិវិធីនៃការចាត់ចែងបណ្ដឹងរដ្ឋប្បវេណីមានគោលបំណងសុំឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ ស្ថាប័នមានសមត្ថិកិច្ចលើការចាត់ចែងរក្សាការពាររួមមាន៖ អាជ្ញាសាលានៃសាលាដំបូងរាជធានី/ខេត្ត សាលាឧទ្ធរណ៍ តុលាការកំពូល តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដីសាលាដំបូងរាជធានី/ខេត្ត ដែលមានសមត្ថកិច្ចលើវត្ថុនៃកម្មវត្ថុ។

## ផ្នែកទី ៥ ៖ បណ្ដឹងឧបាស្រ័យនៃនីតិវិធីចាត់ចែងរក្សាការពារ

ចំពោះនៅក្នុងនីតិវិធីធំៗ នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ សុទ្ធតែមានការពារសិទ្ធិនៅក្នុងការពារផលប្រយោជន៍របស់ខ្លួន។ ដោយឡែកនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារនេះផងដែរ បានទុកសិទ្ធិសម្រាប់ភាគីដែលពាក់ព័ន្ធដែលអាចជាម្ចាស់បំណុល ឬ កូនបំណុល ឬបុគ្គលផ្សេងៗដែលមានទំនាក់ទំនងផលប្រយោជន៍នៃសំណុំរឿងចាត់ចែងរក្សាការពារមានសម្រាប់ការធ្វើបណ្ដឹងទៅនិងការសម្រេចសេចក្ដីរបស់តុលាការនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ។

ដែលមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីសិទ្ធិក្នុងធ្វើការធ្វើបណ្ដឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារទៅលើដីកាសម្រេចផ្សេងដែលចេញដោយតុលាការ ដោយបណ្ដឹងដូចជា៖ ការតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ ការលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ និងបណ្ដឹងជំទាស់។

# ជំពូកទី ២
# ប្រភេទនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

# ជំពូកទី ២
# ប្រភេទនៃបណ្តឹងឧបាស្រ័យ និងនីតិវិធីចាត់ចែងរក្សាការពារ
# ប្រភេទបណ្តឹងឧបាស្រ័យទូទៅ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងប្តឹងទៅតុលាការជាន់ខ្ពស់ បណ្តឹងឧបាស្រ័យនេះចែកចេញជា បីប្រភេទ គឺបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងទំទាស់។ចំពោះបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ គឺជាប្រភេទបណ្តឹងដែលប្តឹងឧបាស្រ័យ ឬភាគីបាត់បង់ផលប្រយោជន៍ប្តឹងមិនសុខចិត្តចំពោះសាលក្រម ឬ សាលដីកា។ ដើម្បីដាក់ពាក្យបណ្តឹងឧបាស្រ័យទាំងនេះបានគួរគប្បីសរសេរឲ្យបានត្រឹមត្រូវដែលច្បាប់បានបញ្ញត្តិទុកតាមប្រភេទនីមួយៗនៃបណ្តឹងឧបាស្រ័យនោះ។

## កថាភាគទី ១ ៖ បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូងនៅក្នុងគោលបំណងឲ្យតុលាជាន់ខ្ពស់ធ្វើការ លុបចោល ឬ ផ្លាស់ប្តូរសាលក្រមចុងក្រោយ។ ការជំនុំជម្រះនៅសាលាឧទ្ធរណ៍ហៅថា **ការជំនុំជម្រះលើកទី ២** ប៉ុន្តែក្នុងករណីតាមបញ្ញតិពិសេសមួយចំនួន ដូចជាសេចក្តីសម្រេចរបស់គណៈមេធាវីជាអាទិ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ ជាតុលាការនៃការជំនុំជម្រះលើកទី១។ ចំពោះការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវបានហៅថា តុលាការនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍។ ដោយឡែកបណ្តឹងឧទ្ធរណ៍អាចធ្វើឡើងចំពោះតែសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ ចំណែកសាលក្រមរបៀប មិនអាចប្តឹងឯករាជ្យដោយឯកឯងបានឡើយ។

### ១. របៀបធ្វើបណ្តឹងឧទ្ធរណ៍

ដើម្បីប្តឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដើម គឺតុលាការនៃការជំនុះជម្រះលើកទី១ ឬ សាលាដំបូង ។ចំពោះពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់អំពី ១.អត្តសញ្ញាណរបស់ភាគី ២.សេចក្តីដែលប្តឹងចំពោះសាលក្រមនោះ ៣.សញ្ញាណនៃសាលក្រមជំនុំជម្រះលើកទី១ និង ៤.មូលហេតុនៃការទាមទារឲ្យលុបចោល ឬផ្លាស់ប្តូរនូវសាលក្រម។

ឧទាហរណ៍ សាលាដំបូងបានចេញសាលក្រមឲ្យ ភាគី"ខ"ឈ្នះ "ក" មិនពេញចិត្តនឹងសាលក្រមរបស់សាលាដំបូងក៏អាចធ្វើប្តឹងឧទ្ធរណ៍បាន។[8] ជាទូទៅបណ្តឹងតែងតែមានការទាមទារដែលកម្មវត្ថុនៃបណ្តឹង ហេតុនេះបណ្តឹងឧទ្ធរណ៍ភាគីនៃបណ្តឹងត្រូវសរសេរជាចាំបាច់ នូចមូលហេតុដែលទាមទារឲ្យលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមនោះ។[9]

---

[8] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៥ កថាខណ្ឌទី១

[9] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៥

### ២. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ អាចធ្វើឡើងបានដោយដើមចោទ និងចុងចម្លើយដែលបានបាត់បង់ផលប្រយោជន៍ដោយសារសាលក្រមរបស់សាលាដំបូង គឺភាគីចាញ់ក្តីមួយផ្នែក ឬទាំងស្រុងភាគីដែលមានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ហើយអាចធ្វើបានមួយផ្នែក ឬទាំងស្រុងបាន។

ឧទាហរណ៍ សាលាដំបូង បង្គាប់ឲ្យ ភាគី "ខ" បង់ប្រាក់ចំនួន ១០០០០ដុល្លា មកឲ្យភាគី "ក" ត្រង់ចំណុចនេះ ភាគី "ខ" អាចប្តឹងឧទ្ធរណ៍បាន។ ហើយសម្រាប់រយៈពេលនេះបណ្តឹងឧទ្ធរណ៍មានរយៈពេល ១ ខែ គិតចាប់ពីភាគីបានទទួលសាលក្រមនោះ។

ចំពោះរយៈពេលនៃការដាក់ពាក្យបណ្តឹងមានរយៈពេល ១ខែ គិតចាប់ពីថ្ងៃភាគីទទួលបានការបញ្ជូនលិខិតសាលក្រមនោះ[10] ឬថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។

### ៣ អនុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

#### ក.ការបង្អាក់ការចូលស្ថាពរនៃសាលក្រម

ការបង្អាក់នៃការចូលជាស្ថាពរនៃសាលក្រមជំនុំជម្រះលើកទី១ ដោយការដាក់ពាក្យប្តឹងឧទ្ធរណ៍ ជាស្ថានភាពនៃការរារាំងការចូលជាស្ថាពររបស់សាលក្រមដែលបានកំណត់តាមច្បាប់។ មានន័យថានៅពេលភាគីដែលបាត់បង់ផលប្រយោជន៍នោះក្នុងរឿងក្តីដែលខ្លួនមិនសុខចិត្តនឹងសាលក្រមនៃការជំនុះជម្រះលើកទី ១ នោះបានប្តឹងទៅសាលាឧទ្ធរណ៍ដូចនេះសាលក្រមដែលសម្រេចដោយសាលាដំបូងនោះត្រូវបង្អាក់ការចូលជាស្ថាពររបស់សាលក្រម។

#### ខ.ការផ្ទេរការជម្រះក្តី

ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ ដែលបានធ្វើឡើងក្នុងរយៈពេលដែលបានកំណត់ក្នុងច្បាប់ ហើយនឹងមានអានុភាពផ្ទេររឿងក្តី ពីសាលាដំបូងមកសាលាឧទ្ធរណ៍ បានន័យថា រឿងក្តីរបស់ដើមចោទ និងចុងចម្លើយនៃសាលាដំបូង គឺមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងទៀតនោះទេ ពោលគឺជាសមត្ថកិច្ចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍នោះ។

#### គ.អវិភាគភាពនៃបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ដែលបានធ្វើឡើងតាមច្បាប់បានកំណត់ មានអនុភាពបង្អង់ការចូលជាស្ថាពររបស់សាលក្រមចុងក្រោយរបស់សាលាដំបូងទាំងមូល ទោះបីជាបណ្តឹងឧទ្ធរណ៍ធ្វើឡើងចំពោះតែផ្នែកណាមួយនៃសាលក្រមចុងក្រោយរបស់សាលាដំបូងក៏ដោយ។

ឧទាហរណ៍ សាលក្រមរបស់សាលាដំបូង ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលសម្រេចដូចតទៅ

(១) បង្គាប់ ឲ្យ "ក" សងលុយមកឲ្យ "ខ" ចំនួន ១០០០០$(ដុល្លា)

[10] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៤

(២) បង្គាប់ឲ្យ "ក" សងជំងឺចិត្តមកឲ្យ "ខ" ចំនួន ៣០០០$(ដុល្លា)

(៣) បង្គាប់ឲ្យ"ខ" បង់ការប្រាក់ ៨%ឲ្យ "ក"

"ខ"ប្តឹងឧទ្ធរណ៍មិនសុខចិត្ត ត្រង់ចំណុច (២)។

## ៤. ការជំនុំជម្រះរបស់តុលាការ( សាលាឧទ្ធរណ៍ តាមរយៈសភាវដ្ឋប្បវេណី )

### (១).ការទទួលពាក្យបណ្តឹង

ភាគីដែលខាតបង់ផលប្រយោជន៍ អំពីសេចក្តីសម្រេចរបស់សាលាដំបូងនៃការជំនុំជម្រះលើកទី១ អាចដាក់ពាក្យបណ្តឹងនៅតុលាការដើម គឺសាលាដំបូង ហើយតុលាការនៃសាលាដំបូងនេះ (តុលាការដើម)ត្រូវបញ្ជូនសំណុំរឿងទាំងអស់នោះទៅតុលាការនៃបណ្តឹងឧទ្ធរណ៍នោះ។ បន្ទាប់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវទទួលបន្ទុករឿងក្តីនេះ។

តុលាការដំបូងមានភារកិច្ចទទួលយកពាក្យបណ្តឹងឧទ្ធរណ៍របស់ភាគីដែលបានដាក់បណ្តឹង ហើយបញ្ជូនសំណុំរឿងទៅតុលាការឧទ្ធរណ៍។ ដូចនេះតុលាការដំបូងពុំមានសមត្ថកិច្ចពិនិត្យលើបណ្តឹងដូចជា ការបង់ពន្ធ មូលហេតុប្តឹងឧទ្ធរណ៍ អំឡុងពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ ទាំងនេះគឺជាសមត្ថកិច្ចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

### (២).ការពនិត្យពាក្យបណ្តឹង ( នាម អាសយដ្ឋាន, ការបង់ប្រាក់ប្រដាប់ក្តី)

នៅពេលដែលតុលាការឧទ្ធរណ៍ទទួលបានពាក្យបណ្តឹងឧទ្ធរណ៍ តុលាការនឹងពិនិត្យលើពាក្យបណ្តឹង[11] នូវចំណុចដូចជា ៖

-នាម នាមករណ៍ អាសយដ្ឋានភាគី ព្រមទាំង នាម នាមករណ៍ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ សញ្ញាណនៃសាលក្រម, និងសេចក្តីដែលប្តឹងឧទ្ធរណ៍នោះ។

-ការបង់ប្រាក់ប្រដាប់ក្តី ក្នុងករណីដែលភាគីមិនបានបង់ពន្ធ ឬខ្វះខាតចំណុចណាមួយ នោះតុលាការនឹងបង្គាប់ឲ្យកែតម្រូវ ដោយកំណត់ពេលមួយសមរម្យ ប្រសិនបើក្នុងករណីដែលភាគីមិនដាក់ ឬមិនព្រមកែតម្រូវនោះទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញដីកាសម្រេចលើចោលពាក្យបណ្តឹងឧទ្ធរណ៍។[12]

### (៣)ការបញ្ជូនពាក្យបណ្តឹង

នៅពេលក្រោយដែលតុលាការនៃបណ្តឹងឧទ្ធរណ៍បានពិនិត្យពាក្យបណ្តឹងរួចហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅឲ្យចុងបណ្តឹងឧទ្ធរណ៍ ដើម្បីឲ្យភាគីចុងចម្លើយបានដឹង និងបានត្រៀមខ្លួនដើម្បីតទល់ ឆ្លើយតបជាមួយម្ចាស់បណ្តឹងឧទ្ធរណ៍។

[11] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៦, កថាខណ្ឌទី១

[12] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦២, កថាខណ្ឌទី២

### ៥. ការដកពាក្យបណ្ដឹង

ចំពោះបណ្ដឹងឧទ្ធរណ៍វិញទោះបីជាបានដាក់ក៏ដោយភាគីនៅតែមានសិទ្ធិដកពាក្យបណ្ដឹងនោះវិញបាន ដោយមិនបាច់មានការយល់ព្រមពីភាគីចុងចម្លើយឧទ្ធរណ៍ ប្រសិនបើរឿងនៅបណ្ដឹងឧទ្ធរណ៍នោះមិនទាន់បាន ចេញសាលដីកា បានន័យថា ដរាបណារឿងនៅបណ្ដឹងឧទ្ធរណ៍មិនទាន់បានចេញសាលដីកានោះទេភាគីដែល ដាក់ពាក្យបណ្ដឹងនៅតែដកពាក្យបណ្ដឹងនោះវិញបាន។

ចំពោះការដកពាក្យបណ្ដឹងឧទ្ធរណ៍ គឺជាការដកចេញនូវពាក្យបណ្ដឹង ឧបាស្រ័យចំពោះសាលក្រមនៃ ការជំនុំជម្រះនៅសាលាដំបូង ហើយអនុភាពនៃការដកពាក្យបណ្ដឹងឧទ្ធរណ៍ ធ្វើឲ្យនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ត្រូវ បានបញ្ចប់ និងត្រូវបានចាត់ទុកថាគ្មានពាក្យបណ្ដឹងឧទ្ធរណ៍តាំងពីដើមមក ហើយសាលក្រមនៃសាលាដំបូង នោះ ត្រូវបានចូលជាស្ថាពរ តាំងពេលផុតបណ្ដឹងឧទ្ធរណ៍។[13]

ឧទាហរណ៍ ភាគី"ក" មិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់សាលាដំបូងចុះថ្ងៃទី ០១ ០៣ ២០២១ ក៏ បានប្ដឹងឧទ្ធរណ៍ តែក្រោយមក ភាគី "ក" យល់ឃើញថា ចង់ដកពាក្យបណ្ដឹងភាគីដែលប្ដឹង អាចដកពាក្យបណ្ដឹង បានដោយមិនមានការយល់ព្រមពី ភាគីចុងចម្លើយ។ក្នុងករណីនេះ សាលក្រមសាលាដំបូងចាត់ទុកជាបានការ ដដែល បន្ទាប់ពីផុតប្ដឹងឧទ្ធរណ៍នោះមក។

### ៦. ការវិនិច្ឆ័យ និងការចេញសាលដីកា

តុលាការនៃបណ្ដឹងឧទ្ធរណ៍ធ្វើការវិនិច្ឆ័យ នៃសាលក្រមជំនុំជម្រះលើកទី១ គឺត្រឹមកម្រិតនៃការទាមទារ ដែលបានដាក់ប្ដឹងតែប៉ុណ្ណោះ ពោលគឺនៅក្នុងពាក្យបណ្ដឹងឧទ្ធរណ៍។ ចំពោះចំណុចផ្សេងៗដែលមិនបានដាក់ ប្ដឹងមកសាលាជម្រះឧទ្ធរណ៍។[14] គឺមិនត្រូវបានលើកយកមកវិនិច្ឆ័យឡើយ ហើយតុលាការនៃបណ្ដឹងឧទ្ធរណ៍ មិនអាចសម្រេចបាននោះទេ។ នៅក្នុងនោះផងដែលតុលាការនៃបណ្ដឹងឧទ្ធរណ៍ក៏ធ្វើការវិនិច្ឆ័យផងដែលថា ពាក្យបណ្ដឹងដែលភាគីបានដាក់មកនោះត្រឹមត្រូវ ឬមិនត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ម៉្យាងទៀត ដើមបណ្ដឹងឧទ្ធរណ៍ មិនអាចទទួលសាលដីកាដែលខូចប្រយោជន៍ច្រើនជាងសាលក្រមនៃការជំនុំជម្រះលើកទី១នោះឡើយ។ តុលាការនៃការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ មានដូចជា **សាលដីកាលើកចោលបណ្ដឹងឧទ្ធរណ៍ សាលដីកាច្រាន ចោលបណ្ដឹងឧទ្ធរណ៍ និងសាលដីកាទទួលស្គាល់បណ្ដឹងឧទ្ធរណ៍**

#### ៦.១ សាលដីកាលើកចោលបណ្ដឹងឧទ្ធរណ៍ (ផុតសិទ្ធិប្ដឹងឧទ្ធរណ៍)

តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាចុងក្រោយចំពោះបណ្ដឹងឧទ្ធរណ៍ ឬ អ្នកប្ដឹងឧទ្ធរណ៍ ដែលគ្មានសិទ្ធិប្ដឹងឧទ្ធរណ៍ គ្មានផលប្រយោជន៍នៃការប្ដឹងឧទ្ធរណ៍ជាអាទិ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវចេញ សាលដីកាលើកចោលពាក្យបណ្ដឹងឧទ្ធរណ៍ ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ហៅ ថា សាលដីកាលើកចោលពាក្យបណ្ដឹងឧទ្ធរណ៍។[15]

---

[13] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៥

[14] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៧៨

[15] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៨

**៦.២ សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍( យល់ថាសាលក្រមថាត្រឹមត្រូវ)**

ក្នុងករណី តុលាការយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ ត្រឹមត្រូវតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញ **សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍** ទោះបីសំអាងហេតុនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវក៏ដោយ រួចបើយល់ឃើញថា សេចក្តីសម្រេចបញ្ចប់នៃសាលក្រមនៃការជនុំជម្រះលើកទី១នោះត្រឹមត្រូវ បើផ្អែកតាមសំអាងហេតុផ្សេងទៀត។

**៦.៣ សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍**

ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវ ឬ ខុស **នីតិវិធីធ្ងន់ធ្ងរ** តុលាការត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ដោយធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលាដំបូង ឬ បញ្ជូនត្រឡប់ ឬ ផ្ទេររឿងក្តី។

ឧទាហរណ៍ តុលាការដែលជំនុំជម្រះ គឺជាតុលាការដែលខុសសមត្ថកិច្ច ដែលគ្មានសិទ្ធិក្នុងការជំនុំជម្រះ សាលាឧទ្ធរណ៍លុបចោលសាលក្រម តុលាការដំបូងដែលខុសសមត្ថកិច្ចនោះ ហើយផ្ទេរសមត្ថកិច្ចជូនតុលាការដែលមានសមត្ថកិច្ចវិញ។

**៧. វិសាលភាពនៃការលុបចោល និងការផ្លាស់ប្តូរ**

**៧ ១.ការលុបចោល និងជំនុំជម្រះដោយខ្លួនឯង**

(១) តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ ( សាលក្រមមានកំហុស)។

ក្នុងករណីខ្លះ តុលាការនៃបណ្តឹងឧទ្ធរណ៍ មិនលុបចោលសាលក្រម នៃការជំនុំជម្រះលើកទី១ទាំងស្រុងនោះទេ ប៉ុន្តែ ធ្វើការផ្លាស់ប្តូរ ឬកែប្រែខ្លឹមសារសាលក្រមនៃការជំនុំជម្រះលើកទី១។

(២) តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ ខុសធ្ងន់ធ្ងរ។ កំហុសនីតិវិធីធ្ងន់ធ្ងរ មានដូចជាការសួរសាក្សីនៅក្នុងនីតិវិធីត្រៀម ឬ ចេញដីកាកោះដោយមិនបានជូនដំណឹងទៅភាគី ឬការប្រកាសសាលក្រមដោយចៅក្រមដែលមិនមែនជាអ្នកវិនិច្ឆ័យជាអាទិ៍។

**៧.២ ការលុបចោល និងការបញ្ជូនត្រឡប់**

**(១)** ក្នុងករណី តុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ទទួលបានពាក្យបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមលើកចោលពាក្យបណ្តឹងរបស់តុលាការនៃការជំនុំជម្រះលើកទី១ ប្រសិនបើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ **មិនត្រូវអនុលោមតាមច្បាប់**នោះទេ ហើយមានភាពចាំបាច់**ត្រូវទាញហេតុផលបន្ថែមទៀត**ចំពោះរឿងក្តីនោះ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមជំនុំជម្រះលើកទី១ ហើយបញ្ជូនត្រឡប់ទៅកាន់តុលាការដើមវិញ។

តុលាការក៏អាច**លើកចោលនូវបណ្តឹង** ដោយមូលហេតុខ្វះលក្ខខណ្ឌនៃបណ្តឹង បណ្តឹងផ្ទុយច្បាប់ដែលមិនអាចកែតម្រូវបាន។

(២) ក្នុងករណីតុលាការដំបូងទទួលស្គាល់ការទាមទារ ប៉ុន្តែក្នុងករណីមាន **កំហុសនីតិវិធីធ្ងន់ធ្ងរ** ដោយអវត្តមានភាគីណាមួយ នៅក្នុងនីតិវិធីនៃទាញហេតុផលដោយផ្ទាល់មាត់ដោយភាគីមិនបានទទួលដីកាកោះតាមច្បាប់។[16] ពោលគឺនៅពេលធ្វើនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកោះហៅគូរភាគីមកចូលរួម។ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមដើម និងបញ្ជូនត្រឡប់ ដើម្បីធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះការលុបចោល រួចបញ្ជូនមកវិញទៅតុលាការដើម តុលាការនៃបណ្តឹងឧទ្ធរណ៍និងមិនសម្រេចអំពីប្រាក់ប្រដាប់ក្តីឡើយ ពីព្រោះការសម្រេចសេចក្តីនេះមិនទាន់បញ្ជាក់ពី អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិរបស់ភាគីនៅឡើយ។

ការសម្រេចប្រាក់ប្រដាប់ក្តី គឺជាការកំណត់អំពីបន្ទុកនៃចំណាយត្រូវបានប្រើប្រាស់ក្នុងនីតិវិធីរបស់តុលាការដោយភាគី មូលដ្ឋាននៃការសម្រេចគឺផ្អែកលើការកំណត់ស្ថាពរនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត។

**៧.៣ ការលុបចោល និងការផ្ទេររឿងក្តី**

តុលាការនៃបណ្តឹងឧទ្ធរណ៍ លុបចោលសាលក្រមដើម ហើយនឹងផ្ទេរសមត្ថកិច្ចទៅតុលាការដែលមានសម្ថកិច្ច ក្នុងករណីដែលតុលាការដំបូងបានជំនុំជម្រះសេចក្តីលើរឿងក្តីដែលខ្លួនគ្មានសមត្ថកិច្ច។

## កថាភាគទី ២ ៖ បណ្តឹងសាទុក្ខ

### ១.អត្ថន័យនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខគឺជាប្រភេទនៃបណ្តឹងឧបាស្រ័យដែលធ្វើទៅតុលាការជាន់ខ្ពស់ និងបណ្តឹងធ្វើឡើងប្រឆាំងនិងសេចក្តីសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍ ឬធ្វើឡើងប្រឆាំងនិងសេចក្តីសម្រេចចុងក្រោយរបស់អាចធ្វើទៅតុលាការកំពូលបាន ប្រសិនបើភាគីគិតថា បានបាត់បង់ផលប្រយោជន៍។ មួយវិញទៀតបណ្តឹងសាទុក្ខ ក៏អាចផ្តល់ក្តីសង្ឃឹមដល់គូរភាគីដែលចាញ់ក្តីនៅថ្នាក់ក្រោមផងដែរ។[17] រយៈពេលនៃបណ្តឹងសាទុក្ខមានរយៈពេល ១ ខែ។ បានន័យថាការជំនុំជម្រះបណ្តឹងសាទុក្ខគឺជាជំនុំជម្រះលើអង្គច្បាប់ ហើយវិនិច្ឆ័យ និងពិនិត្យតែធនធានដែលបានប្រើប្រាស់សម្រាប់ការវិនិច្ឆ័យនៅក្នុងសាលក្រម ឬសាលដីកានោះ មិនអាចបញ្ចូលភស្តុតាងបន្ថែមបានឡើយ។

#### ១.១ ប្រភេទនៃបណ្តឹងសាទុក្ខ

##### ១.១.១ បណ្តឹងសាទុក្ខទូទៅ

បណ្តឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍។[18]មានន័យថានៅពេលភាគីដែលបាត់បង់ផលប្រយោជន៍មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ រួចប្តឹងមកតុលាការកំពូលដើម្បីជំនុំជម្រះ។

ឧទាហរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍បាន សម្រេចបង្គាប់ ភាគី "ក" សង់លុយ ចំនួន ១0000$និង

---

[16] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១១៣

[17] ប្រសាសន៍លោកមេធាវី កែវ វន្នី

[18] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៣, កថាខណ្ឌទី១, វាក្យខណ្ឌទី១

ការប្រាក់ ៦% ក្នុងមួយខែ មកឲ្យភាគី "ខ"។ ភាគី "ក" មិនពេញចិត្តកសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ក៏បានដាក់ពាក្យបណ្តឹងសារទុក្ខ ទៅតុលាការកំពូលធ្វើការវិនិច្ឆ័យ។

### ១.១.២ បណ្តឹងសារទុក្ខផ្លោះ

ចំពោះបណ្តឹងសារទុក្ខផ្លោះ គឺជាពាក្យបណ្តឹងប្តឹងចំពោះ សាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី១ ដោយសាលាដំបូង នៅក្នុងករណីដែលគូរភាគីបានព្រមព្រៀងគ្នាមិនប្តឹងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ឡើយ នៅពេលដែលតុលាការដំបូងបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្តឹងសារទុក្ខ បណ្តឹងសារទុក្ខអាចធ្វើទៅតុលាការកំពូលបាន។[19]

បណ្តឹងឧទ្ធរណ៍អាចធ្វើបានចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ ៖

ក គូរភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកសិទ្ធិប្តឹងសារទុក្ខ ក្រោយពេលដែលតុលាការបានចេញសាលក្រមចុងក្រោយ។ បានន័យថាភាគីត្រូវធ្វើលិខិតទាំងនោះត្រូវជាលាយល័ក្ខណ៍អក្សរនៅពេលក្រោយដែលតុលាការដំបូងបានចេញសាក្រមចុងក្រោយ។

### ១.១.៣ បណ្តឹងសារទុក្ខបន្ទាប់បន្សំ

បណ្តឹងបន្ទាប់បន្សំ គឺជាបណ្តឹងឧបាស្រ័យដោយភ្ជាប់និងសាទុក្ខរបស់ភាគីម្ខាងទៀតចំពោះចំណុចដែលចុងចម្លើយបណ្តឹងសារទុក្ខបាត់បង់ផលប្រយោជន៍ ។[20]

ក្នុងករណីបណ្តឹងសារទុក្ខ ត្រូវបាត់បង់អនុភាព នៅពេលដែលតុលាការនៃបណ្តឹងសារទុក្ខលើកចោល (ផុតរយៈពេលប្តឹង) បណ្តឹងសារទុក្ខ ឬដើមបណ្តឹងសារទុក្ខបានដកពាក្យបណ្តឹងបន្ទាប់បន្សំនោះធ្វើឡើងដោយ**បានហួសពេលប្តឹងសារទុក្ខ**។[21] ប៉ុន្តែបណ្តឹងបន្ទាប់បន្សំបានធ្វើឡើងដោយ**ឯករាជ្យ** ទោះបីជាតុលាការនៃបណ្តឹងសារទុក្ខលើកចោល ឬដើមបណ្តឹងសារទុក្ខបានដកពាក្យបណ្តឹងសារទុក្ខក៏ដោយ ក៏មិនប៉ះពាល់ដល់បណ្តឹងបន្ទាប់បន្សំដែរ ( មិនបានបាត់បង់អនុភាព ) ហើយនៅក្នុងករណីនេះតុលាការនៃបណ្តឹងសារទុក្ខនឹងធ្វើចំណាត់ការលើបណ្តឹងបន្ទាប់បន្សំ។[22]

## ២.មូលហេតុប្តឹងសារទុក្ខ

### ២.១ មូលហេតុទូទៅនៃបណ្តឹងសារទុក្ខ

មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ដោយកំណត់ហេតុនីមួយៗ ដែលក្លាយជាហេតុនៃការធ្វើឧបាស្រ័យចំពោះសាលដីកាដើម ឬសាលក្រមដើម(ហេតុដែលធ្វើឲ្យបានត្រឹមត្រូវក្នុងការបដិសេធចោលនូវសាលដីកាដើម

[19] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៣, កថាខណ្ឌទី២ និងមាត្រា២៦០, កថាខណ្ឌទី១

[20] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៦ និងមាត្រា២៧០

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៦, មាត្រា២៧០, កថាខណ្ឌទី២

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៧០, កថាខណ្ឌទី២, វាក្យខណ្ឌទី២

(សាលក្រមដើម)។[23]មានន័យថាក្នុងករណីមានមូលហេតុដូចនេះមែន តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបដិសេធនូវសាលដីកាដើម (សាលក្រមដើម) ។ផ្ទុយទៅវិញ ប្រសិនបើគ្មានមូលហេតុនេះទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងសាទុក្ខនោះ ។

### ២.២ មូលហេតុដាច់ខាតនៃបណ្តឹងសារទុក្ខ

ក្នុងករណីជាក់លាក់ណាមួយ ត្រូវចាត់ទុកថា មានមូលហេតុនៃបណ្តឹងសាទុកដរាប ។បើទោះបីជាគ្មានឥទ្ធិពលដល់សាលដីកា ឬ សាលក្រមក៏បានដែរព្រោះច្បាប់បានប្រើពាក្យថា ដរាប ដែលបានបញ្ញត្តិទុកក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។មានន័យថា ចៅក្រមដែលចេញសាលដីកា ឬសាលក្រមមិនត្រូវបានចាត់តាំងដោយស្របច្បាប់, ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលក្រម ឬសាលដីកា តែបានចូលរួម (ចៅក្រមដែលត្រូវបានប្តឹងជិតចិត្ត), ភាពផ្ទុយនឹងសមត្ថកិច្ចផ្តាច់មុខ (បណ្តឹងលែងលះ), ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ (អ្នកតំណាងមិនបានដាក់ឯកសារបញ្ជាក់ថាខ្លួនមានសិទ្ធិតំណាង) ខ្វះសិទ្ធិតំណាងដោយអាណត្តិ (ធ្វើសកម្មភាពបណ្តឹងដោយមិនមានការប្រគល់សិទ្ធិ ឬចាត់តាំង) ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង (មិនមានលិខិតប្រគល់សិទ្ធិធ្វើបណ្តឹងជាអាទិ៍), ភាពផ្ទុយពីការបើកការទាញហេតុផល ដោយផ្ទាល់មាត់ជាសាធារណៈ (ការបើកសវនាការជាសាធារណៈចំពោះរឿងក្តីលែងលះ), សាលក្រម ឬសាលដីកា គ្មានសំអាងហេតុ ឬមានសំអាងហេតុដែលមានភាពផ្ទុយគ្នា នឹងសេចក្តីសម្រេចបញ្ចប់។[24]

## ៣. នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ និងការចេញសាលដីកា

ក្រោយពីតុលាការឧទ្ធរណ៍ចេញសាលដីកា រួចលើបណ្តឹងរបស់ភាគី បើភាគីនៅតែមិនយល់ស្របទៅលើសេចក្តីសម្រេចនោះ ភាគីអាចធ្វើការប្តឹងមកតុលាការកំពូល ដែលជាតុលាការចុងក្រោយនៃការជំនុំជម្រះក្តី។ ហើយនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ នឹងការចេញសាលដីកា នឹងធ្វើការបកស្រាយនូវចំណុចខាងក្រោម៖

### ៣.១. ការជំនុំជម្រះបណ្តឹងសាទុក្ខ

តុលាការនៃបណ្តឹងសាទុក្ខត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលដីការដើម ឬសាលក្រមដើមត្រឹមកម្រិតនៃឧបាស្រ័យប៉ុណ្ណោះ ដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខដែលត្រូវបានដាក់ដោយស្របច្បាប់។ ការជំនុំជម្រះលើអង្គសេចក្តី តុលាការត្រូវពិនិត្យមើលឯកសារដូចជា **ពាក្យបណ្តឹង លិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខ** បានដាក់ និងឯកសារផ្សេងៗទៀត ហើយបើយល់ឃើញថាគ្មានមូលហេតុនៃបណ្តឹងសាទុក្ខទេ តុលាការអាចចេញ**ដីកាសម្រេចច្រានចោល**ពាក្យបណ្តឹងនេះដោយ**ចេញសាលដីកា** ដោយមិនឆ្លងកាត់ទាញការហេតុផលដោយផ្ទាល់មាត់។ ទោះបីជាបានទាញហេតុផល

[23] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៤

[24] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២៨៥

ដោយផ្ទាល់មាត់ហើយក៏ដោយបើយល់ឃើញថា ពុំមានមូលហេតុត្រឹមត្រូវសម្រាប់ធ្វើបណ្ដឹងសាទុក្ខទេ តុលាការត្រូវច្រានចោលពាក្យបណ្ដឹងនោះ។

ក្នុងករណីទទួលស្គាល់ថា បណ្ដឹងសាទុក្ខមានមូលហេតុត្រឹមត្រូវតុលាការត្រូវបដិសេធចោលសាលក្រម ឬសាលដីកាដើម មានន័យថា តុលាការនៃការជំនុំជម្រះលើអង្គច្បាប់លុបចោលនូវសាលក្រម ឬសាលដីកាដើម។ ក្រោយការបដិសេធ សាលក្រម ឬសាលដីកាដើម តុលាការពុំពិនិត្យ និងទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនៃរឿងក្ដីទេ ក្នុងករណីនេះ តុលាការត្រូវបញ្ជូនរឿងក្ដីទៅកន្លែងដើមវិញ។

តុលាការដែលទទួលការបញ្ជូនត្រលប់ ត្រូវធ្វើការជំនុំជម្រះដោយទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីចំពោះរឿងក្ដី តាមនីតិវិធីនៃការជំនុំជម្រះនោះ ប៉ុន្តែការវិនិច្ឆ័យជាថ្មី របស់តុលាការដែលទទួលការបញ្ជូន ត្រូវទទួលអានុភាពចងនៃការវិនិច្ឆ័យលើ**អង្គហេតុនិងអង្គច្បាប់** ដែលតុលាការ នៃបណ្ដឹងសាទុក្ខ យកជាមូលហេតុនៃការបដិសេធចោលសាលក្រមឬសាលដីកាដើម។ មានន័យថា តុលាការដើមមិនអាចវិនិច្ឆ័យដែលមានលទ្ធផលដូចសាលក្រម ឬសាលដីកាមុនដោយផ្អែកលើអង្គច្បាប់ ដែលតុលាការនៃបណ្ដឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធសាលក្រម ឬ សាលដីកា។

ក្រៅពីមានការបដិសេធដោយការបញ្ជូនត្រលប់ទៅតុលាការនៃបណ្ដឹងសាទុក្ខ អាចវិនិច្ឆ័យដោយខ្លួនឯង ជំនួសនូវការបញ្ជូនត្រលប់បាន លុះត្រាតែកាលដែលមានមូលហេតុដូចមានចែងក្នុងមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណីការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង។

### ៣.១.១ដីកាសម្រេចលើកចោលបណ្ដឹងសាទុក្ខ

តុលាការនៃបណ្ដឹងសាទុក្ខត្រូវលើកចោលបណ្ដឹងសាទុក្ខ ដោយដីកាសម្រេច ប្រសិនបើបណ្ដឹងសាទុក្ខនោះមិនស្របច្បាប់ ហើយមិនអាចកែតម្រូវបាននោះទេ ឬប្រសិនបើបើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ មិនត្រូវបានដាក់ទៅតុលាការនៃបណ្ដឹងសាទុក្ខ ឬប្រសិនបើមានភាពផ្ទុយគ្នានឹងមាត្រា ២៨៩ កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ (មាត្រា ២៩០)។

ប៉ុន្តែក្នុងករណី ដែលមិនបានចេញដីកាសម្រេចលើកចោលបណ្ដឹងសាទុក្ខនោះទេ ជាគោលការណ៍ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ទៅចុងបណ្ដឹងសាទុក្ខ ហើយត្រូវផ្ដល់ឱកាសឲ្យចុងបណ្ដឹងសាទុក្ខដាក់ឯកសារត្រៀម។[25] តុលាការនេះត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវដោយផ្អែកលើមូលហេតុនៃបណ្ដឹងសារទុក្ខដែលស្របច្បាប់តែប៉ុណ្ណោះ។[26] បានន័យថា ប្រសិនបើតុលាការបានយល់ឃើញថា បណ្ដឹងសាទុក្ខត្រឹមត្រូវតាមច្បាប់ហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យទៅលើមូលហេតុនៃបណ្ដឹងសាទុក្ខ ហើយត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ទៅ

[25] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩២

[26] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៥

ចុងបណ្តឹងសាទុក្ខ ប៉ុន្តែ ឧទាហរណ៍ ប្រសិនបើក្រោយមកតុលាការយល់ឃើញ បណ្តឹងសាទុក្ខនោះមិនស្របច្បាប់ តុលាការត្រូវចេញដីកាលើកចោលនូវបណ្តឹងសាទុក្ខនោះ ហេតុដូចនេះមិនបាច់បញ្ជូនឯកសារចម្លងនោះឡើយ ។

### ក. មិនដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ

ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្តឹងសាទុក្ខក្នុងពាក្យបណ្តឹងសាទុក្ខទេ ដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្តឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្តឹងសាទុក្ខ ប្រសិនបើមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ**ក្នុងរយៈពេលកំណត់នោះទេ**(៣០ថ្ងៃ)[27] តុលាការនៃបណ្តឹងសាទុក្ខនឹងចេញដីកាសម្រេច លើកចោលពាក្យបណ្តឹង ។[28]

### ខ.មិនកែតម្រូវចំណុចខ្វះខាតក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ

ប្រសិនបើបានសរសេរនូវមូលហេតុនៃបណ្តឹងសាទុក្ខក្នុងពាក្យបណ្តឹងសាទុក្ខទេ ដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្តឹងសាទុក្ខ បើមាន**ការខ្វះខាត** តុលាការនៃបណ្តឹងសាទុក្ខបង្គាប់ឲ្យកែតម្រូវ ប្រសិនបើភាគីមិនបានកែតម្រូវនោះទេ តុលាការនឹងលើកចោលពាក្យពាក្យបណ្តឹង ដោយ**ដីកាសម្រេច** ។[29]

### ៣ ១.២.ដីកាសម្រេចលើកចោលពាក្យបណ្តឹងសាទុក្ខ

នៅពេលដើមបណ្តឹងសាទុក្ខ បានដាក់ពាក្យបណ្តឹងសាទុក្ខទៅកាន់តុលាការកំពូល ហើយតុលាការនៃបណ្តឹងសាទុក្ខត្រូវពនិត្យលើពាក្យបណ្តឹង មានចំណុចខ្វះខាតដែរឬទេ ?ប្រសិនបើខ្វះខាត អាចកែតម្រូវបានដែរ ឬ ទេ? ក្នុងករណីដែលមិនអាចកែតម្រូវបាន តុលាការនៃបណ្តឹងសាទុក្ខ ចេញដីកាសម្រេច លើកចោលពាក្យពាក្យបណ្តឹង។[30] ឧទាហរណ៍ភាគីមិនបង់ពន្ធលើពាក្យបណ្តឹងជាដើម។ ចំណែកចំពោះបណ្តឹងសាទុក្ខដែលមិនស្របច្បាប់ ហើយមិនអាចកែតម្រូវបាន តុលាការនៃបណ្តឹងសាទុក្ខ ចេញដីកាសម្រេច លើកចោលពាក្យបណ្តឹងសាទុក្ខ។[31]

### ៣.១.៣ សាលដីកាច្រានចោលបណ្តឹងសាទុក្ខ

### ក.មិនឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់

នៅពេលពនិត្យពាក្យបណ្តឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដែលចុងបណ្តឹងសាទុក្ខបានដាក់លើកដំបូង ឬឯកសារផ្សេងៗទៀត បើតុលាការនៃបណ្តឹងសាទុក្ខយល់ឃើញថា

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៩
[28] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩០
[29] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩០
[30] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៦ និងមាត្រា២៦៦ កថាខណ្ឌ២
[31] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩០ ចំណុច ក

បណ្តឹងសាទុក្ខនោះ **គ្មានមូលហេតុ** តុលាការអាចច្រានចោលបណ្តឹងសាទុក្ខដោយ **សាលដីកា** ដោយមិនបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ។[32]

**ខ.ឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់(២៩៤)**

នៅពេលពិនិត្យពាក្យបណ្តឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដែលចុងបណ្តឹងសាទុក្ខបានដាក់លើកដំបូង ឬ ឯកសារផ្សេងៗទៀតតុលាការនៃបណ្តឹងសាទុក្ខអាចបើកការទាញហេតុផលដោយផ្ទាល់មាត់ប្រសិនបើមិនមានការវិនិច្ឆ័យច្បាស់ ហើយបើតុលាការនៃបណ្តឹងសាទុក្ខយល់ឃើញថា បណ្តឹងសាទុក្ខនោះ**គ្មានមូលហេតុ** តុលាការអាចច្រានចោលបណ្តឹងសាទុក្ខដោយសាលដីកា។[33]

**៤.សាលដីកាទទួលស្គាល់នូវបណ្តឹងសាទុក្ខ**

ក្នុងករណីទទួលស្គាល់ថា មានមូលហេតុត្រឹមត្រូវសម្រាប់ធ្វើបណ្តឹងសាទុក្ខ តុលាការត្រូវបដិសេធចោលនូវសាលក្រម ឬសាលដីកាដើម។ ការបដិសេធចោលមានន័យថា តុលាការនៃការជំនុំជម្រះលើអង្គច្បាប់លុបចោលនូវសាលដីកាដើម ឬសាលក្រមដើម។ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលដែលបដិសេធចោលនូវសាលដីកាដើម ឬសាលក្រមដើម *(ការបកស្រាយបញ្ជាក់នៃមាត្រា ២៩៤)*។

**៤.១. ការបដិសេធចោល និងបញ្ជូនត្រលប់ទៅតុលាការដើម ឬការបដិសេធចោល និងផ្ទេរសំណុំរឿងរឿងក្តី**

ជាគោលការណ៍ ក្រោយការបដិសេធចោលនូវសាលក្រម ឬសាលដីកាដើមតុលាការពុំចាំពិនិត្យ និងទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនៃរឿងក្តីទេ ដូច្នេះហើយករណីនេះ ខុសពីករណីនៃការលុបចោលនូវសាលក្រម ដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីទៅតុលាការដើមវិញ។ ជាបឋមក្នុងករណីដែលមិនបានធ្វើការទទួលស្គាល់អង្គហេតុសាជាថ្មីមិនអាចធ្វើការជំនុំជម្រះជំនួសសាលក្រម ឬសាលដីកាដើមទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះទៅតុលាការដើមវិញ ឬ នៅក្នុងករណីដែលយល់ឃើញថា ការបញ្ជូនត្រលប់នោះមិនសមស្របទេ ដោយសារមានការកម្រិតនៃកថាខណ្ឌទី ៣ មាត្រា ២៩៩ (ដែលមានការពន្យល់ខាងក្រោម) ត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។[34] តុលាការដែលបានទទួលនូវការបញ្ជូនត្រលប់មកវិញ ឬដែលបានទទួលនូវការផ្ទេរនោះ ត្រូវធ្វើការជំនុំជម្រះដោយធ្វើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី ចំពោះរឿងក្តីនោះតាមនីតិវិធីនៃថ្នាក់ជំនុំជម្រះនោះ។ ការទាញហេតុផលដោយផ្ទាល់មាត់នោះជាសារជាតុ គឺជាការបើកឡើងវិញ និងបន្តនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានធ្វើពីមុនមក។ ប៉ុន្តែដូចដែលនឹងពន្យល់ខាងក្រោម ចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬសាលក្រម

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៤

[33] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៤

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៩ កថាខណ្ឌទី២

ដើមមិនអាចចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់នោះ ភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។

ក្នុងករណីនេះ *សេចក្ដីវិនិច្ឆ័យលើអង្គច្បាប់ និងអង្គហេតុ* ដែលតុលាការនៃ *បណ្ដឹងសាទុក្ខបានយកជាមូលហេតុនៃការបដិសេធចោល* ដែលមានសមត្ថកិច្ចទៅលើតុលាការដែលបានទទួលការបញ្ជូន ឬការផ្ទេរ។[35] នេះគឺដោយសារតែ ប្រសិនបើតុលាការដើមនៅតែធ្វើការវិនិច្ឆ័យដូចមុន ឬនៅតែធ្វើការចាត់ចែងដូចមុនដដែលនោះ ទោះជាតុលាការនៃបណ្ដឹងសាទុក្ខបានបញ្ជូនត្រឡប់ទៅវិញប៉ុន្មានដងក៏ដោយ ក៏រឿងក្ដីនោះមិនអាចដោះស្រាយចប់ឡើយ។ សេចក្ដីវិនិច្ឆ័យលើអង្គហេតុដែលមានអានុភាពចងត្រូវបានកម្រិតតែសេចក្ដីវិនិច្ឆ័យអំពីអង្គហេតុដែលតុលាការនៃបណ្ដឹងសាទុក្ខអាចវិនិច្ឆ័យបាន ដូចជាអង្គហេតុដែលទាក់ទងទៅនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិប៉ុណ្ណោះ។[36]

អានុភាពចង នៃសេចក្ដីវិនិច្ឆ័យលើអង្គច្បាប់ដែលសេចក្ដីវិនិច្ឆ័យអំពីចំណុចអង្គច្បាប់នោះដែលមាននៅក្នុងសាលដីការដើម ឬសាលក្រមដើម បានក្លាយទៅជាមូលហេតុនៃការបដិសេធចោល។ ហេតុដូច្នេះ វានុភាពនេះតម្រូវអោយតុលាការដែលទទួលការបញ្ជូន ឬការផ្ទេរជៀសវាងធ្វើការសេចក្ដីវិនិច្ឆ័យអំពីចំណុចអង្គច្បាប់នោះប៉ុណ្ណោះ តែមិនហាមឃាត់អោយតុលាការនោះចេញសាលដីការ ឬសាលក្រមដែលមានសេចក្ដីសន្និដ្ឋានដូចគ្នានឹងសាលដីកា ឬសាលក្រមមុនដោយយកការបកស្រាយផ្សេងនូវអង្គច្បាប់ដែលអាចធ្វើបាន។

ដើម្បីធានានូវអានុភាពនៅក្នុងការវិនិច្ឆ័យនោះបាន គឺចៅក្រមជំនុំជម្រះដែលមានការពាក់ព័ន្ធនឹងសាលក្រមដើម ឬ សាលដីកាដើម ដែលត្រូវបានបដិសេធចោល មិនត្រូវបានអនុញ្ញាតអោយចូលរួមក្នុងការជំនុំជម្រះ និងធ្វើការសម្រេចសេចក្ដីក្រោយនោះបានទេ។[37] ដើម្បីកុំអោយមានឧបសគ្គជាក់ស្ដែង ដោយសារការកម្រិតនេះ ច្បាប់អនុញ្ញាតឲ្យផ្ទេររឿងក្ដីជំនួសការបញ្ជូនត្រឡទៅវិញ។

### ៤.២. ការបដិសេធ និងការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្ដឹងសាទុក្ខ ដែលត្រូវធ្វើការសម្រេចសេចក្ដីផ្ទាល់ដោយខ្លួនឯងដោយមិនចាំបាច់ធ្វើការបញ្ជូនត្រឡប់ ឬ ផ្ទេររឿងក្ដីនោះទៅកាន់តុលាការដើមវិញ។ តុលាការនៃបណ្ដឹងសាទុក្ខដែលបានបដិសេធចោលនូវសាលដីកាដើម ឬ (សាលក្រមដើមបណ្ដឹងសាទុក្ខជាតទៅពន្យល់តែករណីដែលមានក្នុងករណីដែលមានការព្រមព្រៀងជ្រោះទៅ បណ្ដឹងសាទុក្ខចំពោះសាលដីការបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ប៉ុណ្ណោះ) តុលាការអាចធ្វើការវិនិច្ឆ័យ ដោយខ្លួនឯងជំនួសសាលដីកាដើមនោះបានក្នុងករណីដែលអាចចេញនូវ សាលដីកាជំនួសសាលដីកានោះបានដោយផ្អែកលើ អង្គហេតុដែលត្រូវបានកំណត់ជាស្ថាពរនៅក្នុង សាលដីកាដើមតែប៉ុណ្ណោះ។ នៅក្នុងសាលដីកាដែលបានជំនួសសាលដីកាដើម គឺជាចម្លើយចំពោះពាក្យបណ្ដឹងឧទ្ធរណ៍។

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៩ កថាខណ្ឌទី២ វាក្យខណ្ឌ៣

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៧

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៩ កថាខណ្ឌទី៣

ហេតុដូច្នេះ មានករណីខ្លះដែលមិនឆ្លើយផ្ទាល់ចំពោះបណ្តឹងនៃការជំនុំជម្រះលើកទី១ដែរ។ ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខវិនិច្ឆ័យដោយខ្លួនឯង និងចេញសាលដីកាជំនួសសាលដីកាដើមមានករណីដូចតទៅ៖

ជាដំបូង មានករណីដែលតុលាការនៃបណ្តឹងសាទុក្ខ ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ និងលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ឬផ្ទេររឿងក្តីទៅតុលាការនៃការជំនុំជម្រះលើកទី ១។ ក្នុងចំណោមករណីនេះមានពីរករណី គឺ **១** ករណីដែលសាលដីកាដើមដែលត្រូវបានបដិសេធចោល រក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលច្រានចោលកាទាមទារ ឬ រក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខ និង **២** ករណីដែលគួរតែអោយវិនិច្ឆ័យឡើងវិញពីការជំនុំជម្រះលើកទី ១ ដោយសារការជំនុំជម្រះលើកទី ១ ពីមុននោះមិនគ្រប់គ្រាន់។

ក្រៅពីករណីខាងលើ មានករណីដែលតុលាការនៃបណ្តឹងសាទុក្ខលើកចោល ឬ ច្រានចោលបណ្តឹងឧទ្ធរណ៍រួច ឬ ក្នុងករណីដែលទទួលស្គាល់បណ្តឹងឧទ្ធរណ៍ និង ចេញសាលដីកាផ្ទាល់ចំពោះបណ្តឹង (លើកចោលបណ្តឹង ច្រានចោលការទាមទារ ឬទទួលស្គាល់ការទាមទារ)។ ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខបានបដិសេធចោលសាលដីកា ដោយហេតុថា សាលដីកាដើមនោះមានកំហុសក្នុងការអនុវត្ត ឬបកស្រាយច្បាប់ ឬ បទដ្ឋានគតិយុត្តិផ្សេងទៀត ចំពោះរឿងក្តីនោះបានដោយកែតម្រូវការរអនុវត្ត ឬបកស្រាយច្បាប់ ឬបទដ្ឋានគតិយុត្តិនោះអោយបានត្រឹមត្រូវប៉ុណ្ណោះ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ តុលាការនៃ បណ្តឹងសាទុក្ខ នឹងច្រានចោលបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ហើយសម្រេចដោយខ្លួនឯង ទទួលស្គាល់ ឬ ច្រានចោលការទាមទារ។

ម្យ៉ាងទៀត ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលសាលដីកាដើម ដោយហេតុថារឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ (មាត្រា៣០០ កថាខណ្ឌទី ២) ប្រសិនបើសាលក្រមនៃការជំនុំជម្រះលើកទី ១ លើកចោលបណ្តឹង តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងឧទ្ធរណ៍ ហើយប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ បានចេញសាលក្រមសម្រេចអង្គសេចក្តីវិញ តុលាការនៃបណ្តឹងសាទុក្ខត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះនឹងត្រូវលើកចោលបណ្តឹងដោយខ្លួនឯង។[38]

## កថាភាគទី ៣ ៖ បណ្តឹងជំទាស់

### ១.អត្ថន័យនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យដែលភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការដែលធ្វើឲ្យខូចផលប្រយោជន៍របស់ខ្លួន ជាដីកាសម្រេចដែលបានបញ្ញត្តិទុកក្នុងច្បាប់ថាអាចធ្វើបណ្តឹងជំទាស់បានចំពោះដីកាសម្រេចដែលជាសេចក្តីសម្រេចមិនមែនជាសាលក្រម ឬសាលដីកា ហើយតុលាការនៃបណ្តឹងជំទាស់គឺជាតុលាការនៃ**បណ្តឹងជំទាស់ (សាលាឧទ្ធរណ៍ ឬតុលាការកំពូល)** ហេតុដូចនេះ ត្រង់ចំណុចនោះខុសពីការ**តវ៉ា**

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០០

ដែលជាឧបាស្រ័យចំពោះដីកាសម្រេចទៅ**តុលាការសាមី**។ រយៈពេលប្តឹងជំទាស់មានរយៈពេល **១សប្តាហ៍** គិតចាប់ពីថ្ងៃដែលបានទទួលដីកាសម្រេចនោះ។

**២. មូលហេតុនៃបណ្តឹងជំទាស់**

មូលហេតុនៃបណ្តឹងជំទាស់ គឺដោយសាតែភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការដែលជាប្រភេទនៃដីកាសម្រេចដែលចេញដោយសាលាដំបូង ឬនៅពេលដែលភាគីទទួលឥទ្ធិពលដែលនាំឱ្យខូចផលប្រយោជន៍ដល់សិទ្ធិរបស់ខ្លួនដោយសារតែដីកាសម្រេចនោះ។

**៣. របៀបបណ្តឹងជំទាស់**

ដើម្បីប្តឹងជំទាស់បាន គឺតម្រូវឱ្យភាគីត្រូវដាក់ពាក្យបណ្តឹងជាមុនសិនដែលត្រូវឆ្លងកាត់នូវដំណើរការនីតិវិធីនៃបណ្តឹងជំទាស់ដូចជាការធ្វើបណ្តឹងជំទាស់ និងនីតិវិធីនៃការជម្រះក្តីលើបណ្តឹងជំទាស់ដែលត្រូវរៀបរាប់ដូចខាងក្រោមនេះ៖

**៣.១. ការធ្វើបណ្តឹងជំទាស់**

ផលប្រយោជន៍ក្នុងការប្តឹងជំទាស់ ត្រូវបានទទួលស្គាល់ចំពោះភាគី ឬតតិយជនដែលបានបាត់បង់នូវផលប្រយោជន៍ដោយសារដីកាសម្រេចដើម។ បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ០១ សប្តាហ៍ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីការសម្រេច។[39] អំឡុងពេលនេះមិនអាចពន្យារបានទេ។ ដើម្បីធ្វើបណ្តឹងជំទាស់ គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើម ក៏ប៉ុន្តែប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះក៏បណ្តឹងជំទាស់នោះមិនបែរជាគ្មានសុពលភាពដែរ។

ក្នុងករណី ដែលពាក្យបណ្តឹងជំទាស់មិនមានសរសេរអំពីមូលនោះដើមបណ្តឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងជំទាស់នោះទៅតុលាការនៃបណ្តឹងជំទាស់ក្នុងអំឡុងពេល ០២ សប្តាហ៍គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។[40] នៅពេលទទួលបានពាក្យបណ្តឹជំទាស់ តុលាការដើមត្រូវផ្ញើពាក្យបណ្តឹងជំទាស់និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ឱ្យបានឆាប់រហ័ស។ ប្រសិនបើភាគីនោះមិនធ្វើការកែតម្រូវទៅតាមការបង្គាប់របស់តុលាការទេនោះ តុលាការនឹងត្រូវលើកចោលពាក្យបណ្តឹងជំទាស់នោះដោយដីកាសម្រេច។[41]

ចំពោះដីការម្រេចដែលជាសេចក្តីសម្រេចមិនមែនសាលក្រម ឬសាលដីកាហើយតុលាការដែលជំនុំជម្រះលើបណ្តឹងជំទាស់ ហៅថា **តុលាការនៃបណ្តឹងជំទាស់** (សាលាឧទ្ធរណ៍ ឬតុលាការកំពូល)។ ដីកាសម្រេចដែលអាចប្តឹងជំទាស់បាន លុះត្រាតែមានបញ្ញាត្តិក្នុងច្បាប់ ដូចជាដីកាសម្រេចលើកចោលបណ្តឹងក្នុងករណីភាគីមិនកែតម្រូវជាអាទិ៍ ប៉ុន្តែដីកាសម្រេចដែលលើកបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ។

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០០ កថាខណ្ឌទី១

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០០ កថាខណ្ឌទី២

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៤ កថាខណ្ឌទី១

ការដាក់ពាក្យបណ្តឹង និងការជំនុំជម្រះលើបណ្តឹងជំទាស់ ត្រូវអនុលោមទៅតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និងនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចដែលត្រូវបានធ្វើឡើងដោយសាលាដំបូងដូចនេះបញ្ញត្តិនៃមាត្រា *២៦៣ (ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍), មាត្រា ២៦៥ កថាខណ្ឌទី ២ (ការសរសេរពាក្យបណ្តឹងឧទ្ធរណ៍), មាត្រា ២៦៨ (ការលើកចោលពាក្យបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់), មាត្រា ២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ) និង មាត្រា ២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី១)* ត្រូវបានយកមកអនុវត្តផងដែរក្នុងករណីនៃនីតិវិធីតុលាការនៃបណ្តឹងជំទាស់។

លើកលែងតែករណីមានបញ្ញត្តិផ្ទុយនឹងលក្ខណៈនៃបណ្តឹងជំទាស់ដូចជា អំឡុងពេលប្តឹងជំទាស់ ការទាញហេតុផលដោយឆន្ទានុសិទ្ធជាអាទិ៍។ ក្រៅពីនេះបញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និងនីតិវិធីទាក់ទងការជំនុំជម្រះលើបណ្តឹងសាទុក្ខត្រូវយកមកអនុវត្តដូចគ្នា ចំពោះការជំនុំសជម្រះលើបណ្តឹងជំទាស់ក្នុងករណីបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលត្រូវធ្វើឡើងដោយសាលាឧទ្ធរណ៍ ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ លើកលែងតែបញ្ញត្តិដែលមានភាពផ្ទុយនឹងលក្ខណៈបណ្តឹងជំទាស់។ ដូចនេះបណ្តឹងជំទាស់ត្រូវដាក់ទៅតុលាការកំពូលតាមមាត្រា ២៨៣ កថាខណ្ឌទី១ ហើយបណ្តឹងជំទាស់នោះអាចធ្វើទៅបានលុះត្រាតែ មានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលជះឥទ្ធិពលលើដីកាសម្រេចដើមប៉ុណ្ណោះ។

### ៣.២. អំឡុងពេលសម្រាប់ប្តឹងជំទាស់

បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១ សប្តាហ៍ អំឡុងពេលនេះគិតចាប់ពីថ្ងៃដែលបានទទួលអំពីដីកាសម្រេច។

អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌខាងលើនេះ មិនអាចពន្យាពេលបានឡើយ។[42] ប៉ុន្តែក្នុងករណីច្បាប់កំណត់ជាក់លាក់ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងរយៈពេល ០២ សប្តាហ៍ ដូចជាបណ្តឹងជំទាស់ចំពោះការលើកចោលសេចក្តីសម្រេច ដូចមានចែងក្នុងមាត្រា ៥៤៤(បណ្តឹងទំទាស់ចំពោះសេចក្តីសម្រេចលើកចោល)។

## ៤. នីតិវិធីនៃការជំនុំជម្រះទៅលើបណ្តឹងជំទាស់

### ៤.១ ភាគីនៃបណ្តឹងជំទាស់

ចំពោះនីតិវិធីបណ្តឹងជំទាស់ មិនមែនធ្វើតាមវិធីតទល់គ្នារវាងភាគីនៅគ្រប់ពេលវេលា។ នៅក្នុងករណីដែលចំណុចដែលត្រូវបានវិនិច្ឆ័យតាមរយៈដីកាសម្រេច ដែលជាកម្មវត្ថុនៃបណ្តឹងជំទាស់នោះ ត្រូវតែមានវត្តមានមានបុគ្គលនោះបានចូលរួមនៅក្នុងនីតិវិធីទាំងអស់ នៃការប្តឹងជំទាស់នោះ។

ឧទាហរណ៍៖ ដើមបណ្តឹងបានដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចបង្គាប់ឱ្យចុងចម្លើយប្រគល់ឯកសារដែលចុងចម្លើយកាន់កាប់ ហើយតុលាការចេញដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារដោយទទួលស្គាល់ពាក្យសុំនោះប្រសិនបើចុងចម្លើយប្តឹងជំទាស់ចំពោះដីកាសម្រេចនោះចុងចម្លើយត្រូវយកដើមចោទមកធ្វើជាភាគីម្ខាងទៀត។ រីឯប្រសិនបើចុងចម្លើយប្តឹងជំទាស់ចំពោះដីកាសម្រេចច្រានចោលពាក្យសុំដើមចោទនោះត្រូវយក

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៣

ចុងចម្លើយមកធ្វើជាភាគីម្ខាងទៀតវិញ។ ក៏ប៉ុន្តែមានករណីខ្លះដែលសេចក្តីសម្រេចធ្វើឡើងតាមរយៈដីកាសម្រេច តែគ្មានបុគ្គលណាពាក់ព័ន្ធនិងផលប្រយោជន៍ទេដីកាសម្រេចដាក់ពិន័យស៊ីវិលចំពោះតតិយជនដែលមិនគោរព តាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារនៃការជំនុំជម្រះលើកទី ១ ការវិនិច្ឆ័យ និង ខ្លឹមសារនៃសេចក្តីសម្រេចចុងក្រោយ ត្រូវអនុលោម*ទៅតាមករណីនៃការជំនុំជម្រះបណ្តឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់*។

### ៤.២. បណ្តឹងជំទាស់ និងការបង្អាក់នូវអានុភាពនៃដីកាសម្រេចដើម

ដីកាសម្រេចដែលមានលក្ខណៈខុសគ្នាពីសាលក្រម ឬសាលដីកានោះ គឺជាគោលការណ៍ដីកាសម្រេចនឹងបង្កើតនូវអានុភាពចាំបាច់ដើម្បីសម្រេចនូវខ្លឹមសារនៃការសម្រេចសេចក្តីដូចជាអានុភាពអនុវត្ត និង អានុភាពបង្កើតឱ្យមានទំនាក់ទំនងគតិយុត្តិជាដើមដោយការជូនដំណឹងដែលគេអាចទទួលស្គាល់បានថាសមរម្យមួយតែប៉ុណ្ណោះ ក៏ប៉ុន្តែពេលដែលមានបណ្តឹងជំទាស់អានុភាពនៃដីកាសម្រេចដើមដែលបានកើតឡើងម្តងរួចហើយត្រូវបានបង្អាក់។

### ៤.៣. នីតិវិធីជំនុំជម្រះនៃបណ្តឹងជំទាស់

ដោយហេតុថា នីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់ត្រូវបញ្ចប់ដោយដីកាសម្រេចតុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានថា តើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើការទាញហេតុផលផ្ទាល់មាត់។ នៅក្នុងករណីដែលមិនទាន់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេតុលាការនៃបណ្តឹងជំទាស់ អាចសួរម្ចាស់បណ្តឹងជំទាស់ ឬ បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងផលប្រយោជន៍ដែលទាក់ទងនឹងបណ្តឹងជំទាស់នោះបាន។[43] ក្នុងការជំនុំជម្រះបណ្តឹងជំទាស់ភាគី **អាចដាក់អង្គហេតុថ្មី និងភស្តុតាងថ្មីដូចជាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។** សេចក្តីសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ គឺជាដីកាសម្រេចដែលយកខ្លឹមសារនៃដីកាសម្រេចនោះត្រូវអនុលោមទៅតាមសាលដីកាចុងក្រោយនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប៉ុន្តែចំពោះបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ ការវិនិច្ឆ័យ និងខ្លឹមសារនៃសេចក្តីសម្រេចចុងក្រោយដែលត្រូវអនុលោមទៅតាមករណី នៃការជំនុំជម្រះបណ្តឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់។[44]

## ៥. ប្រភេទដីកាសម្រេចដែលអាចប្តឹងជំទាស់បាន

ជាទូទៅ ដីកាសម្រេចទាំងឡាយដែលធ្វើឡើងដោយតុលាការអំពីចំណុចដែលបានក្លាយទៅជាបញ្ហាក្នុងដំណើរការនៃនីតិវិធីរហូតដល់ចេញសាលក្រម ឬសាលដីកាចុងក្រោយត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ជាមួយនឹងសាលក្រម ឬសាលដីកាចុងក្រោយដោយបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ។ ក៏ប៉ុន្តែប្រសិនបើគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនៃនីតិវិធី ឬ ដែលកើតឡើងដោយសារនីតិវិធីនៃការជំនុំជម្រះសុទ្ធតែដាក់ឲ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះការណ៍នេះនឹងរឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើ

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៦ កថាខណ្ឌទី២

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៤

ឱ្យមានការយឺតយ៉ាវក្នុងការជំនុំជម្រះរឿងក្ដីនោះដោយសារតែបញ្ហាដែលកើតចេញពីនោះ។

ដូច្នេះជាការល្អ ប្រសិនបើឲ្យបញ្ហាដែលមិនសូវពាក់ព័ន្ធទៅនឹងអង្គសេចក្ដីនៃរឿងក្ដីហើយដែលត្រូវការសម្រេចឱ្យឆាប់ អាចដោះស្រាយបានតាមនីតិវិធីសង្ខេបដែលអាចធ្វើឡើងដាច់ដោយឡែកនោះ។ ម៉្យាងវិញទៀតក្នុងករណីដែលការបញ្ចប់នីតិវិធីសង្ខេបដោយដីកាសម្រេច ឬ ក្នុងករណីដែលតុលាការចេញដីកាសម្រេចចំពោះតតិយជនវាចាំបាច់ដែលត្រូវបើកផ្លូវឲ្យតតិយជនជាដើមនោះ ដែលមានបំណងចង់ធ្វើបណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចនោះអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន។ ដូច្នេះក្នុងករណីដែលទទួលស្គាល់ថាមានការចាំបាច់ក្រមនីតិវិធីរដ្ឋប្បវេណីនេះមានចែងថាអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចបាន។

បណ្ដឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិចែងក្នុងច្បាប់។[45] ជាទូទៅដីកាសម្រេចទាំងឡាយណា ដែលធ្វើឡើងដោយតុលាការអំពីចំណុចដែលបានក្លាយទៅជាបញ្ហាក្នុងដំណើរការនៃនីតិវិធីហូតចេញសាលក្រម ឬសាលដីកាចុងក្រោយត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ជាមួយសាលក្រម ឬសាលដីកាចុងក្រោយដោយដើមបណ្ដឹងឧទ្ធរណ៍ ឬដើមបណ្ដឹងសាទុក្ខ។[46] ប៉ុន្តែប្រសិនបើគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនីតិវិធី ឬដែលកើតឡើងដោយនីតិវិធីជំនុំជម្រះសុទ្ធតែដាក់ពាក្យឲ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះ ករណីនេះនឹងរឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើឲ្យមានការយឺតយូរក្នុងការជំនុំជម្រះរឿងក្ដីនោះដោយសារតែបញ្ហាដែលកើតឡើងនោះ។

ដូច្នេះជាការល្អប្រសើបើឲ្យបញ្ហាដែលមិនសូវពាក់ព័ន្ធនឹងអង្គសេចក្ដីនៃរឿងក្ដី ហើយដែលត្រូវសម្រេចឲ្យឆាប់អាចដោះស្រាយបាន ដោយនីតិវិធីសង្ខេបដែលអាចធ្វើឡើងដាច់ដោយឡែកនោះ។ ម៉្យាងវិញទៀតក្នុងករណីដែលបញ្ចប់នីតិវិធីដោយដីកាសម្រេច ឬក្នុងករណីដែលតុលាការចេញដីកាសម្រេចចំពោះតតិយជនក្រៅភាគី វាជាការចាំបាច់ដែលត្រូវបើកផ្លូវឲ្យតតិយជនជាដើមនោះដែលចង់ធ្វើឧបាស្រ័យចំពោះដីកាសម្រេចនោះមានការចាំបាច់ ក្រមនីតិវិធីរដ្ឋប្បវេណីនេះមានចែងថាអាចប្ដឹងជំទាស់ចំពោះដីកានោះបាន។

### ៦. វិសាលភាពនៃបណ្ដឹងជំទាស់

ក្នុងកថាខណ្ឌនេះយើងនឹងធ្វើការសិក្សាអំពីចំណុចនៃការប្ដឹងជំទាស់អំពីដីកាសម្រេចនៃសាលាឧទ្ធរណ៍ និងការប្ដឹងជំទាស់ចំពោះដីកាសម្រេចចំពោះចៅក្រមទទួលបញ្ហា ឬ ការប្រគល់សិទ្ធិ (ចៅក្រមទទួលបន្ទុក)។

#### ៦.១. ការប្ដឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍

ទោះជាការប្ដឹងជំទាស់អាចធ្វើឡើងទៅតាមការកំណត់ក្នុងបញ្ញត្តិច្បាប់ក៏ដោយ ប៉ុន្តែចំពោះដីកាសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្ដឹងជំទាស់ដែល តុលាការនៃបណ្ដឹងជំទាស់នោះចេញមិនអាចប្ដឹងជំទាស់ទៀតបានឡើយ។[47]

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩ កថាខណ្ឌទី ២

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦២

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣

ផ្ទុយទៅវិញ ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើឡើងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ អាចប្ដឹងជំទាស់ទៅតុលាការកំពូលបានប្រសិនបើមានបញ្ញត្តិច្បាប់អនុញ្ញាតឲ្យប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះ។ បណ្ដឹងជំទាស់នេះ គឺជាបណ្ដឹងជំទាស់ទៅតុលាការកំពូលក្នុងករណីនេះ គឺស្រដៀងគ្នាទៅនឹងការអនុវត្តចំពោះបណ្ដឹងសាទុក្ខចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១។[48] ដោយហេតុនោះ បញ្ញត្តិស្ដីពីបណ្ដឹងសាទុក្ខ និងនីតិវិធីដែលទាក់ទងនឹងបណ្ដឹងជំទាស់ទាំងនោះលើកលែងតែករណីដែលបញ្ញត្តិជំនុំជម្រះលើកទី ១ និងនីតិវិធីដែលទាក់ទងនឹងបណ្ដឹងជំទាស់ទាំងនោះលើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្ដឹង ឬនីតិវិធីនោះ។

*ហេតុដូច្នេះនៅក្នុងករណីនេះបណ្ដឹងជំទាស់នេះអាចធ្វើទៅបានដោយយកមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ។*

*ម៉្យាងវិញទៀត មានករណីខ្លះដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចក្នុងនាមជាតុលាការនៃការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍។ ក្នុងករណីនេះភាពអាចឬមិនអាចប្ដឹងជំទាស់ជំទាស់ មានករណីខ្លះដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចក្នុងនាមជាតុលាការនៃជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ អាស្រ័យទៅលើការអនុវត្តបញ្ញត្តិនៃមាត្រា ២៥៩ (ប្រភេទបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់)ហេតុដូចនេះហើយលើកលែងតែបញ្ញតិច្បាប់ដែលអនុញ្ញាតឲ្យប្ដឹងជំទាស់ ចំណែកឯភាគីដែលបាត់បង់ផលប្រយោជន៍មិនអាចប្ដឹងជំទាស់បានទៀតឡើយបើច្បាប់មិនអនុញ្ញាតដូចជា បណ្ដឹងជំទាស់នៃដីកាសម្រេចរបស់សាលាឧទ្ធរណ៍។*

### ៦.២. បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬការប្រគល់សិទ្ធិ

ក្នុងករណីដែលភាគីមិនសុខចិត្តទៅនឹងដីកាសម្រេចដែលធ្វើឡើងដោយ ចៅក្រមដែលបានទទួលការបញ្ជា ឬចៅក្រមដែលទទួលការប្រគល់សិទ្ធិ (ចៅក្រមទទួលបន្ទុកជាបឋមវាជាការសមរម្យដែលត្រូវដាក់ដីកសម្រេចរបស់តុលាការ។ ដូច្នេះបើភាគីដែលមិនយល់ស្របចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬចៅក្រមដែលទទួលការប្រគល់សិទ្ធិ **អាចប្ដឹងតវ៉ាទៅតុលាការដែលទទួលបណ្ដឹង** ដែលក្នុងករណីដែលច្បាប់អនុញ្ញាតឲ្យប្ដឹងជំទាស់បានប្រសិនបើដីការសម្រេចនោះ ជាដីកាសម្រេចរបស់តុលាការដែលទទួលបណ្ដឹង ហើយចំពោះដីកាសម្រេចអំពីការតវ៉ានោះតែប៉ុណ្ណោះអាចប្ដឹងជំទាស់បាន។ ក៏ប៉ុន្តែក្នុងករណីដែលតុលាការដែលទទួលបណ្ដឹង ជាតុលាកំពូល ឬសាលាឧទ្ធរណ៍ភាគីអាចប្ដឹងតវ៉ាបានលុះត្រាតែច្បាប់បានអនុញ្ញាតឲ្យប្ដឹងជំទាស់ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់សាលាដំបូង។

ប៉ុន្តែក្នុងករណីនេះ ប្រសិនបើតុលាការដែលទទួលបណ្ដឹងជាតុលាការកំពូលចំពោះដីកាសម្រេចអំពីការតវ៉ាមិនអាចប្ដឹងជំទាស់បានដោយសារគ្មានតុលាការជាន់ខ្ពស់ខាងតុលាការកំពូល។ ចំពោះការតវ៉ាដែលបានកំណត់នៅក្នុងមាត្រា ៣០២ ប្រសិនបើដីកាសម្រេចដែលជាកម្មវត្ថុនៃការតវ៉ានោះត្រូវបានធ្វើឡើងដោយតុលាការ

---

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៤ កថាខណ្ឌទី២

ដែលទទួល បណ្តឹងវិញ ត្រូវក្លាយទៅជាកម្មវត្ថុនៃជំទាស់វិញ។ហេតុដូចនេះ ការតវ៉ានោះត្រូវធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ៣០៣ (**០១សប្តាហ៍**) ចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច។

អំឡុងពេលនេះមិនអាចពន្យាពេលបានឡើយ ដើម្បីធ្វើបណ្តឹងជំទាស់បាន ត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការជាដើម។ នៅក្នុងពាក្យបណ្តឹងជំទាស់គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬផ្លាស់ប្តូរនូវដីកាសម្រេចដើម ក៏ប៉ុន្តែប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះក៏បណ្តឹងជំទាស់នោះមិនប្រែជាគ្មានសុពលភាពដែរ។ ក្នុងករណីដែលពាក្យបណ្តឹងជំទាស់ មិនមានសរសេរអំពីមូលហេតុនោះទេដើមបណ្តឹងជំទាស់ គប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់នោះទៅតុលាការនៃបណ្តឹងជំទាស់ ក្នុង**អំឡុងពេល ០២ សប្តាហ៍** គិតពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។ នៅពេលទទួលបានពាក្យបណ្តឹងជំទាស់តុលាការដើមត្រូវផ្ញើពាក្យបណ្តឹងជំទាស់និងសំណុំរឿង ទៅតុលាការនៃបណ្តឹងជំទាស់ ឲ្យបានឆាប់រហ័ស។ ពេលដែលបានទទួលនូវការផ្ញើតុលាការនៃបណ្តឹងជំទាស់ត្រូវពិនិត្យពាក្យបណ្តឹងជំទាស់នោះ ហើយប្រសិនបើមានចំណុចណាដែលមិនស្របនឹងទម្រង់ នោះត្រូវបង្គាប់ឱ្យដើមបណ្តឹងជំទាស់ធ្វើការកែតម្រូវ។ ប្រសិនបើភាគី នោះមិនធ្វើការកែតម្រូវតាមការបង្គាប់របស់តុលាការនោះទេ តុលការត្រូវលើកចោលពាក្យបណ្តឹងជំទាស់នៃដោយដីកាសម្រេច។

# ជំពូកទី ៣
# ប្រភេទនៃបណ្តឹងឧបាស្រ័យក្នុងនីតិ
# វិធីចាត់ចែងរក្សាការពារ

# ជំពូកទី៣

# ប្រភេទនៃបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ

បណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ សំដៅលើបណ្តឹងមិនសុខចិត្ត ឬ បណ្តឹងប្រឆាំងទៅនឹងសេចក្តីសម្រេចចាត់ចែងរក្សាការពារ។ បណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពាររួមមានៈ **ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ការលុបចោលដីកាសម្រេចរក្សាការពារ** និង**បណ្តឹងជំទាស់**។[49]

## កថាខណ្ឌទី ១ ៖ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ គឺជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យទៅតុលាការដើម(តុលាការចេញដីកាសម្រេចរក្សាការពារ) ដែលធ្វើឡើងដោយកូនបំណុល ប្រឆាំងទៅនឹងដីកាសម្រេចរក្សាការពារដែលបានចេញរួចហើយ ។[50]

### ១. បុគ្គលដែលអាចដាក់ពាក្យសុំតវ៉ា

ក្នុងនីតិវិធីនៃការសម្រេចសេចក្តីអំពីរក្សាការពារ អ្នកដាក់ពាក្យសុំឲ្យតុលាការចេញដីកាសម្រេចចាត់ចែងរក្សាការពារហៅថា ម្ចាស់បំណុល រីឯភាគីម្ខាងទៀតហៅថា កូនបំណុល។[51]

ក្រោយពេលតុលាការបានចេញសេចក្តីសម្រេចអំពីការចាត់ចែងរក្សាការពារ ករណីកូនបំណុលមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ កូនបំណុលពុំអាចដាក់ពាក្យបណ្តឹងជំទាស់បានភ្លាមៗនោះទេ ប៉ុន្តែអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារបាន ។[52]

ឧទាហរណ៍ លោក ក បានដាក់ពាក្យសុំទៅសាលាដំបូងខេត្តព្រះសីហនុឱ្យចេញដីកាសម្រេចចាត់ចែងរក្សាការពារលើដីរបស់លោកស្រី ខ ។ ករណីសាលាដំបូងខេត្តព្រះសីហនុ ចេញដីកាសម្រេចចាត់ចែងរក្សាការពារនោះលោកស្រី ខ ដែលជាកូនបំណុល មានសិទ្ធិដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារនោះបាន។

ការតវ៉ានេះ គឺជាឱកាសមួយដែលផ្តល់ឱ្យកូនបំណុលស្នើសុំទៅតុលាការធ្វើការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃដីកាសម្រេចចាត់ចែងរក្សាការពារដែលបានចេញរួចហើយ និងដែលប៉ះពាល់ដល់សិទ្ធិនិងផលប្រយោជន៍របស់ខ្លួន ។

### ២. នីតិវិធីពាក់ព័ន្ធនឹងពាក្យសុំតវ៉ា

ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ។[53] ឧទាហរណ៍ តុលាការដែលចេញដីកាសម្រេចរក្សាការពារ គឺសាលាដំបូងខេត្តព្រះសីហនុ នោះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ត្រូវដាក់ទៅសាលាដំបូងខេត្តព្រះសីហនុ

[49] លោក MAEDA YUTA ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់, ការធ្វើឧបាស្រ័យ,ថ្ងៃ ២៥ មេសា ឆ្នាំ ២០១៨

[50] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥០

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣១

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥០

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣៤ និងមាត្រា៥៥០

ដដែល ក្រមនីតិវិធីរដ្ឋប្បវេណីពុំបានកំណត់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការតវ៉ាចំពោះដីកាសម្រេចរក្សាការពារនោះទេ ។

ម្យ៉ាងទៀតក្រមនីតិវិធីរដ្ឋប្បវេណីក៏ មិនបានកំណត់អំពីអំឡុងពេលក្នុងការដាក់ពាក្យសុំតវ៉ានេះឡើយ នេះមានន័យថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ អាចដាក់នៅពេលណាក៏បាន ឲ្យតែដីកាសម្រេចនោះនៅមានសុពលភាពនៅឡើយ។ នៅពេលបានទទួលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ នោះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។[54] បើទោះបីជាតុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ប៉ុន្តែក៏ត្រូវកំណត់អំឡុងពេលឱ្យបានសមរម្យ និងត្រូវជូនដំណឹងដល់ភាគីអំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យនេះដើម្បីផ្តល់ឱកាសឱ្យភាគីដាក់ឯកសារសម្រាប់ការវិនិច្ឆ័យឱ្យបានគ្រប់គ្រាន់។ តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យ និងធ្វើការសម្រេចសេចក្តីអំពីការទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលដីកាសម្រេចរក្សាការពារប្រសិនបើការវិនិច្ឆ័យត្រូវបានបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។[55]

### ៣. ការសម្រេចសេចក្តីអំពីពាក្យសុំតវ៉ា

ក្រោយពីបានបញ្ចប់ការវិនិច្ឆ័យ តុលាការត្រូវចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ ហើយដីកានោះអាចជា**ការលុបចោល ផ្លាស់ប្តូរ ឬទទួលស្គាល់នូវដីកាសម្រេចរក្សាការពារ**។ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ ក្នុងករណីដែលមានភាពផ្ទុយយ៉ាច្បាស់លាស់នឹងអត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារ និងភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការចេញដីកាសម្រេចរក្សាការពារ ឬស្ថានភាពដែលមានការបារម្ភថាការខូចខាតនឹងមិនអាចសងបាន នឹងកើតមានឡើងដោយសារការអនុវត្តរក្សាការពារ ដោយតុលាការអាចដាក់លក្ខខណ្ឌឲ្យកូនបំណុលដាក់ប្រាតិភោគបាន។

ប្រសិនបើដីកាសម្រេចរក្សាការពារ មានផ្ទុកនូវចំណុចដែលត្រូវធ្វើការផ្លាស់ប្តូរ ដូចជាលក្ខខណ្ឌដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬការបន្ថែមនូវប្រាតិភោគក្នុងពេលកំណត់ណាមួយ នោះតុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ។ ផ្ទុយទៅវិញ ករណីដែលដីកាសម្រេចរក្សាការពារនោះមានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់។[56]

ចំពោះដីកាសម្រេចទាំងនោះ ត្រូវធ្វើការបញ្ជូនទៅភាគី ហើយភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ អាចប្តឹងជំទាស់បាន ។[57]

---

[54] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥២

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៣

[56] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ទំព័រ២០៣, បោះពុម្ពឆ្នាំ២០១៨

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦១

### ៤. អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

ចំពោះពាក្យសុំតវ៉ាមិនផ្អាកអានុភាពអនុវត្តនៃដីកាសម្រេចរក្សាការពារដោយស្វ័យប្រវត្តិនោះឡើយ ប៉ុន្តែតុលាការអាចចេញសេចក្តីបង្គាប់ឱ្យផ្អាកបាន។ សេចក្តីបង្គាប់ឱ្យផ្អាកនោះអាចចេញបាន លុះត្រាតែមានស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ ដែលរួមមានៈនត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារ ឬការចាត់ចែងរក្សាការពារគ្មានភាពចាំបាច់ទាល់តែសោះ ឬមានការបារម្ភថា ការអនុវត្តរក្សាការពារនាពេលខាងមុខនឹងបង្កឱ្យមានការខូចខាត ដែលមិនអាចធ្វើបដិទានបាន។ ក្នុងករណីនេះ តុលាការដែលបានចេញសេចក្តីបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬលុបចោលការចាត់ចែងការអនុវត្ត អាចបង្គាប់ឱ្យកូនបំណុលដាក់ប្រាតិភោគបាន។[58]

ម្យ៉ាងវិញទៀត ពាក្យសុំតវ៉ារបស់កូនបំណុល មានអានុភាពនាំឱ្យតុលាការឈានដល់ការសម្រេចសេចក្តីតាមរយៈការចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលអាចជាការទទួលស្គាល់ផ្លាស់ប្តូរ ឬលុបចោលនូវដីកាសម្រេចរក្សាការពារ ។[59] ជាងនេះទៅទៀត តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រង នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារបាន តាមពាក្យសុំរបស់កូនបំណុល ក្នុងករណីម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ ឬប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចរក្សាការពារ។[60]

ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ប៉ុន្តែបើយល់ឃើញថាចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ។[61]

## កថាភាគទី២. ការលុបចោលដីកាសម្រេចរក្សាការពារ

ក្រមនីតិវិធីរដ្ឋប្បវេណី មិនបានចង្អុលបង្ហាញថា ការសុំលុបចោលដីកាសម្រេចរក្សាការពារជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យនោះឡើយ ប៉ុន្តែបើយើងក្រឡេកទៅមើលនិយមន័យនៃបណ្តឹងឧបាស្រ័យ ឃើញថាការសុំលុបចោលនេះ ជាវិធីមួយដែលអនុញ្ញាតឱ្យភាគីដែលមិនសុខចិត្តនឹងការសម្រេចរបស់តុលាការស្នើសុំឱ្យមានការលុបចោលនូវសេចក្តីសម្រេចដែលបានចេញរួចហើយនោះ។[62]

### ១. បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ

ក្រមនីតិវិធីរដ្ឋប្បវេណីពុំបានកំណត់ឱ្យច្បាស់ថា ជនណាខ្លះមានសិទ្ធិស្នើសុំលុបចោលដីកាសម្រេចរក្សាការពារនោះទេ ប៉ុន្តែការដាក់ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារនេះ ជាទូទៅធ្វើឡើងដោយភាគីដែលមិន

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥១

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥១

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៥

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៦

[62] លោក សេង នាង ចៅក្រមតុលាការកំពូល,បទបង្ហាញស្តីពីបណ្តឹងឧបាស្រ័យក្នុងនីតិវិធីរដ្ឋប្បវេណី

សុខចិត្តនឹងការសម្រេចនោះ ពោលគឺ កូនបំណុល"។

ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវដាក់ទៅតុលាការដែលបានចេញដីកាសម្រេចចាត់ចែងរក្សាការពារនោះ ដោយផ្អែកលើមូលហេតុគតិយុត្តចំនួនបី រួមមានៈ ការមិនដាក់បណ្តឹងអង្គសេចក្តី ឬឯកសារដែលបញ្ជាក់ថាបានដាក់ពាក្យបណ្តឹងអង្គសេចក្តីការផ្លាស់ប្តូរស្ថានភាព និងដោយសារស្ថានភាពពិសេស។[63]

## ២. មូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ

ចំពោះការលុបចោលដីកាសម្រេចរក្សាការពារ មានភាពខុសគ្នាពីការតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារដោយហេតុថា កូនបំណុលដាក់ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារបាន ដរាបណាមានមូលហេតុដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ មូលហេតុទាំងនោះរួមមានៈ ការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីឬឯកសារដែលបញ្ជាក់ថាបានដាក់ពាក្យបណ្តឹង កាផ្លាស់ប្តូរស្ថានភាព និងដោយសារស្ថានភាពពិសេស។[64]

មូលហេតុទីមួយ គឺម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តី ឬឯកសារដែលបញ្ជាក់ថាបានដាក់ពាក្យបណ្តឹង។ ក្រោយពេលតុលាការបានចេញដីកាសម្រេចរក្សាការ ករណីមានពាក្យសុំរបស់កូនបំណុលតុលាការត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ឬឯកសារដែលបញ្ជាក់ថាបានដាក់ពាក្យបណ្តឹង (ឧទាហរណ៍ ពាក្យបណ្តឹងថតម្តង បង្កាន់ដៃបង់ពន្ធ លេខសំណុំរឿង...) ទៅតុលាការ ក្នុងអំឡុងពេលសមរម្យដែលមិនអាចតិចជាង ០២សប្តាហ៍ឡើយ។ ករណីម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹង ឬឯកសារដូចបានលើកឡើងខាងលើ ក្នុងអំឡុងពេលដែលបានកំណត់ដោយតុលាការទេនោះ ឬករណីដែលពាក្យបណ្តឹងត្រូវបានដក ឬលើកចោល តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល។[65]

ក្រៅពីមូលហេតុដូចបានលើកឡើងខាងលើ កូនបំណុលក៏អាចលើកយកមូលហេតុនៃការផ្លាស់ប្តូរស្ថានភាព ដើម្បីស្នើសុំឱ្យតុលាការលុបចោលដីកាសម្រេចរក្សាការពារបានផងដែរ។ ការផ្លាស់ប្តូរស្ថានភាពសំដៅដល់ស្ថានភាពដែលក្រោយពីចេញដីកាសម្រេចរក្សាការពារ ស្រាប់តែមានការកើតឡើងនូវអង្គហេតុឬស្ថានភាពថ្មីមួយដែលនាំឱ្យដីកាសម្រេចរក្សាការពារមានភាពមិនត្រឹមត្រូវ ដូចជាករណីដែលសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារបានរលត់ ឬគ្មានភាពចាំបាច់ក្នុងការរក្សាការពារ។ ឧទាហរណ៍កូនបំណុលបានសងប្រាក់គ្រប់ចំនួនឱ្យម្ចាស់បំណុល ឬម្ចាស់បំណុលបានចាញ់ក្តីក្នុងការជំនុំជម្រះលើកទី១ជាដើម។[66]

ជាងនេះទៅទៀត កូនបំណុលក៏អាចលើកយកមូលហេតុនៃស្ថានភាពពិសេស ដើម្បីស្នើសុំឱ្យតុលាការលុបចោលដីកាសម្រេចរក្សាការពារបានដែរ។ ស្ថានភាពពិសេស សំដៅលើស្ថានភាពដែលកូនបំណុលឬតុលាការមានការបារម្ភថា ចំពោះនូវការអនុវត្តរក្សាការពារនាពេលខាងមុខ ក្រោយពីបញ្ចប់សំណុំរឿងអង្គសេចក្តីរួចរាល់ហើយក៏ដោយ នឹងដោយសារតែមានការបង្កឱ្យមានការខូចខាតផ្សេងៗគ្រប់រូបភាពដែលមិនអាចធ្វើឱ្យការ

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៧, មាត្រា៥៥៨ និងមាត្រា៥៥៩

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៧ មាត្រា ៥៥៨ និងមាត្រា៥៥៩

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៧

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៨

បដិទានបាន។[67]

### ៣. ការសម្រេចសេចក្តីអំពីពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ

ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់ទៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ[68]។

ឧទាហរណ៍ តុលាការដែលចេញដីកាសម្រេចរក្សាការពារ គឺសាលាដំបូងខេត្តព្រៃវែង នោះពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវដាក់ទៅសាលាដំបូងខេត្តព្រៃវែងដដែល។ ក្រមនីតិវិធីរដ្ឋប្បវេណីមិនបានកំណត់អំពីអំឡុងពេលក្នុងការដាក់ពាក្យសុំលុបចោលនេះឡើយ មានន័យថា ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ អាចដាក់នៅពេលណាក៏បាន ឱ្យតែដីកាសម្រេចនោះនៅមានសុពលភាពនៅឡើយ ។ នៅពេលបានទទួលនូវពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ នោះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។[69]

បើទោះបីជាតុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ប៉ុន្តែក៏ត្រូវកំណត់អំឡុងពេលឱ្យបានសមរម្យ និងត្រូវជូនដំណឹងដល់ភាគី អំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យនេះ ដើម្បីផ្តល់ឱកាសឱ្យភាគីដាក់ឯកសារសម្រាប់ការវិនិច្ឆ័យឱ្យបានគ្រប់គ្រាន់ ។ តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យ និងធ្វើការសម្រេចសេចក្តីអំពីការទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលដីកាសម្រេចរក្សាការពារ ប្រសិនបើការវិនិច្ឆ័យត្រូវបានបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។[70]

ក្រោយពីបានបញ្ចប់ការវិនិច្ឆ័យ តុលាការត្រូវចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលបានចេញរួចហើយ ឬទទួលស្គាល់ ដោយតម្កល់ដីកាសម្រេចរក្សាការពារទុកជាបានការដដែល។ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ ក្នុងករណីដែលមានមូលហេតុដូចបានលើកឡើងនៅក្នុងចំណុចទី២ ស្តីពីមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារខាងលើ។ ផ្ទុយទៅវិញ ករណីដែលដីកាសម្រេចរក្សាការពារនោះមានភាពត្រឹមត្រូវ ហើយពាក្យសុំរបស់កូនបំណុលមិនមានមូលហេតុដូចដែលបានលើកឡើងខាងលើ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ដីកាសម្រេចរក្សាការពារនោះ។[71]

ចំពោះដីកាសម្រេចទាំងនោះ ត្រូវធ្វើការបញ្ជូនទៅភាគីទាំងអស់ ហើយនៅពេលដែលភាគីមិនមានពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់តុលាការដែលបានចេញ នោះភាគីទាំងអស់ គឺមានសិទ្ធិទៅលលើការធ្វើបណ្តឹង

---

[67] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥៩

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣៤, មាត្រា៥៥៧, មាត្រា៥៥៨ និងមាត្រា៥៥៩

[69] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦០

[70] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦០

[71] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦០

អាចប្តឹងជំទាស់បានទៅលើដីកាសម្រេចនោះ។[72]

**៤. អានុភាពនៃពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ**

ពាក្យសុំលុបចោល មិនផ្អាកអានុភាពអនុវត្តនៃដីកាសម្រេចរក្សាការពារដោយស្វ័យប្រវត្តិនោះឡើយ ប៉ុន្តែតុលាការអាចចេញសេចក្តីបង្គាប់ឱ្យផ្អាកបាន។ សេចក្តីបង្គាប់ឱ្យផ្អាកនោះអាចចេញបាន លុះត្រាតែមានស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារដែលរួមមានៈ ការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ឬឯកសារដែលបញ្ជាក់ថាបានដាក់ពាក្យបណ្តឹង ការផ្លាស់ប្តូរស្ថានភាពនិងស្ថានភាពពិសេស។ ក្នុងករណីនេះតុលាការដែលបានចេញសេចក្តីបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្តអាចបង្គាប់ឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។[73]

ម្យ៉ាងវិញទៀតពាក្យសុំលុបចោលរបស់កូនបំណុល មានអានុភាពនាំឱ្យតុលាការឈានដល់ការសម្រេចសេចក្តីតាមរយៈការចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ឬ ដីកាសម្រេចទទួលស្គាល់ដីកាសម្រេចរក្សាការពារ។ ជាងនេះទៅទៀត តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងនៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារបាន តាមពាក្យសុំរបស់កូនបំណុល ក្នុងករណីម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ ឬប្រើប្រាស់ ឬថែរក្សា គ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចរក្សាការពារ។

ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ពុំមានអានុភាពឡើយបើមិនទាន់ចូលជាស្ថាពរ ប៉ុន្តែបើយល់ឃើញថាចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ។

**កថាភាគទី៣. បណ្តឹងជំទាស់**

បណ្តឹងជំទាស់ គឺជាប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលធ្វើឡើងប្រឆាំងនឹងដីកA សម្រេចចាត់ចែងរក្សាការពាររបស់តុលាការដើម ដែលមិនទាន់ចូលជាស្ថាពរ។[74]

**១. បុគ្គលដែលអាចធ្វើបណ្តឹងជំទាស់**

នៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ បុគ្គលដែលមិនសុខចិត្តនឹងការសម្រេចសេចក្តីរបស់តុលាការអាចដាក់ពាក្យបណ្តឹងជំទាស់បាន។ ចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ មានភាពប្លែកបន្តិចពីដីកាសម្រេចផ្សេងៗទៀតត្រង់ថា កូនបំណុលមិនអាចដាក់ពាក្យបណ្តឹងជំទាស់បានភ្លាមៗនោះទេ មានន័យថាកូនបំណុលត្រូវដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារជាមុនសិន ហើយក្នុងករណីដែលតុលាការលើកចោលពាក្យសុំតវ៉ានោះ ទើបកូនបំណុលមានសិទ្ធិប្តឹងជំទាស់បាន។[75] ដោយឡែកម្ចាស់បំណុលក៏អាចប្តឹងជំទាស់នឹង

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦១

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦០

[74] លោក សេង នាង ចៅក្រមតុលាការកំពូល,បទបង្ហាញស្តីពីបណ្តឹងឧបាស្រ័យក្នុងនីតិវិធីរដ្ឋប្បវេណី ស្លាយទី៤,៧,៨និង៩

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៥០ និងមាត្រា៥៦១

សេចក្តីសម្រេចរបស់តុលាការបានផងដែរ។

ចំពោះករណីទី ១ ប្រសិន បើតុលាការបានសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងរក្សាការពារនោះម្ចាស់បំណុលអាចដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់បាន។[76]

ចំពោះករណីទី ២ ប្រសិនបើតុលាកាសម្រេចសេចក្តីអំពីពាក្យសុំតវ៉ារបស់កូនបំណុល ដោយសម្រេចលុបចោល ឬផ្លាស់ប្តូរដីកាសម្រេចចាត់ចែងរក្សាការពារ នោះម្ចាស់បំណុលមានសិទ្ធិប្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់បានផងដែរ។[77] ក្រមនីតិវិធីរដ្ឋប្បវេណីបានចង្អុលបង្ហាញអំពីដីកាសម្រេចដែលអាចប្តឹងជំទាស់បានរួមមានៈ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ ដីកាសម្រេចអំពីពាក្យសុំលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ និងដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន ជាដើម។

### ២. នីតិវិធីទាក់ទងនឹងបណ្តឹងជំទាស់

ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងនីតិវិធីចាត់ចែងរក្សាការពារ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់ទៅតុលាការដែលបានចេញសេចក្តីសម្រេចនោះ។[78] ភាគី (ម្ចាស់បំណុល ឬកូនបំណុល)ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការ ត្រូវធ្វើបណ្តឹងជំទាស់ក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនហើយអំឡុងពេលនេះមិនអាចពន្យារបានឡើយ។[79]

ក្រោយពេលទទួលបានពាក្យបណ្តឹងជំទាស់របស់ភាគី ឬ បុគ្គលផ្សេងទៀត តុលាការដើមត្រូវរៀបចំសំណុំរឿងឲ្យបានរួចស្រេចព្រមទាំងត្រូវបញ្ជូនពាក្យបណ្តឹងជំទាស់ និងសំណុំរឿងនោះទៅតុលាការនៃបណ្តឹងជំទាស់ ឱ្យបានឆាប់រហ័សបំផុត។[80] នៅពេលបានទទួលនូវពាក្យបណ្តឹងជំទាស់ តុលាការនៃបណ្តឹងជំទាស់ ត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

បើទោះបីជាតុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ប៉ុន្តែក៏ត្រូវកំណត់អំឡុងពេលឱ្យបានសមរម្យនិងត្រូវជូនដំណឹងដល់ភាគីអំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យនេះ ដើម្បីផ្តល់ឱកាសឱ្យភាគីដាក់ឯកសារសម្រាប់ការវិនិច្ឆ័យឱ្យបានគ្រប់គ្រាន់។

តុលាការអាចប្រកាសដោយភ្លាមៗ ថាបញ្ចប់ការវិនិច្ឆ័យ និងធ្វើការសម្រេចសេចក្តីអំពីការទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលដីកាសម្រេចរក្សាការពារ ប្រសិនបើការវិនិច្ឆ័យត្រូវបានបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។

[76] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៤៤

[77] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦១

[78] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០១ មាត្រា៥៣៤ និងមាត្រា៥៦១

[79] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦១

[80] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០១

### ៣. ការសម្រេចលើបណ្តឹងជំទាស់

ក្រោយពីបានបញ្ចប់ការវិនិច្ឆ័យ តុលាការនៃបណ្តឹងជំទាស់ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងជំទាស់ ដែលការសម្រេចនោះអាចជាការទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលដីកាសម្រេចចាត់ចែងរក្សាការពាររបស់តុលាការដើម។ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ ដោយតម្កល់ដីកាសម្រេចរក្សាការពាររបស់តុលាការដើមទុកជាបានការដដែល ករណីដីកាសម្រេចដែលត្រូវបានប្តឹងជំទាស់នោះមានភាពត្រឹមត្រូវ។

ប្រសិនបើ ដីកាសម្រេចចេញដោយតុលាការដើម មានផ្ទុកនូវចំណុចដែលត្រូវធ្វើការផ្លាស់ប្តូរ តុលាការនៃបណ្តឹងជំទាស់ត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ។ ផ្ទុយទៅវិញ តុលាការត្រូវចេញដីកាសម្រេចរក្សាការពារថ្មីដោយលុបចោលដីកាសម្រេចដើម ក្នុងករណីដែលមានភាពផ្ទុយយ៉ាច្បាស់លាស់នឹងអត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារ និងភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការចេញដីកាសម្រេចចាត់ចែងរក្សាការពារ ឬស្ថានភាពដែលមានការបារម្ភថាការអនុវត្តរក្សាការពារនាពេលខាងមុខនឹងបង្កឱ្យមានការខូចខាតដែលមិនអាចធ្វើបដិទានបាន ។

ក្រោយពីចេញដីកាសម្រេចលើបណ្តឹងជំទាស់រួចហើយ តុលាការនៃបណ្តឹងជំទាស់ ត្រូវធ្វើការបញ្ជូនទៅភាគី ។[81] ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ។[82]

### ៤. អានុភាពនៃបណ្តឹងជំទាស់

ពាក្យបណ្តឹងជំទាស់ មិនផ្អាកអានុភាពអនុវត្តនៃដីកាសម្រេចរក្សាការពារដោយស្វ័យប្រវត្តិនោះឡើយ ប៉ុន្តែតុលាការនៃបណ្តឹងជំទាស់អាចចេញសេចក្តីបង្គាប់ឱ្យផ្អាកបាន។ សេចក្តីបង្គាប់ឱ្យផ្អាកនោះអាចចេញបានលុះត្រាតែមានស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ ឬ មានការបារម្ភថាការអនុវត្តរក្សាការពារនាពេលខាងមុខនឹងបង្កឱ្យមានការខូចខាតផលប្រយោជន៍ ដែលមិនអាចធ្វើបដិទានបាន។ ក្នុងករណីនេះ តុលាការនៃបណ្តឹងជំទាស់ដែលបានចេញសេចក្តីបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬលុបចោលការចាត់ចែងការអនុវត្ត អាចបង្គាប់ឱ្យកូនបំណុលដាក់ប្រាតិភោគបាន។

ម្យ៉ាងវិញទៀត ចំពោះពាក្យបណ្តឹងជំទាស់មានអានុភាពនាំឱ្យតុលាការនៃបណ្តឹងជំទាស់ឈានដល់ការសម្រេចសេចក្តីតាមរយៈការចេញដីកាសម្រេចលើបណ្តឹងជំទាស់ ដែលការសម្រេចនោះអាចជាការទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលនូវដីកាសម្រេចរក្សាការពារ។ ជាងនេះទៅទៀត តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រង នៅក្នុងដីកាសម្រេចដែលលុបចោល ឬផ្លាស់ប្តូរដីកាសម្រេចរក្សាការពារបាន តាមពាក្យសុំរបស់កូនបំណុល ក្នុងករណីម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ឬប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចរក្សាការពារ។[83]

[81] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦១

[82] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩

[83] ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៦១

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាទៅលើទ្រឹស្តីគតិយុត្ត លើប្រធានបទស្តីពី "បណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ អាចធ្វើការសំយោគបានថា ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ការលុបចោល និងបណ្តឹងជំទាស់ ដែលជាប្រភេទនៃបណ្តឹងឧបាស្រ័យ មានភាពស្មុគស្មាញទាំងនីតិវិធី និងការសម្រេចសេចក្តីបានបង្ហាញឱ្យឃើញពីភាពដូចគ្នា និងភាពខុសគ្នានៃបណ្តឹងឧបាស្រ័យនេះ។ ភាពដូចគ្នា និងខុសគ្នានេះបានរំលេចឱ្យឃើញនូវចំណុចខ្វះចន្លោះចំនួន ០២ (ពីរ) គឺការសម្រេចសេចក្តីពាក់ព័ន្ធនឹងការបង្គាប់ឱ្យកូនបំណុលដាក់ប្រាតិភោគនៅពេលមានការលុបចោលដីកាសម្រេចរក្សាការពារ និងការសម្រេចសេចក្តីពាក់ព័ន្ធនឹងការបង្គាប់ឱ្យធ្វើបដិទាន ឬ បង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រង នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ។

ដោយអនុលោមតាមទ្រឹស្តីគតិយុត្ត ករណីមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និងអំពីការដែលមានការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើង តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬលុបចោលការចាត់ចែងការអនុវត្ត ដោយបង្គាប់ឱ្យកូនបំណុលដាក់ប្រាតិភោគបាន។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង គឺពុំឃើញមានសេចក្តីសម្រេចពាក់ព័ន្ធនឹងការបង្គាប់ឱ្យដាក់ប្រាតិភោគនោះឡើយ។ម្យ៉ាងវិញទៀតអនុលោមតាមទ្រឹស្តីគតិយុត្ត ករណីម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ ឬប្រើប្រាស់ ឬថែរក្សា គ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចរក្សាការពារ តុលាការអាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន ដោយបង្គាប់ឱ្យម្ចាស់បំណុល បង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រង តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សការពារបាន។

សរុបមក ថ្វីត្បិតតែនីតិវិធី និងការសម្រេចសេចក្តីលើការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ការលុបចោលដីកាសម្រេចរក្សាការពារ ឬបណ្តឹងជំទាស់ មានភាពស្មុគស្មាញក៏ពិតមែន ប៉ុន្តែការចាត់ចែងរក្សាការពារបានផ្តល់នូវគុណសម្បត្តិជាច្រើនទៅដល់ភាគីដែលមានឡើងនូវវិវាទ និងការមិនពេញចិត្តទៅលើការវិនិច្ឆ័យ និងសេចក្តីសម្រេចផ្សេងៗ ដែលបានបញ្ញត្តិទុកសិទ្ធិឱ្យភាគីដែលជាម្ចាស់បំណុល ឬកូនបំណុល ឬបុគ្គលដែលពាក់ព័ន្ធនិងការបាត់បង់ផលប្រយោជន៍មានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យទៅលើសេចក្តីសម្រេចផ្សេងៗបាន នៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ។ ដែលនីតិវិធីនៃការចាត់ចែងរក្សាការពារនេះ ធ្វើឡើងដោយក្នុងគោលបំណងមានការបារម្ភថា ការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបានចំពោះកូនបំណុល ឬមានការលំបាកណាមួយមានការប៉ះពាល់ដល់ការអនុវត្តដោយបង្ខំ ដោយសារការប្រែប្រួលមានលក្ខណៈនៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬមានគ្រោះថ្នាក់ចំពោះឋានៈនៃភាគី ដោយសារតែមានទំនាក់ទំនងនៃទំទាស់ផលប្រយោជន៍លើសិទ្ធិនៃកម្មវត្ថុនៃការអនុវត្ត នោះបុគ្គលដែលមានការបារម្ភថាខ្លួននឹងត្រូវបាត់បង់សិទ្ធិទាំងនោះ អាចធ្វើការរក្សាការពារបានទៅតាមបទបញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបាន។ តែ

ទោះជាយ៉ាងសម្រាប់ភាគីដែលមានការបាត់បង់ ឬប៉ះពាល់ទៅលើផលប្រយោជន៍ ដែលមានទាក់ទិនទៅនឹងកម្មវត្ថុនៃការសុំចាត់ចែងរក្សាការពារ មិនថាជាកូនបំណុល ឬ បុគ្គលផ្សេងៗទៀត ដែលមានការទាក់ទិនជាមួយទៅនឹងកម្មវត្ថុនៃការចាត់ចែងរក្សាការពារនោះ នៅមានសិទ្ធិដែលមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីលើការធ្វើបណ្តឹងឧបាស្រ័យទៅលើសេចក្តីសម្រេច នៃការចាត់ចែងរក្សាការពារនោះ ដោយអាចធ្វើការប្តឹងតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ និងអាចធ្វើបណ្តឹងឧបាស្រ័យតាមរយៈបណ្តឹងជំទាស់ ទៅលើដីកាសម្រេចលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ប៉ុន្តែសម្រាប់ដីកាសម្រេចទៅលើពាក្យបណ្តឹងជំទាស់នៃដីកាសម្រេច មិនអាចធ្វើបណ្តឹងឧបាស្រ័យបានទៀតនោះទេ តែក្នុងករណីមានកំហុសនីតិវិធី ឬត្រង់ចំណុចណាមួយភាគី ឬបុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍ អាចប្រើប្រាស់នីតិវិធីបណ្តឹងផ្សេងបាន ក្រៅពីបណ្តឹងឧបាស្រ័យទៅលើដីកាសម្រេចនៃបណ្តឹងជំទាស់នោះបាន។

# អនុសាសន៍

# អនុសាសន៍

ជាការផ្តល់យោបល់បន្តិតបន្តួចរបស់យើងខ្ញុំ បន្ទាប់ពីបានបញ្ចប់ការសិក្សាអំពីបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារ ក្នុងរយៈពេលកន្លងមកនេះ យល់ឃើញថាបណ្តឹងឧបាស្រ័យក្នុងនីតិវិធីចាត់ចែងរក្សាការពារនេះ មានលក្ខណៈដូចគ្នាទៅនឹងបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ផងដែរ។ ដែលជាការយល់ឃើញរបស់យើងខ្ញុំផ្ទាល់យល់ថា ដោយបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ ប្រើប្រាស់នៅក្នុងនីតិវិធីនៃបណ្តឹងទូទៅ ដែលការធ្វើបណ្តឹងនេះឡើង ដោយការមិនពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់តុលាការ ដែលមានដូចជា សាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចផ្សេងៗ ដែលបានបើកសិទ្ធិក្នុងការធ្វើបណ្តឹងតាមរយៈការចែងកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែសម្រាប់នៅក្នុងនីតិវិធីចាត់ចែងរក្សាការពារវិញដែរលនោះ ក្រមនីតិវិធីរដ្ឋប្បវេណីបានធ្វើការកំណត់អំពីសិទ្ធិរបស់ភាគី ឬបុគ្គលពាក់ព័ន្ធផលប្រយោជន៍ និងលក្ខខណ្ឌដែលមានសិទ្ធិក្នុងធ្វើបណ្តឹងឧបាស្រ័យនៃនីតិវិធីចាត់ចែងរក្សាការពារនេះ ទៅលើសេចក្តីសម្រេចផ្សេងៗរបស់តុលាការនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារដែលបណ្តឹងទាំងនោះរួមដូចជា ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ការលុបចោលដីកាសម្រេចរក្សាការពារ និងបណ្តឹងជំទាស់។

មួយវិញទៀតយើងខ្ញុំយល់ឃើញថាទាក់ទងទៅនិង នីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី ជាពិសេសត្រង់ការចាត់ចែងរក្សាការពារ។ ដោយនៅត្រង់ចំណុចនេះមានទាំងការសុំរក្សាការពារដើម្បីការពារផលប្រយោជន៍សម្រាប់ការអនុវត្តដោយបង្ខំ និងការតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែលចេញដោយតុលាការ ដែលមានការប៉ះពាល់ផលប្រយោជន៍របស់បុគ្គលដែលមានការពាក់ព័ន្ធជាមួយកូនបំណុលនោះ មិនទាន់មានការយល់ដឹងច្បាស់អំពីការការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួននោះបាន ដូច្នេះទើបយើងខ្ញុំសូមជូនអនុសាសន៍បន្តិចបន្តួចដូចខាងក្រោម៖

- គួរប្បីចូលរួមបង្កើន និងពង្រីកការផ្សព្វផ្សាយអំពីប្រព័ន្ធច្បាប់ឱ្យបានច្រើនជាងមុន អំពីរាល់កិច្ចនីតិវិធីនៃក្រមនីតិវិធីរដ្ឋប្បវេណី ជាពិសេសនោះ ការការពារសិទ្ធិ និងផលប្រយោជន៍ដែលបានបាត់បង់តាមរយៈការប្រើប្រាស់នីតិវិធីចាត់ចែងរក្សាការពារនេះ ចំពោះកូនបំណុល និងបុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយកម្មវត្ថុនៃការចាត់ចែងរក្សាការពារ។
- ជួយជម្រុញ និងបន្តខិតខំបង្កើតឱ្យមានតុលាការជំនាញរបស់ខ្លួន តាមផ្នែកនីមួយៗ ដើម្បីទទួលបានការជឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋជាងនេះ។

សម្រាប់នីតិវិធីចាត់ចែងរក្សាការពារ នាពេលបច្ចុប្បន្នប្រជាពលរដ្ឋបានប្រើប្រាស់ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់មេធាវី ចំពោះការដាក់ពាក្យសុំរក្សាការពារ ឬ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ បណ្តឹងជំទាស់ ឬ ប្រភេទឧបាស្រ័យទូទៅដែលធ្វើការប្តឹងទៅកាន់តុលាការជាន់ខ្ពស់ដែលមេធាវីជាអ្នកដើរតួជំនួសឱ្យភាគី ឬ កូនបំណុល ម្ចាស់បំណុល ឬ បុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍ បានជួយដល់ដំណើរការនីតិវិធីនិងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋផងដែរ។

ទាំងនេះ គ្រាន់តែជាមតិយល់ឃើញរបស់ក្រុមយើងខ្ញុំតែប៉ុណ្ណោះ ប៉ុន្តែប្រសិនមានការជួយពង្រីកការយល់ដឹងរបស់ប្រជាពលរដ្ឋបាននោះ ប្រជាពលរដ្ឋអាចមានការយល់ដឹងអំពីការការពារសិទ្ធិរបស់ខ្លួនបានល្អប្រសិនជាងនេះ។

# ឯកសារយោង

# ឯកសារយោង

**១.ក្រម**

-ក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

**២.សៀវភៅ បទបង្ហាញ និងឯកសារផ្សេងៗ**

-សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ក្រសួងយុត្តិធម៌ ភាគ១ និងភាគ២ បោះពុម្ពឆ្នាំ ២០០៨។

-បទបង្ហាញស្តីពីការរក្សាការពារក្នុងរឿងរដ្ឋប្បវេណី ផ្នែកទី៤ ដោយលោក MEADA YUTA ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨)

-បទបង្ហាញស្តីពីបណ្តឹងឧបាស្រ័យក្នុងនីតិវិធីរដ្ឋប្បវេណី ដោយលោក សេង នាង ចៅក្រមតុលាការកំពូល (ឆ្នាំសិក្សា ២០១៩-២០២០)

-បទបង្ហាញស្តីពីការចាត់ចែងរក្សាការពារ ដោយលោក កេត សុជាតិ ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ (ឆ្នាំសិក្សា ២០១៩ ២០២០)

-សារណាបញ្ចប់ការសិក្សាឆ្នាំ២០១៩ (បណ្តឹងឧបាស្រ័យ)

-សារណាបញ្ចប់ការសិក្សាឆ្នាំ២០២០ (នីតិវិធីនៃការចាត់ចែងរក្សាការពារក្នុងសំណុំរឿងរដ្ឋប្បវេណី)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១

# ពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..៣៨០/២០..

សាលាដំបូងខេត្តព្រះសីហនុ
ថ្ងៃ ០៤ ខែ ៥ ឆ្នាំ ២០២០
ម៉ោង: ១០.៣០

## ពាក្យសុំឧទ្ធរណ៍ចំពោះ

## ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

**កូនបំណុល ៖**

ក្រុមហ៊ុន ដែលមានទីស្នាក់ការចុះបញ្ជីស្ថិតនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានលោក ជាអភិបាលក្រុមហ៊ុន ។

**អ្នកតំណាងដោយអាណត្តិ ៖**

លោកមេធាវី និង ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យអគារលេខ ផ្លូវ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ តាមរយៈលិខិតជ្រើសតាំងអ្នកតំណាងដោយអាណត្តិចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២០ ។ ទូរស័ព្ទ

**សហម្ចាស់បំណុល ៖**

-ឈ្មោះ ភេទប្រុស អាយុ ៣៧ ឆ្នាំ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-ឈ្មោះ ភេទប្រុស អាយុ ៣៨ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ៥ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

### សូមគោរពជូនមក

### លោកប្រធានសាលាដំបូងខេត្តព្រះសីហនុ

**កម្មវត្ថុ ៖** សុំប្តឹងតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៤៤ ត.រ/២០ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។



Sangkat Tek Laak III, Khan Toul Kork, Phnom Penh, Cambodia. Tel:

**យោង ៖** -សំណុំរឿងរក្សាការពារលេខ ០៩ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

-ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៤៤ ត.វ/២០ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

តបតាមកម្មវត្ថុ និង យោងខាងលើខ្ញុំបាទសូមធ្វើការជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា: សាលាដំបូងខេត្តព្រះសីហនុបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៤៤ ត.វ/២០ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ មានខ្លឹមសារ ចាត់ចែងជាបណ្តោះអាសន្ន ដោយហាមឃាត់កូនបំណុល ក្រុមហ៊ុន [illegible] មានអ្នកតំណាងស្របច្បាប់លោក [illegible] ជាអភិបាលក្រុមហ៊ុន មិនឱ្យធ្វើការឈូសឆាយ លក់ ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិកាន់កាប់ ផ្ទេរកម្មសិទ្ធិ ធ្វើអំណោយ ធ្វើមតកសាសន៍ ធ្វើអច្ច័យទាន និងធ្វើការផ្សេងៗទៀតនៅលើដីចំនួន ០២ កន្លែងដូចខាងក្រោម ៖

ក. ដីទំហំ [illegible] មានព្រំប្រទល់ខាងជើងជាប់នឹងចំណុច ០ , ខាងត្បូងទល់នឹងផ្លូវជាតិលេខ៤ , ខាងលិចទល់នឹងចំណុច ០ និងខាងកើតទល់នឹងឈ្មោះ [illegible] មានទីតាំងស្ថិតនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

ខ. ដីទំហំ [illegible] ម² មានព្រំប្រទល់ខាងជើងទល់នឹងអូរ , ខាងត្បូងទល់នឹងផ្លូវជាតិលេខ៤ , ខាងលិចទល់នឹងឈ្មោះ [illegible] និងខាងកើតទល់នឹងអូរ មានទីតាំងស្ថិតនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

បើយើងពិនិត្យកស្តុតាងនឹងឯកសារផ្សេងៗ ឃើញថាសហម្ចាស់បំណុលពុំមានសិទ្ធិទំនាក់ទំនងគតិយុត្តិក្នុងការស្នើសុំឱ្យតុលាការចេញដីការក្សាការពារ ចាត់ចែងជាបណ្តោះអាសន្នលើដីទាំង ០២ កន្លែងខាងលើនេះទេ ព្រោះដីនេះមិនមែនជាកម្មសិទ្ធិរបស់សហម្ចាស់បំណុល ។ ខ្ញុំបាទសូមធ្វើការបញ្ជាក់ជូនតុលាការថាដី ០២ កន្លែងខាងលើនេះគឺជាដីកម្មសិទ្ធិស្របច្បាប់របស់ ក្រុមហ៊ុន [illegible] មានអ្នកតំណាងស្របច្បាប់លោក [illegible] ជាអភិបាលក្រុមហ៊ុន ដីនេះគឺកូនក្តីខ្ញុំបានទិញ និងធ្វើការកាន់កាប់ ប្រើប្រាស់អាស្រ័យផលផ្សេងចាប់តាំងពីឆ្នាំ ១៩៩៥ ដូចមានក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១១ប័ណ្ណ ក្នុងនោះមានលេខ ពន [illegible] , [illegible] , [illegible] , [illegible] , [illegible] , [illegible] ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ និងប័ណ្ណលេខ ពន [illegible] , [illegible] , [illegible] , [illegible] , [illegible] ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ មានទីតាំងស្ថិតនៅ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចេញដោយប្រធាននាយកដ្ឋានសុរិយោដី ដែលមានកំណត់ទីតាំង ព្រំប្រទល់ និងនិយាមការច្បាស់លាស់ ។

ដីនេះគឺកូនក្តីរបស់ខ្ញុំបាទបានកាន់កាប់ជាប់រហូតចាប់តាំងពីឆ្នាំ ១៩៩៥ មក ហើយកន្លងមកនៅក្នុងអំឡុងឆ្នាំ ២០១៨ ធ្លាប់មានក្រុមជនខិលខូចមួយចំនួន បានបង្កភាពអនាធិបតេយ្យនៅលើដីរបស់ក្រុមហ៊ុន ករណី

នេះត្រូវបានក្រុមហ៊ុន ធ្វើការអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ហើយរដ្ឋបាលខេត្តព្រះសីហនុបានចេញលិខិតបង្គាប់ការលេខ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៨ ដើម្បីឱ្យកំលាំងមានសមត្ថកិច្ចអនុវត្ត រុះរើផ្ទះ ខ្ទម ពេង របងទាំងឡាយចេញពីទីតាំងដីក្រុមហ៊ុន និងបានដាក់ពាក្យបណ្ដឹងទៅកងរាជអាវុធហត្ថខេត្តព្រះសីហនុ ឃាត់ខ្លួនបានមេខ្លោងឈ្លានពានរំលោភយកដី និងបក្ខពួកមួយចំនួនផងដែរ ។

ដូច្នេះឃើញថាការប្ដឹងសុំរបស់សហម្ចាស់បំណុលដូចមាននៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២៤៤ ត.រ/២០ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ គឺជាការប្ដឹងខុសស្របពេលដែលសហម្ចាស់បំណុល ពុំមានកម្មសិទ្ធិស្របច្បាប់លើដីនេះ ម៉្យាងវិញទៀតការប្ដឹងសុំនេះនាំឱ្យមានការប៉ះពាល់ដល់សិទ្ធិ និងខាតបង់ផលប្រយោជន៍របស់កូនក្ដីខ្ញុំបាទយ៉ាងធ្ងន់ធ្ងរ ។ ដីកាសម្រេចនេះពុំមានភាពចាំបាច់ក្នុងការរក្សាទុកឡើយគប្បីតុលាការពិនិត្យ និងសម្រេចលុបចោល ។

**សំណូមពរ ៖**

-សុំលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២៤៤ ត.រ/២០ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ជាអសារបង់ ។

អាស្រ័យហេតុនេះសូម លោកប្រធាន មេត្តាពិនិត្យ និងធ្វើការសម្រេចសេចក្ដីតាមការស្នើសុំរបស់ខ្ញុំបាទដោយក្ដីអនុគ្រោះ ។

*សូម លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។*

ថ្ងៃ ច័ន្ទ ១៣ កើត ខែ ពិសាខ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០

មេធាវី

AVOCAT ATTORNEY AT LAW

KINGDOM OF CAMBODIA

**ជូនភ្ជាប់មកជាមួយ ៖**

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ១១ ប័ណ្ណ ។

-គំនូសបង្ហាញទីតាំងដី ។

-ឯកសារពាក់ព័ន្ធផ្សេងៗ ។

# ឧបសម្ព័ន្ធទី ២
# ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះ
# ដីកាសម្រេចចាត់ចែងជា
# បណ្តោះអាសន្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
លេខ:៣៤៣.ត.រ/២០

# ដីកាសម្រេច
## អំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

យើង ចៅក្រមទទួលបន្ទុកសំណុំរឿងសាលាដំបូងខេត្តព្រះសីហនុ

-**បានឃើញ** ក្រមនីតិវិធីរដ្ឋប្បវេណីប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦០ ២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

-**បានឃើញ** សំណុំរឿងរក្សាការពារលេខ ០៩ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

រវាង ៖

សហម្ចាស់បំណុល ៖

១.ឈ្មោះ ភេទប្រុស អាយុ ៣៧ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

២.ឈ្មោះ ភេទប្រុស អាយុ ៣៨ ឆ្នាំមានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ៥ សង្កាត់មិត្តភាព ខណ្ឌ៧ មករា រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិ ៖ លោកមេធាវី និងលោកមេធាវី ជាសមាជិកការិយាល័យមេធាវី និង មានការិយាល័យស្ថិតនៅផ្ទះលេខ ផ្លូវ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

កូនបំណុល ៖ ក្រុមហ៊ុន ដែលមានទីស្នាក់ការចុះបញ្ជីស្ថិតនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ តំណាងដោយស្របច្បាប់លោក ជាអភិបាលក្រុមហ៊ុន ។

អ្នកតំណាងដោយអាណត្តិ ៖ លោកមេធាវី , លោកមេធាវី លោកមេធាវី និងលោកមេធាវី មានការិយាល័យស្ថិតនៅអគារលេខ ផ្លូវ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២៤៤ ត.វ/២០ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

-**បានឃើញ** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល ។

**១.សេចក្ដីថ្លែងការណ៍របស់គាគី ៖**

**១.១. សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល ៖**

ខ្លួនសូមរក្សាសេចក្ដីថ្លែងការណ៍ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០ ទុកជាបានការដដែល ។ បើពិនិត្យលើកស្តុតាង និងឯកសារផ្សេងៗឃើញថា សហម្ចាស់បំណុលពុំមានទំនាក់ទំនងគតិយុត្តិក្នុងការស្នើសុំដីកាសម្រេចរក្សាការពារចាត់ចែងជាបណ្ដោះអាសន្នទាំងពីរកន្លែងនេះទេ ព្រោះថាដីនេះមិនមែនជាកម្មសិទ្ធិរបស់សហម្ចាស់បំណុលឡើយ ។

ខ្លួនសូមធ្វើសេចក្ដីបញ្ជាក់ជូនតុលាការថា ដីទាំងពីរកន្លែងខាងលើនេះ គឺជាកម្មសិទ្ធិស្របច្បាប់របស់ក្រុម ហ៊ុន មានអ្នកតំណាងស្របច្បាប់លោក ជាអភិបាលក្រុមហ៊ុន ដី នេះគឺកូនក្ដីខ្ញុំបាទបានទិញ និងធ្វើការកាន់កាប់ប្រើប្រាស់អាស្រ័យផលផ្សេងៗចាប់ពីឆ្នាំ ១៩៩៥ ដូចមានក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១១ ប័ណ្ណ ដែលបានភ្ជាប់មកជាមួយនឹងពាក្យសុំតវ៉ាជូនតុលាការពិនិត្យរួចហើយ ដីនោះគឺមានទីតាំងស្ថិតនៅឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ហើយប័ណ្ណទាំងអស់នេះចេញដោយប្រធាននាយកដ្ឋានសុរិយោដី ដែលមានកំណត់ទីតាំងព្រំប្រទល់ និងនិយាមការច្បាស់លាស់ ។

ដីនេះគឺកូនក្ដីរបស់ខ្លួនបានកាន់កាប់ជាប់រហូតចាប់តាំងពីឆ្នាំ១៩៩៥ មក ហើយកន្លងមកក្នុងឆ្នាំ២០១៨ ធ្លាប់មានជនខិលខូចមួយចំនួន បានបង្កភាពអនាធិបតេយ្យលើដីរបស់ក្រុមហ៊ុន ករណីនេះត្រូវបានក្រុមហ៊ុនធ្វើការអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ហើយរដ្ឋបាលខេត្តព្រះសីហនុ បានចេញលិខិតបង្គាប់ការលេខ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ដើម្បីឱ្យកម្លាំងមានសមត្ថកិច្ចអនុវត្ត រុះរើផ្ទះខ្ទម រោង របងទាំងឡាយចេញពីទីតាំងដីក្រុមហ៊ុន និងបានដាក់ពាក្យបណ្ដឹងទៅកងរាជអាវុធហត្ថខេត្តព្រះសីហនុ [illegible] ខ្លួនបានមេក្លោងឈ្មោះពានរំលោភយកដី និងបក្ខពួកមួយចំនួនផងដែរ ។ ដូច្នេះឃើញថា ការប្ដឹងសុំរបស់សហម្ចាស់បំណុលដូចមាននៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

លេខ២៤៤ ត.វ/២០ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ គឺជាការប្តឹងខុសស្របពេលដែលសហម្ចាស់បំណុល ពុំមានកម្មសិទ្ធិស្របច្បាប់លើដីនេះ ម្យ៉ាងវិញទៀតការប្តឹងសុំនេះនាំឱ្យមានការប៉ះពាល់ដល់សិទ្ធិ និងខាតបង់ផលប្រយោជន៍របស់កូនក្តីខ្ញុំបាទយ៉ាងធ្ងន់ធ្ងរ ។

ផ្អែកតាមកស្តុតាង និងឯកសារផ្សេងៗរបស់សហម្ចាស់បំណុល គឺមានតម្លៃគតិយុត្តទាបជាងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុទាំង១១ប័ណ្ណរបស់កូនក្តីខ្លួន ។ ដីកាសម្រេចនេះពុំមានភាពចាំបាច់ក្នុងការរក្សាទុកឡើយ គប្បីតុលាការពិនិត្យ និងសម្រេចលុបចោល ។

**១.២. សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យម្ចាស់បំណុល ៖**

មូលហេតុនៃការដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ដោយស្នើសុំហាមឃាត់កូនបំណុល មិនឲ្យធ្វើការឈូសឆាយ លក់ ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិកាន់កាប់ ផ្ទេរកម្មសិទ្ធិ ធ្វើអំណោយ ធ្វើមតកសាសន៍ ធ្វើអច្ច័យទាន និងធ្វើការប្រែផ្សេងៗទៀត ទៅលើដី ០២ កន្លែង ដូចមានចែងក្នុងកម្មវត្ថុនៃពាក្យសុំចេញដីកាសម្រេចរក្សាការពារ ដោយហេតុថា ៖

ដីទំហំ ៩៥.០០០ (ប្រាំបួនម៉ឺនប្រាំពាន់) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងជាប់នឹងចំនុច០ ខាងត្បូងទល់នឹងផ្លូវជាតិ ខាងលិចទល់នឹងចំនុច០ និងខាងកើតទល់នឹងឈ្មោះ មានទីតាំងស្ថិតនៅភូមិចំណោទរាម សង្កាត់បិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានម្ចាស់ដីដើមឈ្មោះ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះ ថ្ងៃទី ០១ ខែ មករា ឆ្នាំ១៩៩៩ បានលក់មកឲ្យកូនក្តីខ្ញុំឈ្មោះ ដូចមានលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

ចំណែកដីទំហំ ៧៦.០៧៧ (ប្រាំពីរម៉ឺនប្រាំមួយពាន់ចិតសិបប្រាំពីរ) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងអូរ ខាងត្បូងទល់នឹង ផ្លូវជាតិលេខ៤ ខាងលិចទល់នឹងឈ្មោះ និងខាងកើតទល់នឹងអូរ មានទីតាំងស្ថិតនៅភូមិពូធឿង សង្កាត់បិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានម្ចាស់ដីដើមឈ្មោះ បានលក់មកឱ្យកូនក្តីខ្លួនឈ្មោះ ដូចមានកិច្ចសន្យាផ្ទេរសិទ្ធិលក់ផ្តាច់ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០០៩។ ដីដែលកូនក្តីខ្ញុំបានទិញមានប្រវត្តិត្រឹមត្រូវ ដែលម្ចាស់ដើមបានធ្វើការកាន់កាប់ ស្របតាមច្បាប់ភូមិបាល រហូតមានឯកសារបញ្ជាក់ពីសិទ្ធិកាន់កាប់ (គោគ:) គឺពាក្យស្នើសុំសិទ្ធិកាន់កាប់ដីធ្លី ដែលបានទទួលស្គាល់ពីមន្ត្រីថ្នាក់មូលដ្ឋានភូមិ-ឃុំត្រឹមត្រូវ និងបានផ្ទេរបន្តតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬកិច្ចសន្យាផ្ទេរសិទ្ធិដីលក់ផ្តាច់ មានទីតាំងស្ថិតនៅភូមិពូធឿង

និងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មិនមែនស្ថិតនៅក្នុងសង្កាត់លេខ១ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ ដូចមានក្នុងប័ណ្ណទាំង ១១ ប្លង់របស់កូនបំណុលឡើយ ។

បន្ទាប់ពីបានទិញពីម្ចាស់ដើម កូនក្តីខ្លួនបានគ្រប់គ្រងកាន់កាប់ជាក់ស្តែង ជាប់លាប់និងដីងត្ម ពីអាជ្ញាធរភូមិឃុំក្នុងមូលដ្ឋានផ្ទាល់ មិនដែលមានតតិយជនណាមកអះអាង ឬតវ៉ាទាមទារថា ជាដីរបស់ខ្លួននោះឡើយ ។ រហូតមកដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ កូនក្តីខ្លួនឈ្មោះ បានស្នើសុំការអនុញ្ញាតពីរដ្ឋបាលខេត្តព្រះសីហនុ ហើយរដ្ឋបាលខេត្ត បានចេញលិខិតអនុញ្ញាតលេខ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នា ២០១៨ ដោយឯកភាពឲ្យកូនក្តីខ្លួនធ្វើការឈូសឆាយពង្រាប និងធ្វើរបងព័ទ្ធជុំវិញដីលើផ្ទៃដីទំហំ ៧ ហិកតា ៦០ អា ស្ថិតនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ ទើបតែក្នុងពេលថ្មីៗនេះ ស្រាប់តែកូនបំណុលគឺ **ក្រុមហ៊ុន** បានយកប្លង់ដីរបស់ខ្លួនចំនួន ១១ ប័ណ្ណ មានទីតាំងស្ថិតនៅសង្កាត់លេខ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មករំលោភយកដីជាកម្មសិទ្ធិស្របច្បាប់របស់កូនក្តីខ្ញុំ ដែលកំពុងកាន់កាប់ជាក់ស្តែងនៅភូមិពូធឿង និងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ លើសពីទំហំដីជាកម្មសិទ្ធិរបស់ខ្លួនជាក់ស្តែង ដែលមានក្នុងប័ណ្ណកម្មសិទ្ធិទាំង ១១ ប័ណ្ណ និងមានទីតាំងផ្សេងគ្នា ។ លើសពីនេះទៀត **ក្រុមហ៊ុន** បានដាក់ពាក្យសុំអន្តរាគមន៍ ទៅអាជ្ញាធរមានសមត្ថកិច្ច ហើយនៅពេលដែលអវត្តមានរបស់កូនក្តីខ្ញុំជាម្ចាស់ដី កម្លាំងមានសមត្ថកិច្ចបានចុះបង្ក្រាបរុះរើផ្ទះ និងសំណង់ផ្សេងៗ ដែលកូនក្តីខ្លួនបានសាងសង់នៅលើដីរបស់ពួកគាត់ ។ មិនតែប៉ុណ្ណោះ អ្នកចាំដីរបស់កូនក្តីខ្លួន ក៏ត្រូវបានពួកគេបណ្តេញចេញអស់ពីទីតាំងដីដែរ ដោយហេតុថា ពួកគេគ្មានលទ្ធភាពទប់ទល់ក៏ព្រមចាកចេញទាំងបង្ខំ ។

ដើម្បីសបញ្ជាក់អំពីការពិត ខ្លួនសូមដាក់ជូននូវឯកសារភស្តុតាងមួយចំនួនដូចជា ១. ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៩ (ម្ចាស់ដីដើម ) ។ ២.លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ (ផ្ទេរសិទ្ធិកាន់កាប់ពីឈ្មោះ មកឈ្មោះ ) ។ ៣.ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០១ (ម្ចាស់ដីដើម ) ។ ៤.កិច្ចសន្យាផ្ទេរសិទ្ធិលក់ផ្តាច់ចុះថ្ងៃទី ០២ ខែធ្នូ

ឆ្នាំ២០០៩ (ផ្ទេរសិទ្ធិកាន់កាប់ពីឈ្មោះ មកឈ្មោះ ) ។ ៥.លិខិតអនុញ្ញាតលេខ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់រដ្ឋបាលខេត្តព្រះសីហនុ ។

**២.សំអាងហេតុ**

២-១. ផ្អែកតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យភាគី ដូចមានក្នុងចំណុច ១.១ និង ១.២ ខាងលើ និងផ្អែកតាមការពិនិត្យភ័ស្តុតាងនានាក្នុងសំណុំរឿងដែលភាគីបានដាក់ជូនតុលាការពិនិត្យ តុលាការពិចារណាឃើញថា ៖

- ដីដែលជាវត្ថុវិវាទនេះមានទីតាំងស្ថិតនៅភូមិពូជឿង និងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ហើយបើតាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុលបានបញ្ជាក់ថា ដីនេះជាកម្មសិទ្ធិរបស់កូនក្តីខ្លួន គឺក្រុមហ៊ុន ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១១ ប័ណ្ណ ក្នុងនោះមានប័ណ្ណលេខ ពន , លេខ ពន , លេខ ពន , លេខ ពន , លេខ ពន , លេខ ពន , លេខ ពន , លេខ ពន , លេខ ពន , លេខ ពន និងលេខ ពន ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ។
- ចំពោះទឡ្ហីករណ៍ខាងលើនេះ ត្រូវបានមេធាវីតំណាងដោយអាណត្តិឱ្យសហម្ចាស់បំណុលបានធ្វើវិវាទកម្មថា ដីដែលជាវត្ថុវិវាទនេះ គឺកូនក្តីខ្លួនឈ្មោះ និងឈ្មោះ បានទិញពីម្ចាស់ដីដើមឈ្មោះ និងឈ្មោះ តាមរយៈកិច្ចសន្យាផ្ទេរសិទ្ធិលក់ផ្តាច់ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០០៩ , ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

២-២. យោងតាមសំអាងហេតុខាងលើនេះឃើញថា កិរិយានៃការកាន់កាប់ដីរបស់ភាគីសហម្ចាស់បំណុល ដោយសំអាងលើកិច្ចសន្យាផ្ទេរសិទ្ធិលក់ផ្តាច់ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ , ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៩ គឺពុំអាចតតាំងនិងកិរិយានៃការកាន់កាប់របស់កូនបំណុល ដែលសំអាងលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់

អចលនវត្ថុទាំង ១១ ប័ណ្ណ ដូចមានបញ្ជាក់ក្នុងសំអាងហេតុក្នុងចំណុច ២-១ ខាងលើនេះបានទេ ។

២-៣. យោងតាមសំអាងហេតុក្នុងចំណុចទី ២-១ និងទី ២-២ ខាងលើបានរំលេចឱ្យឃើញថា ការប្តឹងសុំរបស់កូនបំណុល គឺមានមូលហេតុត្រឹមត្រូវ ។ គប្បីតុលាការសម្រេចតាមពាក្យប្តឹងសុំរបស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល ។

២-៤. ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៤៤ ត.រ/២០ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលសម្រេចហាមឃាត់កូនបំណុលឈ្មោះ ក្រុមហ៊ុន គឺគ្មានភាពចាំបាច់ទៀតទេ ។ គប្បីសម្រេចលុបចោល ។

២-៥. ប្រាក់ពន្ធដាក់ពាកក្យសុំជាបន្ទុករបស់កូនបំណុលដាក់ពាក្យសុំតវ៉ា ។

## ៣.សេចក្តីសម្រេចបញ្ចប់

៣-១. ទទួលពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-២. លុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៤៤ ត.រ/២០ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៣-៣. ដីកាសម្រេចនេះ មានអានុភាពភ្លាមៗ ។

៣-៤. រឹបអូសប្រាក់ពន្ធដាក់ពាក្យសុំ ដែលប្រាក់នេះកូនបំណុលបានបង់រួចហើយ ។

ដីកាសម្រេចនេះ ធ្វើនៅថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ។

ចៅក្រម

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ១៧ ខែ ៦ ឆ្នាំ ២០២០
ក្រឡាបញ្ជី

# ឧបសម្ព័ន្ធទី ៣
# ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះ
# ដីកាសម្រេចរក្សាការពារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេច

សាលាដំបូងខេត្តព្រះសីហនុ
ដីកាសម្រេច
លេខ..៥៤១...... ត.រ/២០
ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

## អំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

ឯកឧត្តម ជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ។

*-បានឃើញក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦-០៧-២០០៦ ។*

-បានឃើញ សំណុំរឿងរក្សាការពារលេខ៦៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាសម្រេចរក្សាការពារ លេខ ៣៧៥ តរ/២០ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

-បានឃើញ ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ របស់មេធាវី និងលោក តំណាងដោយអាណត្តិឱ្យកូនបំណុលឈ្មោះ ។

**-ភាគីម្ចាស់បំណុល:**

ម្ចាស់បំណុលឈ្មោះ ភេទប្រុស សញ្ជាតិចិន មានទីសំណាក់នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តំណាងឱ្យក្រុមហ៊ុន មានអាសយដ្ឋាន ផ្លូវ សង្កាត់ច្រាំងចំរេះ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។ អ្នកបកប្រែឈ្មោះ ភេទស្រី អាយុ៤០ឆ្នាំ អាសយដ្ឋានភូមិ២ សង្កាត់៣ ក្រុងខេត្តព្រះសីហនុ ។

-អ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលលោកមេធាវី អត្តលេខ មានការិយាល័យភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

**-ភាគីកូនបំណុល:**

កូនបំណុលឈ្មោះ តំណាងឱ្យ ក្រុមហ៊ុន មានទីស្នាក់ការផ្ទះលេខ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-អ្នកតំណាងដោយអាណត្តិឱ្យកូនបំណុលលោកមេធាវី និងលោកមេធាវី មានការិយាល័យក្រុមមេធាវី ស្ថិតនៅអគារលេខ ផ្លូវលេខ២៤២កែង ១០៧ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

<u>កម្មវត្ថុបណ្តឹង៖</u> ប្តឹងតវ៉ាលើដីកាសម្រេចរក្សាការពារ លេខ ៣៧៥ តរ/២០ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

*ភស្តុតាងថតចម្លងបញ្ជាក់ការទាមទារដាក់ដោយកូនបំណុល៖*

- កិច្ចព្រមព្រៀងសាងសង់ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ។
- លិខិតឆ្លងដែន លេខ [illegible] ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ [illegible] ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ របស់ឈ្មោះ [illegible] ។
- លិខិតអនុញ្ញាតសាងសង់ លេខ [illegible] ដនស/អដន ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ។
- លិខិតលេខ [illegible] គ.ត.ស.ព ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ប្រធានគណៈកម្មការត្រួតពិនិត្យគុណភាពសំណង់ខេត្តព្រះសីហនុ ។
- លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ លេខ [illegible] អសណ/នសណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។
- លិខិតជូនដំណឹងតប ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ។

## ១.ការអះអាងរបស់ភាគីនៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់

១.១. លោកមេធាវី [illegible] តំណាងដោយអាណត្តិឱ្យកូនបំណុលឈ្មោះ [illegible] បានថ្លែងការណ៍ថា៖ ខ្ញុំបាទស្នើសុំសុំលុបចោលដីកាសម្រេចរក្សាការពារលេខ៣៧៩ត.រ/២០ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ក្នុងសំណុំរឿងរក្សាការពារលេខ៦៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។

សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចចេញដីសម្រេចរក្សាការពារលេខ៣៧៩ ត.រ/២០ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ក្នុងសំណុំរឿងរក្សាការពារលេខ៦៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលបានហាមឃាត់កូនក្តីយើងខ្ញុំជាកូនបំណុលធ្វើសកម្មភាពជាច្រើនដូចជា៖ (១)មិនឱ្យកូនបំណុលធ្វើការលក់ ដាក់ហ៊ីប៉ូតែក ដាក់បញ្ចាំធានា ធ្វើអំណោយ ជួល ដោះដូរ ឬធ្វើការផ្ទេរកម្មសិទ្ធិនូវសំណង់អគារកំពស់២៧ជាន់ និងដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ [illegible] ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ដែលមានទីតាំងនៅភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុជាបណ្តោះអាសន្ន (២)កូនបំណុលអាចដាក់ប្រាតិភោគប្រាក់ចំនួន [illegible] ដុល្លារអាមេរិក) ដើម្បីលុបដីកាសម្រេចនេះ (៣)ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីកូនបំណុល (៤)ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ។ ចំពោះដីកាសម្រេចរក្សាការពារនេះបានធ្វើឱ្យខូចខាតប្រយោជន៍របស់កូនក្តីយើងខ្ញុំយ៉ាងខ្លាំង ព្រោះថាជាក់ស្តែងកូនក្តីរបស់យើងខ្ញុំតែងតែអនុវត្តកាតព្វកិច្ចទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងសាងសង់ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ពុំដែលខកខាននោះទេ។ ដោយឡែកភាគីខាងម្ចាស់បំណុលវិញទេដែលសាងសង់អគារមិនទាន់រួចរាល់ និងផ្អាកការសាងសង់តាំងពីចុងឆ្នាំ២០១៩ មកម្ល៉េះ ដែលបង្កឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់កូនក្តីយើងខ្ញុំយ៉ាងធ្ងន់ធ្ងរ។ មិនតែប៉ុណ្ណោះនាពេលកន្លងមក ក្រុមហ៊ុន [illegible] មិនបានបំពេញលក្ខខណ្ឌតាមការសន្យាជាមួយនឹងកូនក្តីខ្ញុំបាទពាក់ព័ន្ធនឹងការសាងសង់អគារឱ្យស្របទៅតាមទិដ្ឋភាពច្បាប់នោះទេ ជាក់ស្តែងដូចលិខិតលេខ [illegible] គ.ត.ស.ព ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់គណៈកម្មការពិនិត្យគុណភាពសំណង់ខេត្តព្រះសីហនុ ដែលបានបញ្ជាក់ថាក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ ក្រុមជាងសំណង់ និងវិស្វករប្រចាំការដ្ឋាន [illegible]

ប័ណ្ណប្រកបអាជីវកម្មចេញពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលធ្វើឱ្យគុណភាពសំណង់ ពុំត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសសាងសង់ ដែលច្បាប់បានកំណត់ដូចមានបញ្ជាក់នៅក្នុងលិខិតខាងលើ។ ប៉ុន្តែទោះបីជាមានករណីដូចខាងលើនេះកើតឡើងយ៉ាងណាក៏ដោយ ក៏កូនក្តីយើងខ្ញុំនៅតែមានបំណងក្នុងការដោះស្រាយជាមួយនឹងភាគីម្ចាស់បំណុលតាំងពីដើមរហូតមក ដូចជាការស្នើសុំទៅកាន់អាជ្ញាធរពាក់ព័ន្ធដើម្បីបន្តការសាងសង់អគារ និងបានព្រមព្រៀងគ្នាក្នុងការប្រគល់បន្ទប់នៃអគារចំនួន៧៨បន្ទប់ គឺចាប់ពីជាន់ទី៣ ដល់ជាន់ទី៩ ស្មើនឹង៦ជាន់(អគារគ្មានជាន់ទី៤ទេ) ដែលការព្រមពៀងនោះគឺម្ចាស់បំណុលបានសរសេរដោយដៃជាភាសាចិន និងមានការផ្តិតមេដៃពីកូនក្តីយើងខ្ញុំ ហើយម្ចាស់បំណុលក៏បានយកឯកសារនោះទៅប្រទេសចិនបាត់ដោយមិនបានទុកឱ្យកូនក្តីយើងខ្ញុំ និងមិនបានផ្តិតមេដៃជាមួយកូនក្តីយើងខ្ញុំនោះទេ។ បន្ទាប់ពីមានហេតុការណ៍ដូចរៀបរាប់ខាងលើនេះ ភាគីម្ចាស់បំណុលបានធ្វើលិខិតជូនដំណឹងមកកូនក្តីយើងខ្ញុំ ហើយកូនក្តីយើងខ្ញុំក៏បានធ្វើការជូនដំណឹងតាមរយៈលិខិតជូនដំណឹងតប ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ទៅម្ចាស់បំណុលក្រុមហ៊ុន [illegible] ដើម្បីធ្វើការដោះស្រាយបញ្ហាខាងលើឱ្យបានរួចរាល់ ក៏ប៉ុន្តែភាគីខាងក្រុមហ៊ុននៅតែគ្មានដំណោះស្រាយណាមួយមកឱ្យកូនក្តីយើងខ្ញុំដដែល។

សរុបសេចក្តីមក ការអាក់ខានបង់ប្រាក់សម្រាប់ការសាងសង់អគារខាងលើ គឺកើតដោយសារតែការពុំបានបំពេញកាតព្វកិច្ចរបស់ម្ចាស់បំណុលឱ្យបានត្រឹមត្រូវតាមការកំណត់ និងមិនព្រមចូលខ្លួនធ្វើការដោះស្រាយបញ្ហា។ ម្យ៉ាងវិញទៀតទីតាំងដីខាងលើរបស់កូនក្តីយើងខ្ញុំបានលក់បន្ទប់នៃអគារនោះមានចំនួន ៩១ បន្ទប់ទៅឱ្យអតិថិជនរួចរាល់ហើយ ដោយតាមការសន្យាអគារខាងលើត្រូវសាងសង់ឱ្យបានរួចរាល់ និងចូលស្នាក់នៅបានក្នុងខែមិថុនា ឆ្នាំ២០២០។ ហេតុដូចនេះ ដីកាសម្រេចរក្សាការពារខាងលើ គឺបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូនក្តីយើងខ្ញុំយ៉ាងធ្ងន់ធ្ងរ ហេតុនេះដើម្បីជៀសវាងការខូចខាតប្រយោជន៍របស់កូនក្តី យើងខ្ញុំស្នើសុំអោយតុលាការមេត្តាសម្រេចតាមពាក្យសុំរបស់យើងខ្ញុំ ដោយក្តីអនុគ្រោះ។

ក្នុងកិច្ចសន្យា ម្ចាស់បំណុលត្រូវសាងសង់សំណង់រួចរាល់រយៈពេល១៥ខែ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ប៉ុន្តែម្ចាស់បំណុលមិនបានសាងសង់រួចរាល់នោះទេ ក៏ធ្វើការចាកចេញពីអគារ ។ ការបញ្ឈប់ការសាងសង់អគារ គឺប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កូនក្តីខ្ញុំបាទ ដោយកូនក្តីខ្ញុំបាទត្រូវប្រគល់បន្ទប់ឱ្យអតិថិជនចំនួន ៩១បន្ទប់ ដោយសន្យាថាប្រគល់ឱ្យក្នុងខែមិថុនា ប្រសិនបើមានការយឺតយ៉ាវ គឺត្រូវបង់ប្រាក់ពិន័យមួយថ្ងៃ១០$ក្នុងមួយបន្ទប់ ដូច្នេះ កូនក្តីខ្ញុំបាទត្រូវចំណាយប្រាក់ចំនួន ៩១០$ក្នុងមួយថ្ងៃឱ្យអតិថិជន ។ នៅមុនពេលសាងសង់ ក្រុមហ៊ុនម្ចាស់បំណុលមិនមានច្បាប់សាងសង់ត្រឹមត្រូវទេ ដោយកូនក្តីខ្ញុំបាទជាអ្នកចេញមុខដោះស្រាយ ទើបអាចសាងសង់បន្តបាន ។ ចំពោះការលក់បន្ទប់នោះ គឺកូនក្តីខ្ញុំបាទបានលក់មុនពេលសាងសង់អគារនេះទៅទៀត ។

១.២. ម្ចាស់បំណុលឈ្មោះ [illegible] ថ្លែងការណ៍៖ លោកមេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុលលើកឡើងថាខាងខ្ញុំបាទមិនបានសាងសង់អគារឱ្យលោក [illegible] តាមការកំណត់ នោះមិនត្រឹមត្រូវទេ ហេតុផលទាំងអស់ដោយសារតែលោក [illegible] មិនព្រមបង់ថ្លៃសាងសង់តាមការកំណត់ក្នុងកិច្ចព្រមព្រៀង ដែលភាគីទាំងសងខាងបានចុះព្រមព្រៀងគ្នា។ ចំពោះការលើកឡើងថា សំណង់មានអ្នកគ្រប់គ្រងទេ

ដោយនៅក្នុងអំឡុងពេលសាងសង់លោក  បានហៅវិស្វករថ្មីមួយមកចូលរួមពិនិត្យលើគុណភាពសំណង់ផងដែល ។ ចំពោះការលើកឡើងថា សំណង់របស់គាត់ពុំមានគុណភាពតាមស្តង់ដា គឺគាត់អាចលើកឡើងពេលសំណង់ដំបូង មិនមែនចាំតែក្រុមហ៊ុនរបស់ខ្ញុំបាទសាងសង់ដល់ជាន់ទី២៧ ទើបប្រាប់ថា សំណង់គ្មានគុណភាព នោះមិនអាចទទួលយកបានទេ ។ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ពួកខ្ញុំបានចាក់ឬង់សេជាន់ទី២៧រួចរាល់ នៅពេលដែលចងគ្រោងដែក និងចាក់បេតុង គឺត្រូវកម្មង់គេ ដោយក្នុងកិច្ចព្រមព្រៀង លោក  ត្រូវបង់ប្រាក់ឱ្យគ្រប់ ៤,៥០០,០០០$(បួនលានប្រាំសែនដុល្លារអាមេរិក) ប៉ុន្តែរហូតដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ លោក  ទើបតែបង់បានចំនួន ១,៨១០,០០០$(មួយលានប្រាំបីសែនមួយម៉ឺនដុល្លារអាមេរិក) ដោយលោក  មានចេតនាពន្យាពេលបង់ប្រាក់ដល់ក្រុមហ៊ុនយើងខ្ញុំ ។ ទោះបីជាលោក  មិនបានបង់ប្រាក់គ្រប់តាមកិច្ចសន្យាក៏ដោយ ក៏ក្រុមហ៊ុនយើងខ្ញុំនៅតែដំណើរការបន្តសាងសង់ដល់ជាន់ទី២៧ និងបានដេគ័របានដល់ជាន់ទី១៦ ។ ក្រោយមកដោយសារតែ ក្រុមហ៊ុនយើងខ្ញុំជំពាក់ប្រាក់ខែបុគ្គលិក និងប្រាក់ថ្លៃសំណង់ច្រើន ដែលនាំឱ្យក្រុមហ៊ុនយើងខ្ញុំមិនអាចដំណើរការបាន ទើបទាមទារឱ្យកូនបំណុលគោរពកិច្ចព្រមព្រៀង ។ រហូតដល់ខែឧសភា ឆ្នាំ២០២០ លោក  បានហៅក្រុមហ៊ុនសំណង់ថ្មីចូលទៅបន្តសាងសង់ និងដេញកម្មកររបស់យើងខ្ញុំចេញទៀតផង ។ ដូច្នេះទើបខ្ញុំបាទស្នើសុំរក្សាការពារផ្អាកការសាងសង់ និងមិនឱ្យលក់ដូរជួល ដើម្បីទុកអគារនេះធានាបំណុលរបស់ខ្ញុំបាទ ។

១.៣. លោកមេធាវី  តំណាងដោយអាណត្តិឱ្យម្ចាស់បំណុល បានថ្លែងការណ៍ថា៖ កូនបំណុលបានទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់លុយថ្លៃសាងសង់ មិនទាន់បានបង់គ្រប់ចំនួន ៤,៥០០,០០០$(បួនលានប្រាំសែនដុល្លារអាមេរិក) ឱ្យកូនក្តីខ្ញុំប្រាកដមែន ដោយមានការស៊ីសង្វាក់ទៅនឹងសំអាងជាច្រើន ថាពិតជាបានសាងសង់បាន២៧ជាន់តាមការព្រមព្រៀងប្រាកដមែន ។ មិនមានភាពចាំបាច់ដើម្បីលុបចោលដីកាសម្រេចរក្សាការពារ ដោយសារអគារនេះ គឺកូនក្តីខ្ញុំបាទជាអ្នកសាងសង់ និងកូនបំណុលជំពាក់ប្រាក់កូនក្តីខ្ញុំបាទជាង ២,៥៤០,០០០$ មែន ។ បើសិនជាការលើកឡើងរបស់មេធាវីកូនបំណុល និយាយថាអគារមិនទាន់ធ្វើហើយ គឺកាន់តែមិនអាចយកទៅលក់ជួលបាន ។ ដោយមិនមានភស្តុតាងថ្មី នាំឱ្យលុបដីកាសម្រេចរក្សាការពារនោះទេ ស្នើសុំឱ្យតុលាការមេត្តាតំកល់ដីកាសម្រេចរក្សាការពារទុកនៅដដែល ព្រោះមុននឹងតុលាការចេញដីកាសម្រេចរក្សាការពារគឺបានពិនិត្យត្រឹមត្រូវហើយ ។

ការដែលកូនបំណុលលើកឡើងថាលក់បាន៩១បន្ទប់ គឺផ្ទុយពីរក្សាការពាររបស់តុលាការ ។ តែប្រសិនបើកូនបំណុលមានបំណងចង់លក់បន្ទប់នៃអគារនេះ គឺអាចយកប្រាក់មកតំកល់ដើម្បីធានាសំណងកូនក្តីខ្ញុំបាទបាន ។ ជាទូទៅ ម្ចាស់អគារជាអ្នកធ្វើច្បាប់សាងសង់ មិនមែនជាការងាររបស់កូនក្តីខ្ញុំបាទទេ ដូចភាគីកូនបំណុលបានលើកឡើងថា ដោយសារមិនមានច្បាប់អនុញ្ញាតត្រឹមត្រូវ ពេលមានសមត្ថកិច្ចមករក គឺកូនបំណុលតែងតែជួយអន្តរាគមន៍ ។

ចំពោះការលក់បន្ទប់ តាមច្បាប់ គឺទាល់តែមានការផ្ទេរកម្មសិទ្ធិ ជាលិខិតយថាភូត [illegible] ទើបអាចយកជាការបាន ដូច្នេះការលើកឡើងនេះ គឺអាចជាការកាឡៃ ឬកុហកដើម្បីរួមផុតពីការ[illegible] ។

២.សំអាងហេតុ

តាមលទ្ធផល និងពិនិត្យភស្តុតាងនានាក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់រួចមកឃើញថា៖

២.១. ពាក្យសុំតវ៉ាដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ របស់មេធាវី [redacted] និងលោក [redacted] តំណាងដោយអាណត្តិឱ្យកូនបំណុលឈ្មោះ [redacted] ប្ដឹងតវ៉ាទៅនឹងដីកាសម្រេចរក្សាការពារ លេខ ៣៧៥ តរ/២០ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ដូចមានចែងតាមមាត្រា៥៣៤ និងមាត្រា៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.២. តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល ថា មូលហេតុដែលកូនក្ដីខ្លួនប្ដឹងតវ៉ានឹងដីកាសម្រេចរក្សាការពារ លេខ ៣៧៥ តរ/២០ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ដោយសារកូនក្ដីខ្លួនមានការបារម្ភថា ចំពោះដីកាសម្រេចរក្សាការពារនេះបានធ្វើឱ្យខូចខាតប្រយោជន៍របស់កូនក្ដីខ្លួនយ៉ាងខ្លាំង ព្រោះថាជាក់ស្ដែងកូនក្ដីរបស់ខ្លួនតែងតែអនុវត្តកាតព្វកិច្ចទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងសាងសង់ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ពុំដែលខកខាននោះទេ។ ដោយឡែកភាគីខាងម្ចាស់បំណុលវិញទេដែលសាងសង់អគារមិនទាន់រួចរាល់ និងផ្អាកការសាងសង់តាំងពីចុងឆ្នាំ២០១៩ មកម្ល៉េះ ដែលបង្ករឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់កូនក្ដីខខ្លួនយ៉ាងធ្ងន់ធ្ងរ។ មិនតែប៉ុណ្ណោះនាពេលកន្លងមក ម្ចាស់បំណុលមិនបានបំពេញលក្ខខណ្ឌតាមការសន្យាជាមួយនឹងកូនក្ដីខ្លួនពាក់ព័ន្ធនឹងការសាងសង់អគារឱ្យស្របទៅតាមទិដ្ឋភាពច្បាប់នោះទេ ជាក់ស្ដែងដូចលិខិតលេខ [redacted] គ.ត.ស.ព ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់គណៈកម្មការពិនិត្យគុណភាពសំណង់ខេត្តព្រះសីហនុ ដែលបានបញ្ជាក់ថាក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ ក្រុមជាងសំណង់ និងវិស្វករប្រចាំការដ្ឋាន គ្មានអាជ្ញាប័ណ្ណប្រកបអាជីវកម្មចេញពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលធ្វើឱ្យគុណភាពសំណង់ ពុំត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសសាងសង់ ដែលច្បាប់បានកំណត់ដូចមានបញ្ជាក់នៅក្នុងលិខិតខាងលើ។ សរុបសេចក្ដីមក ការអាក់ខានបង់ប្រាក់សម្រាប់ការសាងសង់អគារខាងលើ គឺកើតដោយសារតែការពុំបានបំពេញកាតព្វកិច្ចរបស់ម្ចាស់បំណុលឱ្យបានត្រឹមត្រូវតាមការកំណត់ និងមិនព្រមចូលខ្លួនធ្វើការដោះស្រាយបញ្ហា។ ម្យ៉ាងវិញទៀតទីតាំងដីខាងលើរបស់កូនក្ដីខ្លួនបានលក់បន្ទប់នៃអគារនោះមានចំនួន ៩១ បន្ទប់ទៅឱ្យអតិថិជនរួចរាល់ហើយ ដោយតាមការសន្យាអគារខាងលើត្រូវសាងសង់ឱ្យបានរួចរាល់ និងចូលស្នាក់នៅបានក្នុងខែមិថុនា ឆ្នាំ២០២០។ ហេតុនេះដើម្បីជៀសវាងការខូចខាតប្រយោជន៍របស់កូនក្ដី ខ្លួនស្នើសុំអោយតុលាការមេត្តាសម្រេចតាមពាក្យសុំរបស់ខ្លួន ដោយក្ដីអនុគ្រោះ។ តុលាការយល់ឃើញថា ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល មិនមានហេតុផលសមរម្យ ម្យ៉ាងទៀត បើលុបដីកាសម្រេចរក្សាការពារ នាំឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់ម្ចាស់បំណុល និងដើម្បីធានាភាពចាំបាច់សិទ្ធិលើបំណុលផងដែរ ដូច្នេះការស្នើសុំនេះ មិនអាចឱ្យតុលាការយកមកពិចារណាបានឡើយ ។

២.៣. តាមសេចក្ដីថ្លែងការណ៍របស់ម្ចាស់បំណុលថ្លែងការណ៍ថា ការលើកឡើងថា [illegible] សាងសង់អគារឱ្យលោក [redacted] តាមការកំណត់ នោះមិនត្រឹមត្រូវទេ ហេតុផលទាំងអស់ [illegible] លោក [redacted] មិនព្រមបង់ថ្លៃសាងសង់តាមការកំណត់ក្នុងកិច្ចព្រមព្រៀង ដែលភាគី [illegible]

ព្រមព្រៀងគ្នា។ ចំពោះការលើកឡើងថា សំណង់មានបញ្ហា គឺមិនអាចទេ ដោយនៅក្នុងអំឡុងពេលសាងសង់ លោក  បានហៅវិស្វករថ្មីមួយមកចូលរួមពិនិត្យលើគុណភាពសំណង់ផងដែល ។ ចំពោះការលើកឡើងថា សំណង់របស់គាត់ពុំមានគុណភាពតាមស្តង់ដា គឺគាត់អាចលើកឡើងពេលសំណង់ដំបូង មិនមែនចាំតែក្រុមហ៊ុនរបស់ខ្លួនសាងសង់ដល់ជាន់ទី២៧ ទើបប្រាប់ថាសំណង់គ្មានគុណភាព នោះមិនអាចទទួលយកបានទេ ។ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ខ្លួនបានចាក់ប្លង់សេជាន់ទី២៧ រួចរាល់ នៅពេលដែលចងគ្រោងដែក និងចាក់បេតុង គឺត្រូវកម្មង់គេ ដោយក្នុងកិច្ចព្រមព្រៀង លោក  ត្រូវបង់ប្រាក់ឱ្យគ្រប់ ៤,៥០០,០០០$(បួនលានប្រាំសែនដុល្លារអាមេរិក) ប៉ុន្តែរហូតដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ លោក  ទើបតែបង់បានចំនួន ១,៨១០,០០០$(មួយលានប្រាំបីសែនមួយម៉ឺនដុល្លារអាមេរិក) ដោយលោក  មានចេតនាពន្យាពេលបង់ប្រាក់ដល់ក្រុមហ៊ុនខ្លួន ។ ទោះបីជាលោក  មិនបានបង់ប្រាក់គ្រប់តាមកិច្ចសន្យាក៏ដោយ ក៏ក្រុមហ៊ុនខ្លួននៅតែដំណើរការបន្តសាងសង់ដល់ជាន់ទី២៧ និងបានដេគ័របានដល់ជាន់ទី១៦ ។ ក្រោយមកដោយសារតែ ក្រុមហ៊ុនខ្លួនជំពាក់ប្រាក់ខែបុគ្គលិក និងប្រាក់ថ្លៃសំណង់ច្រើន ដែលនាំឱ្យក្រុមហ៊ុនខ្លួនមិនអាចដំណើរការបាន ទើបទាមទារឱ្យកូនបំណុលគោរពកិច្ចព្រមព្រៀង ។ រហូតដល់ខែឧសភា ឆ្នាំ២០២០ លោក  បានហៅក្រុមហ៊ុនសំណង់ថ្មីចូលទៅបន្តសាងសង់ និងដេញកម្មកររបស់ខ្លួនចេញទៀតផង ។ ដូច្នេះទើបខ្លួនស្នើសុំរក្សាការពារផ្អាកការសាងសង់ និងមិនឱ្យលក់ដូរជួល ដើម្បីទុកអគារនេះធានាបំណុលរបស់ខ្លួន ។ តុលាការយល់ឃើញថា ការលើកឡើងរបស់ម្ចាស់បំណុល មានហេតុផល និងសំអាងហេតុច្បាស់លាស់ អាចឱ្យតុលាការយកមកពិចារណាបាន ។

២.៤. តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលថា កូនបំណុលបានទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់លុយថ្លៃសាងសង់ មិនទាន់បានបង់គ្រប់ចំនួន ៤,៥០០,០០០$(បួនលានប្រាំសែនដុល្លារអាមេរិក) ឱ្យកូនក្តីខ្លួនប្រាកដមែន ដោយមានការស៊ើសង្កាត់ទៅនឹងសំអាងជាច្រើន ថាពិតជាបានសាងសង់បាន២៧ជាន់តាមការព្រមព្រៀងប្រាកដមែន។ មិនមានភាពចាំបាច់ដើម្បីលុបចោលដីកាសម្រេចរក្សាការពារ ដោយសារអគារនេះ គឺកូនក្តីខ្លួនជាអ្នកសាងសង់ និងកូនបំណុលជំពាក់ប្រាក់កូនក្តីខ្លួនជាង២,៥៤០,០០០$ មែន ។ បើសិនជាការលើកឡើងរបស់មេធាវីកូនបំណុល និយាយថាអគារមិនទាន់ធ្វើហើយ គឺកាន់តែមិនអាចយកទៅលក់ជួលបាន។ ដោយមិនមានភស្តុតាងថ្មី នាំឱ្យលុបដីកាសម្រេចរក្សាការពារនោះទេ ស្នើសុំឱ្យតុលាការមេត្តាតំកល់ដីកាសម្រេចរក្សាការពារទុកនៅដដែល។ តុលាការយល់ឃើញថា ការលើកឡើងនេះ អាចឱ្យតុលាការពិចារណាបាន ។

២.៥. តុលាការយល់ឃើញថា ការទាមទាររបស់កូនបំណុលមិនមានហេតុផលសមរម្យ អាចឱ្យតុលាការសម្រេចលុបចោលដីកាសម្រេចរក្សាការពារនេះទេ ដូចនេះតុលាការគប្បីសម្រេចទទួលស្គាល់ដីកាសម្រេចរក្សាការពារ លេខ ៣៧៥ តរ/២០ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

២.៦. ដីកាសម្រេចរក្សាការពាររបស់សាលាដំបូងខេត្តព្រះសីហនុនេះ ជាវិធានការបណ្តោះអាសន្នបណ្តោះដើម្បីធានាភាពចាំបាច់ នូវសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីមានការប្រញាប់ ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ តាមបញ្ញត្តិមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

<u>សេចក្តីសម្រេចបញ្ចប់</u>

១. ច្រានចោលពាក្យសុំតវ៉ាដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ របស់មេធាវី និងលោក តំណាងដោយអាណត្តិឱ្យកូនបំណុលឈ្មោះ ចោលជាអាសាបង់ចាប់ពីពេលនេះតទៅ ។

២. ទទួលស្គាល់ដីកាសម្រេចរក្សាការពារ លេខ ៣៧៥ តរ/២០ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល។

៣. រឹបអូសប្រាក់ពន្ធលើពាក្យសុំតវ៉ា ដែលកូនបំណុលបានបង់ទុករួច ។

៤. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

-ដីកាសម្រេចនេះអាចប្តឹងជំទាស់បានក្នុងអំឡុងពេលពីរសប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចនេះ តាមមាត្រា៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ២០២០
ក្រឡាបញ្ជី

# ឧបសម្ព័ន្ធទី ៤
# ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ

25-8-2010

ស. សាលាដំបូងខេត្តព្រះសីហនុ
បញ្ជី ...៣៧៩៣...
ថ្ងៃ ២៥ ខែ ៨ ឆ្នាំ ២០១០
ម៉ោង ១៥ ... ៤០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ

**<u>មេធាវីតំណាងដោយអាណត្តិ</u>** ៖ មេធាវី [illegible] អត្តលេខ [illegible] ពីជាមេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា នាមករណ៍៖ ការិយាល័យមេធាវី [illegible] ដែលមានទីតាំងស្ថិតនៅផ្ទះលេខ [illegible] ផ្លូវលេខ ២៣បេ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [illegible] មានទូរស័ព្ទទំនាក់ទំនងលេខ ([illegible]) ។

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តព្រះសីហនុ**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំលុបចោលដីកាសម្រេចរក្សាការពារលេខ ៨៧ ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តព្រះសីហនុ ។

**<u>យោង</u>** ៖ - ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

- សំណុំរឿងចាត់ចែងរក្សាការពារលេខ ២៦ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តព្រះសីហនុ។
- ដីកាសម្រេចរក្សាការពារលេខ ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តព្រះសីហនុ ។

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរព និងជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាប៖ កូនក្តីខ្ញុំបាទបានចូលកាន់កាប់ដីនៅឆ្នាំ១៩៨៧ ដែលមានទីតាំងស្ថិតនៅ ភូមិមណ្ឌល០៣ សង្កាត់លេខ០១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ក្រោយមកនៅឆ្នាំ១៩៨៩ គាត់ក៏បានដាក់ពាក្យសុំកាន់កាប់ដីធ្លីដែលមានបង្កាន់ដៃលេខ [illegible] ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៨៩ បន្ទាប់មកនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩១ គណៈកម្មការបានចុះអង្កេត និងពិនិត្យវាស់វែងដីនេះ និងបានចេញប័ណ្ណសំគាល់កម្មសិទ្ធិលេខ [illegible] ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២ ឲ្យមកកូនក្តីខ្ញុំបាទឈ្មោះ [illegible] ប្រើប្រាស់តាមផ្លូវច្បាប់។ ស្រាប់តែនៅឆ្នាំ១៩៩៤ ឈ្មោះ [illegible] ជាអ្នកតំណាងកម្មករអគ្គិសនីក្រុងព្រះសីហនុ ចំនួន ៥៦ (ហាសិបប្រាំមួយ) នាក់ បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តព្រះសីហនុ ទាំងបំពានថា កូនក្តីខ្ញុំបានរំលោភយកដីរបស់ខ្លួន ដោយគ្មានភស្តុតាងណាមួយមកបញ្ជាក់សាលាដំបូងនោះទេ ដូចនេះ នាំឲ្យសាលាដំបូងបានសម្រេចសេចក្តីកាត់ដីនេះមកឲ្យកូនក្តីខ្ញុំ ពេលនោះពួកគេក៏បានប្តឹងមកដល់សាលាឧទ្ធរណ៍ និងតុលាការកំពូល តែចុងក្រោយនៅឆ្នាំ២០០៧ តុលាការកំពូលក៏បានចេញសាលដីកា ដោយ

ភូមិមណ្ឌល០៣ សង្កាត់លេខ០១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានប័ណ្ណសំគាល់ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២ ឲ្យទៅឈ្មោះ ដែលជាកូនក្តីខ្ញុំបាទ។ ស្រាប់តែនៅឆ្នាំ២០០៨ ឈ្មោះ និងបក្ខពួក បានទៅដាក់ពាក្យសុំដីកាសម្រេចរក្សាការពារលើដីរបស់កូនក្តីខ្ញុំបាទ ដោយបានបង្កើត និងប្រើឯកសារក្លែង ០១(មួយ) គឺបង្កាន់ដៃទទួលពាក្យ ចុះថ្ងៃ១៥ ខែកុម្ភៈ ឆ្នាំ១៩៩២ របស់ការិយាល័យកសិកម្មស្រុកនាំឲ្យតុលាការ នៃសាលាដំបូងផ្អែកលើឯកសារក្លែងនេះ ចេញដីកាសម្រេចរក្សាការពារ ហាមឃាត់មិនឲ្យកូនក្តីខ្ញុំ លក់ ដូរ ផ្ទេរសិទ្ធិ ជួល បញ្ចាំ ធ្វើសំណង់លើដីនេះឡើយ។ ពេលគឺដីកាសម្រេចរក្សាការពារនេះ ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កូនក្តីខ្ញុំបាទយ៉ាងខ្លាំង ដោយហេតុថាតុលាការកំពូលបានចេញសាលាដីកាលេខ ៩៦ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ដោយឲ្យដីខាងលើនេះមកកូនក្តីខ្ញុំបាទជាអ្នកមានសិទ្ធិកាន់កាប់ស្របច្បាប់ មិនមានឈ្មោះ មកពាក់ព័ន្ធនៅក្នុងសាលដីកានេះនោះទេ។ រហូតមកដល់ពេលនេះកូនក្តីខ្ញុំបាទបានទៅធ្វើប័ណ្ណប្រព័ន្ធថ្មី ស្រាប់តែខាងសុរិយោដីថាដីនេះនៅជាដីកាសម្រេចរក្សាការពាររបស់ឈ្មោះ នៅវិញ ។ ដូច្នេះហើយ ទើបខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិដាក់ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារដូចមានក្នុងកម្មវត្ថុខាងលើ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចលុបចោលដីកាសម្រេចរក្សាការពារលេខ ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តព្រះសីហនុ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃចន្ទ ៦កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅខេត្តព្រះសីហនុ, ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០

**ហត្ថលេខា និងត្រា**

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

# ឧបសម្ព័ន្ធទី ៥
# ដីកាសម្រេចលុបចោលដីកាសម្រេច
# ក្សាការពារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
ដីកាសម្រេច
លេខ ៦៧១......... ត.រ/២០
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០

## ដីកាសម្រេច
## លុបចោលដីកាសម្រេចរក្សាការពារ

យើង ចៅក្រម សាលាដំបូងខេត្តព្រះសីហនុ ។

*-បានឃើញក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើ តាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦-០៧-២០០៦ ។*

-បានឃើញ សំណុំរឿងរក្សាការពារលេខ១០៩ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាសម្រេចរក្សាការពារលេខ៤៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ។

-បានឃើញពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ របស់លោកមេធាវី តំណាងដោយអាណត្តិឱ្យឈ្មោះ ។

**-ភាគីសហម្ចាស់បំណុល:**

-ឈ្មោះ ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិ៣ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

-ឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិ៣ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

-ឈ្មោះ ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី១៩ ភូមិ៣ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាតំណាងអោយប្រជាជន៥៨គ្រួសារ ។

ដោយមានលោកមេធាវី មានការិយាល័យក្រុម ផ្លូវ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាអ្នកតំណាងដោយអាណត្តិឱ្យសហម្ចាស់បំណុល ។

**-ភាគីកូនបំណុល:**

-ឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៤៦ និងប្រពន្ធឈ្មោះ កើតនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៤៩ ជនជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ២៤ ផ្លូវ២០០ ភូមិ១ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានមេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យកូនបំណុល ។

កម្មវត្ថុបណ្ដឹង៖ ប្ដឹងសុំលុបចោលដីកាសម្រេចរក្សាការពារ លេខ ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ។

គូនបំណុលស្នើសុំដាក់កស្តុតាងជាឧបសម្ព័ន្ធ៖

- កំណត់ហេតុអង្កេតដី ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២ ។
- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២។
- សាលដីកាលេខ៩៦ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧ របស់តុលាការកំពូល ។

## សេចក្តីបញ្ជាក់ដំបូង

- លោកមេធាវី តំណាងដោយអាណត្តិឱ្យកូនបំណុលឈ្មោះ បានធ្វើសេចក្តីបញ្ជាក់ដំបូងថាៈខ្ញុំបាទសុំឱ្យតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារលេខ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ នៅលើដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២ ទំហំ ១៧០ម គុណនឹង៦៨០ម៉ែត្រ មានទីតាំងស្ថិតនៅមណ្ឌល៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ចោលជាអសារបង់ ។

-សិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលនឹងត្រូវលុបដីកាសម្រេចរក្សាការពារ ៖ កូនក្តីខ្ញុំបាទបានចូលកាន់កាប់ដីនៅឆ្នាំ១៩៨៧ ដែលមានទីតាំងនៅមណ្ឌល៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ក្រោយមកនៅឆ្នាំ១៩៨៩ គាត់ក៏បានដាក់ពាក្យសុំកាន់កាប់ដីធ្លីដែលមានបង្កាន់ដៃលេខ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៨៩ ។ បន្ទាប់មកនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩១ គណៈកម្មការបានចុះអង្កេត និងពិនិត្យវាស់វែងដីនេះ និងបានចេញប័ណ្ណសំគាល់កម្មសិទ្ធិលេខ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២ ឱ្យមកកូនក្តីខ្ញុំបាទឈ្មោះ ប្រើប្រាស់តាមផ្លូវច្បាប់ ។ ស្រាប់តែនៅឆ្នាំ១៩៩៤ ឈ្មោះ ជាអ្នកតំណាងកម្មករអគ្គិសនីក្រុងព្រះសីហនុចំនួន៥៦នាក់ បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តព្រះសីហនុទាំងបំពានថា កូនក្តីខ្ញុំបាទរំលោភយកដីរបស់ខ្លួន ដោយគ្មានភស្តុតាងណាមួយមកបញ្ជាក់សាលាដំបូងនោះទេ ដូចនេះនាំឱ្យសាលាដំបូងបានសម្រេចសេចក្តីកាត់ដីនេះមកឱ្យកូនក្តីខ្ញុំ ពេលនោះពួកគេក៏បានប្តឹងមកដល់សាលាឧទ្ធរណ៍ និងតុលាការកំពូល តែចុងក្រោយនៅឆ្នាំ២០០៧ តុលាការកំពូលក៏បានចេញសាលដីកា ដោយប្រគល់ដីទំហំ ១៧០ម គុណនឹង៦៨០ម ស្ថិតនៅមណ្ឌល៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានប័ណ្ណសំគាល់លេខ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២ ឱ្យទៅឈ្មោះ ដែលជាកូនក្តីខ្ញុំ ។ ស្រាប់តែនៅឆ្នាំ២០០៨ ឈ្មោះ និងបក្ខពួក បានទៅដាក់ពាក្យសុំដីកាសម្រេចរក្សាការពារលើដីរបស់កូនក្តីខ្ញុំបាទ ដោយបានបង្កើត និងប្រើឯកសារក្លែង មួយ គឺបង្កាន់ដៃទទួលពាក្យ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩២ របស់ការិយាល័យកសិកម្មស្រុកនាំឱ្យតុលាការ

នៃសាលាដំបូងផ្អែកលើឯកសារក្លែងនេះ ចេញដីកាសម្រេចរក្សាការពារ ហាមឃាត់មិនឱ្យកូនក្តីខ្ញុំ លក់ ដូរ ផ្ទេរសិទ្ធិ ជួល បញ្ចាំ ធ្វើសំណង់លើដីនេះឡើយ ។ ពោលគឺដីកាសម្រេចរក្សាការពារនេះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កូនក្តីខ្ញុំបាទយ៉ាងខ្លាំង ដោយហេតុថាតុលាការកំពូលបានចេញសាលដីកាលេខ ៩៦ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ដោយឱ្យដីខាងលើនេះមកកូនក្តីខ្ញុំបាទជាអ្នកមានសិទ្ធិកាន់កាប់ស្របច្បាប់ មិនមានឈ្មោះ [illegible] មកពាក់ព័ន្ធនៅក្នុងសាលដីកានេះនោះទេ ។ រហូតមកដល់ពេលនេះ កូនក្តីខ្ញុំបាទបានទៅធ្វើប័ណ្ណជាប្រព័ន្ធថ្មី ស្រាប់តែខាងសុរិយោដីប្រាប់ថាដីនេះនៅជាប់ដីកាសម្រេចរក្សាការពាររបស់ឈ្មោះ [illegible] ទៅវិញ ។ ជាពិសេសជាងនេះទៅទៀតនោះគឺបន្ទាប់ពីសាលាដំបូងខេត្តព្រះសីហនុបានចេញដីកាសម្រេចរក្សាការពាររួចមក សាលាដំបូងខេត្តព្រះសីហនុ ក៏បានចេញដីកាសម្រេចបង្គាប់ឱ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៨ ដោយមានខ្លឹមសារថា បង្គាប់មកលោក [illegible] , [illegible] , [illegible] ដាក់ពាក្យបណ្តឹងអង្គសេចក្តីពាក់ព័ន្ធនឹងដីទំនាស់ខាងលើក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចនេះ ។ ផុយមកវិញរហូតមកដល់ឆ្នាំ២០២០ នេះ សហម្ចាស់បំណុលទាំងអស់មិនមានដាក់ពាក្យបណ្តឹងអង្គសេចក្តីឡើយ ។

<u>-ភាពចាំបាច់នៃការលុបចោលដីកាសម្រេចរក្សាការពារៈ</u> ការរឹបអូសជាបណ្តោះអាសន្ន ដោយការដាក់ប្រាតិភោគជាដីកម្មសិទ្ធិរបស់កូនក្តីខ្ញុំបាទ ដែលហាមឃាត់កូនក្តីខ្ញុំបាទមិនឱ្យលក់ ឬ ផ្ទេរសិទ្ធិ ជួល ដាក់បញ្ចាំ ដាក់ហ៊ីប៉ូតែក ដាក់ធានា ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើប្រទានកម្ម ធ្វើសន្តតិកម្ម ឬធ្វើមតកសាសន៍ និងធ្វើការផ្សេងទៀត ជាហេតុធ្វើឱ្យកូនក្តីខ្ញុំមិនអាចប្រើប្រាស់ដីនេះបានពេញលេញ ដោយសេរី តាមទំហំដែលច្បាប់បានកំណត់ ពោលគឺមិនមានគ្រប់នូវសិទ្ធិទាំងបី របស់ម្ចាស់កម្មសិទ្ធិករ ដែលមានដូចជា សិទ្ធិកាន់កាប់ សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលនោះទេ ។ ដូច្នេះ ដើម្បីកុំឱ្យមានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់កូនក្តីខ្ញុំបាទតទៅទៀត ទើបរូបខ្ញុំបាទដាក់ពាក្យសុំ ដើម្បីលុបចោលដីកាសម្រេចរក្សាការពារលេខ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តព្រះសីហនុ ក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពួកគាត់ ។ នៅពេលដែលទទួលបានដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារចាស់ ដីកាសម្រេចថ្មីនេះ នឹងផ្តល់យុត្តិធម៌ដល់កូនក្តីខ្ញុំ ស្របតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពីព្រោះបានជួយបញ្ចប់នូវព្យសនកម្មឬការខូចខាតដែលកើតមានកន្លងមកចំពោះពួកគាត់ ។

<u>-អង្គច្បាប់នៃការលុបចោលដីកាសម្រេចរក្សាការពារៈ</u> យោងតាមមាត្រា៥៥៨ (ការលុបរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព)នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មានខ្លឹមសារថា ម្ចាស់បំណុលលែងមានសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ឬភាពចាំបាច់នៃរក្សាការពារទៀតហើយ ពីព្រោះការសម្រេចលើអង្គសេចក្តី ពោលគឺសាលដីកាសម្រេចលេខ៩៦ ចុះ

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ របស់តុលាការកំពូល ជាសាលដីកាបិទផ្លូវតវ៉ា និងបានចូលជាស្ថាពរ ដោយសម្រេចឱ្យឈ្មោះ (កូនបំណុល) ដែលជាកូនក្តីខ្ញុំបាទឈ្នះក្តីទទួលបានកម្មសិទ្ធិស្របច្បាប់លើដីនេះ ។ យោងតាមមាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មានខ្លឹមសារថា "តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល បើម្ចាស់បំណុល មិនដាក់ឯកសារតាមកាលកំណត់នោះទេ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល "។ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៨ តុលាការបានចេញដីកាសម្រេច បង្គាប់ឱ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី តែម្ចាស់បំណុលមិនមានដាក់ពាក្យបណ្តឹងអង្គសេចក្តីឡើយ ដូច្នេះជាមូលដ្ឋានដែលតុលាការត្រូវលុបដីកាសម្រេចរក្សាការពារនេះចោល ដើម្បីជៀសវាងបន្តប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់កូនក្តីខ្ញុំបាទ ។

## សំអាងហេតុ

តាមលទ្ធផល និងពិនិត្យភស្តុតាងនានាក្នុងសំណុំរឿងរួចមកឃើញថា៖

១. ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ប្តឹងសុំលុបចោលដីកាសម្រេចរក្សាការពារ លេខ ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ដូចមានចែងតាមមាត្រា៥៣៤ , មាត្រា**៥៥៧** និងមាត្រា៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. តាមសេចក្តីបញ្ជាក់ដំបូងរបស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុលថា ខ្លួនសុំឱ្យតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារលេខ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ នៅលើដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩២ ទំហំ ១៧០ម គុណនឹង ២៨០ម៉ែត្រ មានទីតាំងស្ថិតនៅមណ្ឌល៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ចោលជាអសារបង់ ដោយខ្លួនអះអាងថា បន្ទាប់ពីតុលាការចេញដីកាសម្រេចរក្សាការពារ តុលាការបានចេញដីកាសម្រេចបង្គាប់ឱ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៨ ក្នុងរយៈពេល៣០ថ្ងៃ ដោយឡែក សហម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីរហូតមកដល់ពេលនេះ ។ តុលាការយល់ឃើញថា ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល មានហេតុផលសមរម្យអាចឲ្យតុលាការយកមកពិចារណាបាន ។

៣. យោងតាមដីកាសម្រេចបង្គាប់ឱ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី លេខ១៣៧ តរ.០៨ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ បានសម្រេចបង្គាប់ឱ្យឈ្មោះ , ឈ្មោះ , ឈ្មោះ ដែលមានលោក ជាមេធាវីតំណាងដោយអាណត្តិ ដាក់ពាក្យបណ្តឹងអង្គសេចក្តីពាក់ព័ន្ធនឹងដីទំនាស់ខាងលើក្នុងរយៈពេល៣០ថ្ងៃចាប់គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចនេះ។ ក្នុងករណីដែលបានដាក់ពាក្យបណ្តឹងអង្គសេចក្តីរួចហើយ ត្រូវថតចម្លងពាក្យបណ្តឹង បង្កាន់ដៃបង់ពន្ធ និងលេខសំណុំរឿងមកតុលាការ ។ ដោយឡែក មកដល់ពេលនេះ តុលាការមិនទាន់បានឃើញពាក្យបណ្តឹង ឬ បង្កាន់ដៃបង់ពន្ធឡើយ ។

៤. ផ្អែកតាមមាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌ៣ ចែងថា បើម្ចាស់បំណុលមិនដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹង ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ដូច្នេះ តុលាការគប្បីសម្រេចលុបចោលដីកាសម្រេចរក្សាការពារលេខ ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ។

## សេចក្តីសម្រេចបញ្ចប់

១. សម្រេចលុបចោលដីកាសម្រេចរក្សាការពារលេខ៨៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ចាប់ពីពេលនេះតទៅ។

២. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ

ចៅក្រម

# ឧបសម្ព័ន្ធទី ៦
# ពាក្យបណ្តឹងជំទាស់នឹងដីកាសម្រេច
# រក្សាការពារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

—※—

សា.លាដំបូងខេត្តព្រះសីហនុ
ចូល លេខ: ១៧២៣ ឆ.ប
ថ្ងៃទី ២៥ ខែ ១០ ឆ្នាំ ២០១៩
ម៉ោង: ១០ និង ៤០

**ពាក្យបណ្តឹងជំទាស់នឹងដីកាសម្រេចរក្សាការពារ**

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ២៩ឆ្នាំ មានអាសយដ្ឋានផ្ទះលេខ ផ្លូវជាតិលេខ ៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ រាជធានីភ្នំពេញ ជាម្ចាស់បំណុល ក្នុងសំណុំរឿងរក្សាការពារលេខ ១០៣ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ។

**សូមគោរពចូលមក**

**លោកប្រធានសាលាដំបូងខេត្តព្រះសីហនុ**

*សូមទានជ្រាប!*

**កម្មវត្ថុ:** សុំប្តឹងជំទាស់នឹងដីកាសម្រេចរក្សាការពារលេខ ១១៦៥ ត.រ/១៩ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ។

**យោង:** -សំណុំរឿងរក្សាការពារលេខ ១០៣ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា: ការចេញដីកាសម្រេករក្សាការពារលេខ ១១៦៥ ត.រ/១៩ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍របស់ខ្ញុំបាទ។ ហេតុដូច្នេះ ខ្ញុំបាទសុំប្តឹងជំទាស់នឹងដីកាសម្រេចរក្សាការពារលេខ ១១៦៥ ត.រ/១៩ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ នូវចំណុចទាំងមូល ។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាទទួលពាក្យបណ្តឹង ដូចមានចែងក្នុងកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

សព្រះសីហនុ. ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៩

ស្នាមមេដៃ និងឈ្មោះ



# ឧបសម្ព័ន្ធទី ៧
# ពាក្យបណ្តឹងជំទាស់

ក្រុមមេធាវី LAW GROUP

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
ចូល
លេខ: ៤៣២ ...
ថ្ងៃខែឆ្នាំ: ៧ ... ២០២០
ម៉ោង: ១១ ... ០០

## ពាក្យបណ្តឹងជំទាស់

មេធាវី សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ អាសយដ្ឋានលេខ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យរាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ អាយុ៦៨ឆ្នាំ ជនជាតិខ្មែរ គឺជាភាគីកូនបំណុលនៃសំណុំរឿងរក្សាការពារលេខ ៨៣ ចុះថ្ងៃទី២២-០៣-២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ។

### សូមគោរពជូនមក

### លោកប្រធានសាលាដំបូងខេត្តព្រះសីហនុ

**កម្មវត្ថុ:** សុំប្តឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ានឹងដីកាសម្រេចចាត់ចែងរក្សាការពារលេខ ៥១ គ.រ/២០ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ គ្រប់សេចក្តីសម្រេចទាំងមូល។

**យោង:** -មាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បណ្តឹងជំទាស់។
-ដីកាសម្រេចលើកចោលពាក្យសុំតវ៉ានឹងដីកាសម្រេចចាត់ចែងរក្សាការពារលេខ៥១ គ.រ/២០ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានមេត្តាជ្រាបថា សាលាដំបូងខេត្តព្រះសីហនុបានចេញដីកាសម្រេចលើកចោលពាក្យសុំលេខ៥១ គ.រ/២០ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ដោយសម្រេចលើកចោលពាក្យសុំតវ៉ានឹងដីកាសម្រេចចាត់ចែងរក្សាការពាររបស់ខ្ញុំបាទចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៩។ ដីកានេះសម្រេចមិនត្រឹមត្រូវ និងមិនបានផ្តល់.../



អាសយដ្ឋាន: 1075 ផ្លូវជាតិលេខ2 សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
A21 ផ្លូវជាតិលេខ4 ភូមិ1 សង្កាត់លេខ ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទ: 012 446602 / 071 8333 999
E-mail:

យុត្តិធម៌ដល់រូបខ្លួនខ្ញុំបាទឡើយ។ ដូច្នេះ ខ្ញុំសូមប្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំលេខ៥១ ត.រ/២០ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ខាងលើនេះគ្រប់សេចក្ដីសំរេចទាំងមូល។

អាស្រ័យហេតុដូចបានជម្រាបខាងលើ សូម លោកប្រធាន មេត្តាទទួលពាក្យបណ្ដឹងរបស់ខ្ញុំបាទចាត់ការតាមនីតិវិធីច្បាប់ចាប់ពីពេលនេះតទៅ។

សូម លោកប្រធាន មេត្តាទទួលនូវការគោរពអំពីខ្ញុំ។

ភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

**ហត្ថលេខានិងត្រា**

# ឧបសម្ព័ន្ធទី ៨
# ដីកាសម្រេចលើបណ្ដឹងជំទាស់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# ដីកាសម្រេច

សំណុំរឿងដីកាសម្រេច
លេខ ៨៧ (ដ)/២៨-០៥-២០២០
ដីកាសម្រេច
លេខ ៣៦ ក្រ III "ឃ" ដកស
ចុះថ្ងៃទី ២៨-០៨-២០២០

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នា ថ្ងៃទីដប់បួន ខែសីហា ឆ្នាំពីរពាន់ម្ភៃ ដោយមាន៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

| | |
|---|---|
| ឯកឧត្តម | ប្រធានក្រុមប្រឹក្សា |
| លោក | ចៅក្រមប្រឹក្សា |
| លោក | ចៅក្រមប្រឹក្សា |

## ក្រឡាបញ្ជី

## ភាគី

**ម្ចាស់បំណុល៖** ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវលេខ ៤០០ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កូនបំណុល៖** ឈ្មោះ ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវលេខ ៤០០ ភូមិ៨ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិមេធាវី មេធាវី និងមេធាវី ។

**១-ខ្លឹមសារនៃដីកាសម្រេចដែលម្ចាស់បំណុលទាមទារ៖**

សុំឲ្យចេញដីកាសម្រេចរក្សាការពារហាមឃាត់ឈ្មោះ និងតតិយជន មិនឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិលក់ ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិចាត់ចែង អាស្រ័យផល ធ្វើអំណោយ និងសាងសង់សំណង់ផ្សេងៗ ចាក់ដី កាយព្រំ បណ្តាលឲ្យខុសពីរូបភាពដើម នូវលើដីទំហំ ៩៥.៥០០ ម² (ប្រាំបួនម៉ឺនប្រាំពាន់ប្រាំរយ) ម៉ែត្រការ៉េ ដែលមាន៖

ក. ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ពន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលមានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវរថភ្លើង ខាងត្បូងទល់នឹងផ្លូវជាតិលេខ៤ ខាងកើតទល់នឹងបាំង ម៉ុងគិត និងខាងលិចទល់នឹងផ្លូវ មានទីតាំងនៅតំបន់ទួលឃាយម៉ៅ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ ។

ខ. ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ពន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលមានព្រំប្រទល់ខាងជើងទល់នឹងរថភ្លើង ខាងត្បូងទល់នឹងផ្លូវជាតិលេខ ៤ ខាងកើតទល់នឹង និងខាងលិចទល់

និង មានទីតាំងនៅតំបន់ទួលឃាយម៉ៅ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

**ឫានឃើញ** ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ១២០១ តរ/១៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

**ឫានឃើញ** ដីកាសម្រេចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៣៣ តរ/២០ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

**ឫានឃើញ** ពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២០ និងសេចក្តីចម្លងបណ្តឹងជំទាស់លេខ ០៩ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២០ របស់លោក តំណាងដោយអាណត្តិឱ្យឈ្មោះ សុំប្តឹងជំទាស់នឹងដីកាសម្រេចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៣៣ តរ/២០ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ របស់សាលាដំបូងរាជខេត្តព្រះសីហនុ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេចបញ្ចប់ ។

**២-អំពីសេចក្តីថ្លែងការណ៍**

មេធាវី ធ្វើសេចក្តីថ្លែងការណ៍: ពាក់ព័ន្ធនឹងរឿងនេះ ដោយផ្អែកលើលិខិតស្នាមដែលមានប្លង់ដីរបស់ខាងឈ្មោះ ដែលមិនមែនជាប្លង់ដីរបស់កូនក្តីខ្លួននោះទេ ដូចមានក្នុងឯកសារដែលគាត់បានយកប្លង់ដីចំនួនពីរមកធ្វើការហាមឃាត់ដីរបស់កូនក្តីខ្លួនដែលមានទីតាំងដីខុសគ្នា ដោយសារទីតាំងដីរបស់កូនក្តីខ្លួនបានទិញតាំងពីឆ្នាំ ១៩៩២ ពីប្រជាជន បន្ទាប់មកគាត់បានធ្វើប្លង់LMap នៅឆ្នាំ ២០០៩ ។ ក្រោយពីបានចេញប្លង់ LMap រួចហើយកូនក្តីខ្លួនបានធ្វើរបង រស់នៅ កាន់កាប់ អាស្រ័យផល មកដល់បច្ចុប្បន្ននេះ មានន័យថាការប្តឹងសុំហាមឃាត់ដីរបស់ភាគីម្ចាស់បំណុល គឺគាត់បានប្តឹងហាមឃាត់ដីទីតាំងខុស ដោយបានប្តឹងហាមឃាត់ដីកន្លែងផ្សេង មកធ្វើការហាមឃាត់ដីរបស់កូនក្តីខ្លួនដែលមានទីតាំងដាច់ស្រលះដូចមាននៅក្នុងលិខិតបំភ្លឺរបស់សុរិយោដីលេខ រប.ងនសស/ខសន ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ បានឆ្លើយតបមកតុលាការវិញហើយថាការហាមឃាត់នេះ គឺប័ណ្ណរបស់ភាគីខាង គឺជាប័ណ្ណនៅទីតាំងផ្សេង រីឯប័ណ្ណនៅទីតាំងដីរបស់កូនក្តីខ្លួនមានទីតាំងខុសគ្នា-ចំពោះទីតាំងរបស់កូនក្តីខ្លួនបានចុះបញ្ជីប័ណ្ណកម្មសិទ្ធិរួចហើយ រីឯដីរបស់ឈ្មោះ ដែលបានដាក់ពាក្យប្តឹងនោះមិនទាន់បានចុះបញ្ជីដីនៅឡើយទេ ដែលបញ្ជាក់យ៉ាងច្បាស់ថា ទីតាំងដីដែលបានដាក់រក្សាការពារនោះខុសគ្នា ទាំងទំហំ និងទីតាំងដី ទើបតុលាការខេត្តព្រះសីហនុបានចេញដីកាសម្រេចលុបចោលនូវដីកាសម្រេចរបស់ខ្លួនទៅវិញ ដោយផ្អែកទៅលើឯកសារភស្តុតាងរបស់កូនក្តីខ្លួនដែលបានដាក់ជូនតុលាការថាមិនមែនជាដីដែលជាកម្មវត្ថុដែលគាត់ប្តឹងសុំហាមឃាត់នោះទេ ទើបតុលាការខេត្តព្រះសីហនុចេញដីកាសម្រេចលេខ: ២៣៣ តរ/២០ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ ។ ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចតម្កល់នូវដីកាសម្រេចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ: ២៣៣ តរ/២០ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។

មេធាវី ធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍ [illegible] ចំនួន និងខ្លួនសូមធ្វើការលើបន្ថែមមួយចំនួនទៀតលើការដាក់ពាក្យសុំរបស់ម្ចាស់បំណុល ។ [illegible]

ពាក្យសុំរបស់ម្ចាស់បំណុលដែលមុននឹងធ្វើការដាក់ពាក្យសុំ ត្រូវបង្ហាញអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្ត ដែលត្រូវរក្សាការពារ និងភាពចាំបាច់ដែលត្រូវរក្សាការពារ ។ តាមសេចក្ដីបញ្ជាក់ដំបូង និងភស្តុតាងនានារបស់ម្ចាស់បំណុលពុំមានសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារនោះទេ តាមមាត្រា ៥៤១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថា ម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ។ ម្ចាស់បំណុលមិនបានបង្ហាញថាទ្រព្យដែលត្រូវរក្សាការពារនេះ ជាទ្រព្យរបស់កូនបំណុលនោះទេ ដោយគាត់លើកយកប័ណ្ណចំនួន ២ ដែលមានប័ណ្ណលេខ: ពន និងលេខ: ពន ដែលប័ណ្ណ២នេះ ម្ចាស់បំណុលបានអះអាងថាជាដីកម្មសិទ្ធិរបស់ឪពុកខ្លួនដែលបានស្លាប់ទៅឈ្មោះ ហើយក្រសួងដែនដីគាត់បានចេញលិខិតមួយមកសាលាដំបូងខេត្តព្រះសីហនុ ដែលបានបញ្ជាក់ហើយថា ទីតាំងដីនេះពុំស្ថិតជាមួយទីតាំងដីរបស់កូនក្ដីខ្លួននោះទេ ប័ណ្ណដែលឈ្មោះ

បានដាក់មកសុំរក្សាការពារខាងជំនាញមន្ទីរសុរិយោដីបានធ្វើការស្រាវជ្រាវ និងបានបញ្ជាក់យ៉ាងច្បាស់ថាម្ចាស់កម្មសិទ្ធិលើប័ណ្ណនេះមិនមែនឈ្មោះ នោះទេ។ ប័ណ្ណទី១ លេខ: ម្ចាស់កម្មសិទ្ធិឈ្មោះ ប័ណ្ណទី២លេខ: ម្ចាស់កម្មសិទ្ធិឈ្មោះ បើពិនិត្យលើពាក្យសុំបានដាក់នៅតំបន់ទួលយាយម៉ៅ ដែលមិនបានកំណត់ព្រំច្បាស់លាស់នោះទេ ដែលនៅក្នុងច្បាប់បានកំណត់ឱ្យបានច្បាស់ពីទ្រព្យរបស់កូនបំណុល មួយវិញទៀតនៅពេលដែលគាត់ដាក់ពាក្យសុំរក្សាការពារគាត់បានអះអាងថាគាត់ជាទាយាទ និងសន្តតិជន ប៉ុន្តែពុំមានសេចក្ដីសម្រេច ឬសាលក្រមណាមួយបញ្ជាក់ថាគាត់ជាសន្តតិជននោះទេ គាត់គ្រាន់តែយកសៀវភៅគ្រួសារមកបង្ហាញ ។ ចំណុចមួយទៀតចំពោះការបញ្ជាក់ពីព្រំប្រទល់ដែលគាត់បានស្នើសុំដាក់រក្សាការពារដែលបានបញ្ជាក់ថាដីនោះបានទិញពីឈ្មោះ ប៉ុន្តែដោយមានលិខិតបញ្ជាក់របស់ បានបញ្ជាក់ថាគាត់មិនដែលស្គាល់ឈ្មោះ នោះទេ ហើយគាត់ក៏មិនដែលបានលក់ដីមួយដុំឱ្យឈ្មោះ នោះដែរ ។ ម្ចាស់បំណុលពុំមានលក្ខណៈសម្បត្តិ និងភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់ជូនតុលាការ ក្នុងការចេញដីកាសម្រេចរក្សាការពារនោះទេ ដូច្នេះ ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចតម្កល់នូវដីកាសម្រេចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ: ២៣៣ តរ/២០ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។

## សំអាងហេតុ

១-បណ្ដឹងជំទាស់លេខ: ០៩ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២០ របស់លោក តំណាងដោយអាណត្តិឱ្យឈ្មោះ សុំប្ដឹងជំទាស់នឹងដីកាសម្រេចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២៣៣ ត.រ/២០ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី សភារដ្ឋប្បវេណីអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-សភារដ្ឋប្បវេណីបានធ្វើការបញ្ជូនដីកាកោះត្រឹមត្រូវតាមនីតិវិធីរួចហើយ ភាគីម្ចាស់បំណុលមិនបានចូលរួមក្នុងនីតិវិធីនេះ សភារដ្ឋប្បវេណីអាចបន្តនីតិវិធីបានដោយរាងការកកស្ទះសំណុំរឿង ។

៣-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិអោយកូនបំណុល និងតាមការពិនិត្យឯកសារដែលពាក់ព័ន្ធ ឃើញថាភាគីម្ចាស់បំណុល បានដាក់ពាក្យសុំរក្សាការពារលើទ្រព្យសម្បត្តិរបស់កូនបំណុល ប៉ុន្តែពុំមានភស្តុតាង និងឯកសារណាមកបញ្ជាក់ថាខ្លួនពិតជាមានទំនាក់ទំនងសិទ្ធិ និង គតិយុត្តដែលត្រូវរក្សាការពារបាននោះទេ ដូច្នេះតុលាការពុំសម្រេចតាមការស្នើសុំនោះទេ ។ ម្យ៉ាងទៀតតាមរបាយការណ៍លេខ របដនតសស/ខសន ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ និងពាក្យសុំឆ្លើយបំភ្លឺ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ របស់ឈ្មោះ ដែលបានបញ្ជាក់ថាការចាត់ចែងជាបណ្តោះអាសន្ន លើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ០២ ប័ណ្ណដែលមានលេខ ពន ( ) និងប័ណ្ណលេខ ពន ( ) មិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ ដែលជាឪពុករបស់ម្ចាស់បំណុលឈ្មោះ នោះទេ ដូច្នេះបញ្ជាក់អោយឃើញថាម្ចាស់បំណុលពុំមានសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារបាននោះទេ ។

៤-រឿងក្តីនេះ ចៅក្រមសាលាដំបូងបានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈច្បាស់លាស់ហើយ ហេតុដូច្នេះសភាសម្ប្បវេណីឯកភាពតាមសំអាងហេតុនេះ ពុំចាំបាច់លើកយកសំអាងហេតុដដែលមកបញ្ជាក់ជាថ្មីម្តងទៀតទេ ។

៥-ដីកាសម្រេចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៣៣ តរ/២០ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## សេចក្តីសម្រេចបញ្ចប់

១-ច្រានបណ្តឹងជំទាស់លេខ: ០៩ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២០ របស់លោក តំណាងដោយអាណត្តិឲ្យឈ្មោះ ចោល ។

២-តម្កល់ដីកាសម្រេចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២៣៣ តរ/២០ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីម្ចាស់បំណុល ។

ដីកាសម្រេចនេះប្រកាសជាសាធារណៈ នៅថ្ងៃ សុក្រ ១០ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ១០កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

សាលាឧទ្ធរណ៍ភ្នំពេញ,ថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០២០

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

# ឧបសម្ព័ន្ធទី ៩
# ដីកាសម្រេចលើបណ្តឹងជំទាស់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

**សំណុំរឿងលេខ ២៤២ (រ)**
ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៩
**ដីកាសម្រេច**
លេខ ៣៥/ក្រ III "ឃ" ដកស
ចុះថ្ងៃទី ២៥-០៨-២០២០

# ដីកាសម្រេច

បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នាថ្ងៃទីដប់មួយ ខែសីហា ឆ្នាំពីរពាន់ម្ភៃ ដោយមាន៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

| | | |
|---|---|---|
| លោក | | ប្រធាន |
| ឯកឧត្តម | | ចៅក្រមប្រឹក្សា |
| លោក | | ចៅក្រមប្រឹក្សា |

**ក្រឡាបញ្ជី**
**លោកស្រី**

-ម្ចាស់បំណុលឈ្មោះ ភេទប្រុស អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាន ក្រុម១៨ ភូមិ ២ សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

-អ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលឈ្មោះ មេធាវី មេធាវី និងមេធាវី ។

-សហកូនបំណុលឈ្មោះ ភេទប្រុស និងឈ្មោះ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋាន ភូមិ ៣ សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

-អ្នកតំណាងដោយអាណត្តិឱ្យសហកូនបំណុលឈ្មោះ និងឈ្មោះ មេធាវី ។

**ខ្លឹមសារនៃដីកាសម្រេចដែលម្ចាស់បំណុលសុំ៖**

-ប្ដឹងសុំឱ្យតុលាការចេញដីកាសម្រេចរក្សាការពារហាមឃាត់សហកូនបំណុល និងអ្នកដទៃមិនឱ្យលក់ ដូរ ផ្ទេរសិទ្ធិ ធ្វើអំណោយ ជួល បញ្ចាំ ធ្វើហ៊ីប៉ូតែក និងធ្វើការអ្វីៗលើដីមួយផ្នែកជ្រុងនៃទិសនិរតី មានទំហំបណ្ដោយផ្លូវបេតុងពីចំណុចល្ងដើមក្រខុបទៅជើងក្បាលប្រវែង ៥០ (ហាសិប) ម៉ែត្រ និងទទឹងពីចំណុចផ្លូវបេតុងទៅកើតប្រវែង ៥០ (ហាសិប) ម៉ែត្រ

មានផ្ទៃក្រឡា ២៥០០ (ពីរពាន់ប្រាំរយ) ម៉ែត្រការ៉េ (តាមការវាស់វែងជាក់ស្ដែង) មានទីតាំងស្ថិតនៅមណ្ឌល៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៩២ និងបង្គាប់ឱ្យកម្លាំងសាធារណៈចុះរុះរើរបង ។

**បានឃើញ** ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ **៦៣១ ត.រ/១៩** ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចសេចក្ដីដូចខាងក្រោម៖

១-លើកចោលពាក្យសុំចេញដីកាសម្រេចរក្សាការពាររបស់ម្ចាស់បំណុលឈ្មោះ ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៨ និងពាក្យសុំកែតម្រូវពាក្យសុំចេញដីកាសម្រេចរក្សាការពារបន្ថែម ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១៨ ។

២-រឹបអូសប្រាក់ប្រដាប់ក្ដីដែលម្ចាស់បំណុលបានបង់រួចហើយ ។

៣-ដីកាសម្រេចនេះ ធ្វើនៅថ្ងៃអង្គារ ២កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ ហើយភាគីម្ចាស់បំណុលអាចប្ដឹងជំទាស់បាន តាមបញ្ញត្តិមាត្រា ៥៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**បានឃើញ** បណ្ដឹងជំទាស់ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៩ និងសេចក្ដីចម្លងបណ្ដឹងជំទាស់លេខ ២៩ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៩ របស់មេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលឈ្មោះ ប្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ គ្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេចបញ្ចប់ ។

**អំពីសេចក្ដីថ្លែងការណ៍**

-មេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលឈ្មោះ បានធ្វើសេចក្ដីថ្លែងការណ៍ថា៖ នៅក្នុងរឿងនេះ ដីទំហំប្រហែល ២៥០០ (ពីរពាន់ប្រាំ-រយ) ម៉ែត្រការ៉េ ស្ថិតនៅក្នុងប័ណ្ណកម្មសិទ្ធិលេខ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៩២ ជារបស់កូនក្ដីខ្លួន ។ ចំពោះដីទំហំ ០៣ (បី) ហិកតា ៩៤ (កៅសិបបួន) អា និង ៨២ (ប៉ែតសិប-

ពីរ) សង្វីអា ដែលមានប័ណ្ណកម្មសិទ្ធិលេខ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៩២ ជារបស់ឪពុកកូនក្តីខ្លួន ដែលបានកាន់កាប់តាំងពីឆ្នាំ ១៩៩២ ក្រោយមក នៅឆ្នាំ ១៩៩៧ ឪពុករបស់កូនក្តីខ្លួនបានស្លាប់ កូនក្តីខ្លួនក៏បានប្តឹងសុំបែងចែកមរតក ដោយតុលាការបាន សម្រេចបែងចែកដីខាងលើនេះ មកឱ្យកូនក្តីខ្លួន និងម្តាយចុងឈ្មោះ ។ នៅឆ្នាំ ២០១២ សាលក្រមបានចូលជាស្ថាពរ និងបានអនុវត្តដោយបង្ខំលើសាលក្រមរួចរាល់ហើយ ដោយឱ្យកូនក្តីខ្លួនគ្រប់គ្រងជាកម្មសិទ្ធិ ស្រាប់តែនៅឆ្នាំ ២០១៤ បែរជាមានប័ណ្ណកម្មសិទ្ធិ ឈ្មោះ និងឈ្មោះ មកធ្វើការព័ទ្ធរបងលើដីរបស់កូនក្តីខ្លួន ថែមទាំង សង់ផ្ទះខ្ទមនៅលើដីរបស់កូនក្តីខ្លួនទៀត ទើបកូនក្តីខ្លួនប្តឹងចូលសាលាដំបូងខេត្តព្រះសីហនុ សុំឱ្យតុលាការសម្រេចឱ្យឈ្មោះ និងឈ្មោះ ុះរើរបងចេញពីលើដី ខាងលើ និងហាមឃាត់សហកូនបំណុល មិនឱ្យលក់ ដូរ ផ្ទេរសិទ្ធិ ធ្វើអំណោយ ជួល បញ្ចាំ ធ្វើហ៊ីប៉ូតែក និងធ្វើការផ្សេងៗ លើដីខាងលើនេះ ។ ចំពោះសំណុំរឿងអង្គសេចក្តី ប្តឹងសុំឱ្យ តុលាការសម្រេចលុបចោលឈ្មោះ និងឈ្មោះ ចេញពីប័ណ្ណកម្មសិទ្ធិ និងសុំទទួលស្គាល់ប័ណ្ណកម្មសិទ្ធិរបស់កូនក្តីខ្លួន និងប្រគល់ដីឱ្យកូនក្តីខ្លួនគ្រប់គ្រង កាន់កាប់ ជាកម្មសិទ្ធិវិញ ។

នៅដំណាក់កាលសាលាដំបូង និងគណៈកម្មាការចម្រុះ បាន ធ្វើការចុះវាស់វែងត្រង់ចំណុចដែលជាន់លើដីកូនក្តីខ្លួន ឃើញថា ពិតជាមានការជាន់លើដី របស់កូនក្តីខ្លួនប្រាកដមែន មិនមែនដូចការយល់ឃើញរបស់ចៅក្រមសាលាដំបូង នៅក្នុង ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ នោះទេ ខ្លួនសុំច្រានចោលការយល់ ឃើញរបស់ចៅក្រមសាលាដំបូងទាំងស្រុង ដោយសារមិនផ្អែកលើអង្គហេតុ និងអង្គច្បាប់ ។ ប័ណ្ណកម្មសិទ្ធិរបស់សហកូនបំណុល ដែលបានជាន់លើដីរបស់កូនក្តីខ្លួន បានប៉ះពាល់សិទ្ធិ កម្មសិទ្ធិរបស់កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ ជាពិសេស ការកសាងប័ណ្ណរបស់សហកូនបំណុល ដែល ជាន់មកលើកូនក្តីខ្លួន សហកូនបំណុលមិនបានជូនដំណឹងឱ្យបានត្រឹមត្រូវតាមនីតិវិធីនៃការ សាងប័ណ្ណ មកកូនក្តីខ្លួន ឬសាធារណៈជននោះទេ បែរនៅពេលបានទទួលប័ណ្ណកម្មសិទ្ធិ

ក៏ធ្វើការសង់រោង និងព័ទ្ធរបងកូនក្តីខ្លួនតែម្តង ។ ដោយសារដីខាងលើជារបស់កូនក្តីខ្លួន និងសំណុំរឿងអង្គសេចក្តីកំពុងតែដំណើរការនីតិវិធី ដូច្នេះ ការរក្សាការពារនៅតែមានភាពចាំបាច់នៅឡើយ សំណូមពរ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ មេត្តាសម្រេចលុបចោលដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ចោលជាអសារបង់ និងស្នើសុំសម្រេចចេញដីកាសម្រេចហាមឃាត់ ឱ្យកូនបំណុលរុះរើរបងចេញពីដីខាងលើ ហើយហាមឃាត់មិនសហកូនបំណុលធ្វើការលក់ ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ អំណោយទាន រហូតរង់ចាំដល់សំណុំរឿងអង្គសេចក្តីចប់ជាស្ថាពរ ។ របងនៅលើដីខាងលើនេះ មានប្រវែង ផ្នែកខាងមុខ ៥៧ (ហាសិបប្រាំពីរ) ម៉ែត្រ ចំណុចពីល្វ ដល់ផ្នែកខាងចុង និងបណ្តោយមានប្រហែលជាង ១.០០០ (មួយពាន់) ម៉ែត្រ ហើយដីរបស់កូនក្តីខ្លួនចាប់តាំងពីចំណុចល្វ តែដីរបស់សហកូនបំណុលជាន់ពាក់កណ្តាលលើដីរបស់កូនក្តីខ្លួន ។

-មេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យសហកូនបំណុលឈ្មោះ និងឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ សុំរក្សាសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០២០ ទុកជាបានការ និងធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា នៅក្នុងរឿងនេះ ម្ចាស់បំណុលបានប្តឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្ត-ព្រះសីហនុ ដោយម្ចាស់បំណុលបានលើកឡើងតែអង្គហេតុដដែលៗ ។

កន្លងមក ម្ចាស់បំណុលបានប្តឹងសុំរក្សាការពារច្រើនដងហើយ ហើយម្ចាស់បំណុលបានទទួលស្គាល់ទៀតថា នៅពេល បានចុះវាស់វែងលើដីទំនាស់នេះ តែម្ចាស់បំណុលក៏ពុំបានដាក់ភស្តុតាងនេះបញ្ចូលនៅក្នុងសំណុំរឿង ដើម្បីឱ្យតុលាការពិនិត្យ ពិចារណានោះទេ ប៉ុន្តែភាគីកូនក្តីខ្លួនបានដាក់ភស្តុតាងចូលក្នុងសំណុំរឿងរួចហើយដោយបញ្ជាក់អំពីការវាស់វែងដីខាងលើ ឃើញថា ដីនេះ ពុំបានជាន់គ្នានោះទេ ។ មេធាវីតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលបានលើកឡើងដដែលថា ដីរបស់ម្ចាស់បំណុលជាន់នៅលើដីកូនក្តីខ្លួន ប៉ុន្តែនៅក្នុងពាក្យសុំ និងសេចក្តីបញ្ជាក់ដំបូង ប្រើតែពាក្យប្រហែលលើទំហំដីទាំងអស់ បញ្ហាមួយទៀត គឺភស្តុតាងជាផែនទី ដែលម្ចាស់បំណុលឈ្មោះ

បានផ្តិតស្នាមមេដៃទទួលស្គាល់ តាំងពីឆ្នាំ ២០១២ ដោយដីរបស់កូនក្តីខ្លួននៅសង្កាត់លេខ៣ ដោយមានអូរកាត់ទទឹង ។ ប្រសិនជាកូនបំណុលថា ដីរបស់កូនក្តីខ្លួនជាន់លើដីរបស់គាត់ពិតប្រាកដមែន ដូច្នេះ ដីប័ណ្ណកម្មសិទ្ធិផ្សេងទៀត ក៏ជាន់ដីរបស់គាត់ដូចគ្នា ព្រោះជាប់ព្រំប្រទល់ដីរបស់គាត់ដែរ ។ នៅក្នុងពាក្យសុំ និងសេចក្តីបញ្ជាក់ ទំហំដីរបស់ម្ចាស់បំណុលមានភាពមិនច្បាស់លាស់ ផ្ទុយនឹងមាត្រា ៥៤១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ម្យ៉ាងវិញទៀត ដីរបស់ម្ចាស់បំណុល មានទីតាំងស្ថិតនៅសង្កាត់លេខ១ ហើយដីរបស់កូនក្តីខ្លួនមានទីតាំងនៅសង្កាត់លេខ៣ ភូមិខុសគ្នា ខណ្ឌមិត្តភាព ។ សំណូមពរ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភា-រដ្ឋប្បវេណីសាលាឧទ្ធរណ៍ មេត្តាសម្រេចតម្កល់ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.វ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

## សំអាងហេតុ

*ក្រោយពីបានទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖*

១-បណ្តឹងជំទាស់ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៩ របស់មេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលឈ្មោះ ដែលប្តឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.វ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេចបញ្ចប់ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៥៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-មេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុល ប្តឹងជំទាស់មិនសុខចិត្តនឹងដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.វ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេចបញ្ចប់ ដោយស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍លុបចោលដីកាសម្រេចនេះ និងសម្រេចរក្សាការពារតាមពាក្យសុំរបស់ភាគីខ្លួន ប៉ុន្តែនៅដំណាក់កាលសាលាឧទ្ធរណ៍ ភាគីម្ចាស់បំណុលពុំមានភស្តុតាងថ្មី ផ្ទុយទៅនឹងសំអាងហេតុរបស់ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ លើកយកមកសំអាងក្នុងដីកាសម្រេចលើកចោល

ពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ឡើយ ។

៣-រឿងក្តីនេះ ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ បានលើកយកសំអាងហេតុមកបញ្ជាក់ក្នុងដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ មានភាពត្រឹមត្រូវហើយ ។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះសភាវដ្ឋប្បវេណីសាលាឧទ្ធរណ៍ ឯកភាពតាមសំអាងហេតុរបស់ចៅក្រមសាលាដំបូងខេត្តព្រះសីហនុទាំងមូល ដោយពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់លម្អិតជាថ្មីទៀតឡើយ ។

៤-សេចក្តីសម្រេចបញ្ចប់ នៃដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ មានមូលហេតុត្រឹមត្រូវ គប្បីក្រុមប្រឹក្សាជំនុំជម្រះសភាវដ្ឋប្បវេណីសាលាឧទ្ធរណ៍ ទទួលស្គាល់ទុកជាបានការដដែល ។ ចំពោះប្រាក់ប្រដាប់ក្តីវិញ គឺជាបន្ទុករបស់ម្ចាស់បំណុល ។

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលបណ្តឹងជំទាស់ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៩ របស់មេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុលឈ្មោះ ។

២-ទទួលស្គាល់ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារលេខ ៦៣១ ត.រ/១៩ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ម្ចាស់បំណុល ។

ដីកាសម្រេចនេះ ប្រកាសជាសាធារណៈ នៅថ្ងៃអង្គារ ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០២០ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

ថ្ងៃអង្គារ ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

សាលាឧទ្ធរណ៍ភ្នំពេញ, ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធទី ១០
# ក្រមនីតិវិធីរដ្ឋប្បវេណី
# គន្ថីទី ៧
# ការចាត់ចែងរក្សាការពារ

# គន្ថីទី ៧
# ការចាត់ចែងរក្សាការពារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៣០.-** គោលគំនិត

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៥៣១.-** ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗ ខាងក្រោមនេះ :

ក-ការរឹបអូសជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ-ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូល

ជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

**មាត្រា ៥៣២.-** ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

១-ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២-ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣-តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៣.-** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ។

**មាត្រា ៥៣៤.-** របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ :

ក-ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

ខ-ពាក្យបណ្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

គ-ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

ឃ-ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ង-ពាក្យបណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្ដឹងជំទាស់) នៃក្រមនេះ ។

ច-ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៥.-** ការសម្រេចសេចក្តីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១-ការសម្រេចសេចក្តីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និង នីតិ-វិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្តីអំពីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៦.-** ការផ្តល់នូវប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីធ្វើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៧.-** សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅតុលាការ ។

២-ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ។

៣-ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលា-ការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារ ឬ អាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន ។

៤-ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្តឹងជំទាស់បាន ។

៥-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

**មាត្រា ៥៣៨.-** ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

**មាត្រា ៥៣៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្លឹះទី ២ ដល់គន្លឹះទី ៤

បញ្ញត្តិពីគន្លឹះទី ២ ដល់គន្លឹះទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

## ជំពូកទី ២
## ដីកាសម្រេចរក្សាការពារ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៤០.-** តុលាការដែលមានសមត្ថកិច្ច

១-រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣-បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុល ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

**មាត្រា ៥៤១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូង

១-ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចបានកំណត់ខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

២-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

៣-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ៥៤២.–** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

**មាត្រា ៥៤៣.–** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

**មាត្រា ៥៤៤.–** បណ្ដឹងជំទាស់ចំពោះសេចក្ដីសម្រេចលើកចោល

១-ចំពោះសេចក្ដីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្ដឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

**មាត្រា ៥៤៥.–** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

**មាត្រា ៥៤៦.–** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្ដោះអាសន្ន អាចចេញបាន

ដោយមិនចាំបាច់កំណត់កម្មវត្ថុ ។

**មាត្រា ៥៤៧.-** ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះ-អាសន្ន ។

២-ការផ្ញើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

## ផ្នែកទី ៣
## ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

**មាត្រា ៥៤៨.-** ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ជាអាទិ៍

១-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

៤-តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការ

ទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

**មាត្រា ៥៤៩.–** វិធីចាត់ចែងជាបណ្ដោះអាសន្ន

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្ដល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

## ផ្នែកទី ៤
## ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥០.–** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

**មាត្រា ៥៥១.–** ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។

២-ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្ដី តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

៣-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥២.-** ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

**មាត្រា ៥៥៣.-** ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

**មាត្រា ៥៥៤.-** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២-ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

**មាត្រា ៥៥៥.-** ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់

ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងបាន តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៥៥៦.-** អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ

ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ ។

## ផ្នែកទី ៥
## ការលុបចោលដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥៧.-** ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍

១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្ដាហ៍ ។

៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤-ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែល

បានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ។

៥-ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្តឹងអង្គសេចក្តី។

៦-បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្តីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់។

៧-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្តឹងអង្គសេចក្តីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបានលើកចោល។

៨-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧។

**មាត្រា ៥៥៨.–** ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព

១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន។

២-ចំពោះការផ្លាស់ប្តូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកា

សម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥៩.-** ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេស

១-ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដីអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។

២-ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៦០.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការ-ពារ ជាអាទិ៍

១-បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) ។

២-ចំពោះការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្ត

ដូចគ្នា នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្ដឹងអង្គសេចក្ដី ផ្សេងពីតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ផ្នែកទី ៦
## បណ្ដឹងជំទាស់

**មាត្រា ៥៦១.-** បណ្ដឹងជំទាស់

១-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្ដឹងជំទាស់ក្នុងអំឡុងពេល២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ :

ក-ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ខ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ។

គ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៦០ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍) ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្ដីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលបានធ្វើឡើងដោយតុលាការនៃបណ្ដឹងជំទាស់ ។

២-អំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានទេ ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីបណ្ដឹងជំទាស់ ហើយបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៥២ (ការវិនិច្ឆ័យអំពីការតវ៉ា

ចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៣ (ការបញ្ឈប់ការវិនិច្ឆ័យ) និង មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីដែលពាក់ព័ន្ធនឹងបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសេចក្តីសម្រេចដែលអាចប្តឹងជំទាស់បាន បានចូលជាស្ថាពរ ។

៤-ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងករណីដែលមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ជំពូកទី ៣
## ការអនុវត្តរក្សាការពារ

**មាត្រា ៥៦២.–** ល័ក្ខខ័ណ្ឌនៃការអនុវត្តរក្សាការពារ

១-ការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត ។

២-ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ (ពីរ) សប្តាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

៣-ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារ អាចធ្វើបានដែរ ។

**មាត្រា ៥៦៣.-** ករណីពិសេសនៃតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងតវ៉ារបស់តតិយជន

ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) នៃក្រមនេះក៏ដោយ ក៏បណ្ដឹងតវ៉ារបស់តតិយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើ ក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ។

**មាត្រា ៥៦៤.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងជំពូកនេះ បញ្ញត្តិពីមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា) ដល់មាត្រា ៣៤៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៤៨ (អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ) បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ នៃមាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុ-វត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត) ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ពីមាត្រា ៣៥៧ (ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត) ដល់មាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត) មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) និង មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) និង បញ្ញត្តិពីមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ដល់មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ ។

**មាត្រា ៥៦៥.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ ។

២-អាជ្ញាសាលាត្រូវធ្វើប្រាក់ដែលបានមកពីការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ ។

៣-បើមានការបារម្ភថា ចលនវត្ថុដែលការរឹបអូសជាបណ្ដោះអាសន្នត្រូវបានអនុវត្តនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន ឬ កូនបំណុល ហើយធ្វើប្រាក់ដែលបានមកពីការលក់នោះនៅតុលាការដែលខ្លួនស្ថិតនៅ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្ដើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ដល់មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ។

**មាត្រា ៥៦៦.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុល ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ត្រូវមានសមត្ថ-

កិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្នុងករណីដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ បើកូនបំណុលទី៣បានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគដែលលើសពីចំនួនប្រាក់នោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា ៤០៤ (ទំហំនៃការរឹបអូស) ដល់មាត្រា ៤០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍) មាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) និងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះ-អាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេង ទៀត ។

**មាត្រា ៥៦៧.–** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាកាពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤២០ (ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូស

ជាអាទិ៍) វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ នៃមាត្រា ៤២១ (អានុភាពនៃការរឹបអូស) កថាខណ្ឌ ទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការ បាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) និង មាត្រា ៤២៨ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) នៃក្រមនេះ ត្រូវយកមកអនុ-វត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ។

**មាត្រា ៥៦៨.–** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) មាត្រា ៤៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍) និង មាត្រា ៤៦៦ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះ-អាសន្នតាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) កថាខណ្ឌទី ៧ នៃមាត្រា ៤៥៧ (ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍) មាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង

មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិត បញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

**មាត្រា ៥៦៩.–** ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ដោយធ្វើប្រាក់រំ-ដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-បើកូនបំណុលបានធ្វើប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុ-វត្តរក្សាការពារ ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តរឹប អូសជាបណ្ដោះអាសន្ន ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៥ (បណ្ដឹងជំទាស់ចំពោះដីកា សម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្លឹទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិ នៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

**មាត្រា ៥៧០.–** ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូស ជាបណ្ដោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ។

**មាត្រា ៥៧១.–** អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការ កាន់កាប់

១-បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យ អាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវ បានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការ ផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាស ជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬតាមរបៀបសមរម្យផ្សេងទៀត ។

២-បើការចាត់ចែងជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ។ ប៉ុន្ដែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ ។

៣-ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្ដោះ-អាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះ ត្រូវបានធ្វើហើយ ។